ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- អត្ថន័យនៃបទចម្រៀង៖ «អន្លង់វែងស្នេហា» និង «គ្មានឥន្ធនធនូស្នេហ៍»
- បងស្រីរបស់ខ្ញុំឈ្មោះ ផាន់នី និង បងប្អូនផ្សេងទៀត

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៣៨ ខែតុលា ឆ្នាំ២០១៩

# ស្វែងរកការពិត

លេខ២៣៨ ខែតុលា ឆ្នាំ២០១៩


## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

**សំបុត្រ**


◆ អត្ថន័យនៃបទចម្រៀង ....................................................១


**ផ្នែកឯកសារ**


◆ មើក សួន សមាជិកវរសេនាតូច ............................................៦

◆ ថោង ឈឺន ប្រធានសន្តិសុខ ............................................ ៩


**ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ**


◆ វត្តពោធិ៍កែវព្រះនេត្រព្រះ៖ អតីតមន្ទីរពេទ្យ..........................១៣

◆ បូជនីយដ្ឋានតម្កល់អដ្ឋិធាតុជនរងគ្រោះ .............................. ១៦

◆ គុលាការខ្មែរក្រហមដិតបញ្ចប់ ....................................... ១៨

◆ ក្មេងស្រី គួច សុឃីម មានសំណាង...................................២១

◆ កូនប្រុសត្រូវចេញតស៊ូបម្រើបដិវត្តន៍............................... ២៧

◆ ទស្សនៈយល់ឃើញរបស់ខ្ញុំអំពីអត្ថន័យឃ្លាន........................ ២៩

◆ រឿងរ៉ាវរបស់ ពុត សុផល ...............................................៣២

◆ គម្រោងប្រកួតជ្រើសរើសស្នាដៃតែងនិពន្ធរឿងខ្លី.................... ៣៥

◆ សេចក្ដីជូនដំណឹងការប្រកួតជ្រើសរើសស្នាដៃ....................... ៣៦


**ផ្នែកច្បាប់**


◆ សេចក្ដីសង្ខេបសាលក្រមសំណុំរឿង០០២/០២.................... ៣៨


**វេទិកាពិភាក្សាសាធារណៈ**


◆ បដិមាអ្នកតាព្រះភក្ត្រ៨ ................................................ ៤១

◆ «អន្ទង់វែងស្នេហា» និង «គ្មានឥន្ទធនូស្នេហ៍»..........................៤៣


**ទំព័រស្រាវជ្រាវរកគ្រួសារ**


◆ បងស្រីរបស់ខ្ញុំឈ្មោះដាន់នី ...............................................៤៨

◆ ប្រវត្តិរូប ប៉ែន អ៊ុន និង ប្រពន្ធ......................................... ៥០

◆ បញ្ជីឈ្មោះអ្នកដែលបានស្លាប់ ........................................ ៥២

◆ «ដេះដង់ធូលី» រឿងរ៉ាវចេញពីប្រជាជនថ្មី...............................៥៨




**មើង គីមសុន ប្រពន្ធរបស់ ឡាំ សុំ ឆ្នាំ១៩៦៥។ គាត់បានពាក់នាឡិកាដៃអូមេហ្គា១៨ការ៉ាត ហើយបានដូរយកស្ករពាគីឡូក្រាម និងទឹកដោះគោខាប់៥កំប៉ុង នៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។**


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម,៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩


រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា


**ស្នេរលេខនេះ៖** ឆាំង យុ, ផេង ពង្សរ៉ាស៊ី, ឡុង ដានី, សុខ វណ្ណៈរី លក្ខិណា, ឃិន សិលា, ដាត ចាន់សុនិតា, វ៉ាន់ថាន់ ពៅដារ៉ា **អ្នកនិពន្ធនិងស្រាវជ្រាវ៖** ហូ ថុនា,ដារ៉ារដ្ឋ មេត្តា, អ៊ុន សុដារី **អ្នកបកប្រែ៖** អ៊ុន សុដារី **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន **ជំនួយការនិពន្ធនាយក៖** ហូ ថុនា **ក្រាហ្វិកកុំព្យូទ័រ៖** ដាត ចាន់សុនិតា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង



**Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org**

# អត្ថន័យនៃបទចម្រៀង៖ «អន្លង់វែងស្នេហា» និង «គ្មានឥន្ទធនូស្នេហ៍»

***១) លោក ឆាំង យុ តើលោកអាចប្រាប់ទស្សនិកជនរបស់យើងបន្ថែមទៀត អំពីបទចម្រៀងទាំងពីរបទនេះបានដែរឬទេ?***

*បទចម្រៀងទាំងពីរបទនេះ និពន្ធទំនុកច្រៀង និងបទភ្លេងដោយ លោក ស៊ុំ សារឿន អតីតអ្នកចម្រៀងដើងចាស់ម្នាក់នឹងក៏ជាអតីតអ្នកនិពន្ធប្រចាំផលិតកម្មរស្មីហង្សមាស។ បទចម្រៀងទាំងពីរបទនេះ បានផ្តោតលើសាច់រឿងពីរខុសពីគ្នាក៏ប៉ុន្តែមានលក្ខណៈស្រដៀងគ្នា ដែលតំណាងឲ្យក្តីស្រឡាញ់ចំពោះប្រទេសកម្ពុជា និងឥទ្ធិពលទៅលើសហគមន៍ និងអត្តសញ្ញាណជាតិ ប្រវត្តិសាស្ត្រ នយោបាយ និងវប្បធម៌។ ចម្រៀងទាំងពីរបទនេះរៀបរាប់អំពីសេចក្តីស្នេហារវាងបុរសម្នាក់និងស្ត្រីម្នាក់ដែលមានក្តីស្នេហ៍ជាមួយនឹងគ្នា។ រៀបចំការផលិតដោយសនប៊ុនស៊ីមប្រធានផលិតកម្ម តន្ត្រីឥន្ទធនូនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំបាទសូមផ្ញើបទចម្រៀងទាំងពីរបទនេះ ជូនដល់អ្នកស្រុកអន្លង់វែងទាំងអស់ដែលបានចូលរួមចំណែកធ្វើឲ្យ មានសន្តិភាពជាប្រវត្តិសាស្ត្រនៅក្នុងប្រទេ-សកម្ពុជារបស់យើង។*



***លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និង លោកគ្រូ ស៊ុំ សារឿន អតីតអ្នកនិពន្ធទំនុកច្រៀង និងបទភ្លេង ប្រចាំផលិតកម្មហង្សមាស***

*បទចម្រៀងទីមួយគឺ «អន្លង់វែងស្នេហា» ច្រៀងដោយ ឱថាវ៉ែនបានបរិយាយអំពីសាច់រឿងរបស់បុរសម្នាក់ដែលជាអតីតយោធាខ្មែរក្រហម ហើយបានលង់ស្នេហ៍លើស្ត្រីម្នាក់។ ស្ត្រីរូបនោះគឺតំណាងឲ្យប្រទេសកម្ពុជា។ បុរសដែលជាអតីតយោធាខ្មែរក្រហមបានសុខចិត្តទម្លាក់អាវុធចុះ ដើម្បីមករួមរស់ជាមួយនារីដែលខ្លួនស្រឡាញ់ និង ដើម្បីបង្ហាញពីការប្តេជ្ញាចិត្តចំពោះសេចក្តីស្នេហារបស់ខ្លួន។នារីដ៏ស្រស់សោភាបានសន្យាថាមានសេចក្តីស្នេហា ប៉ុន្តែមិនបានប្តេជ្ញាចិត្តនឹងលះបង់ ចំពោះសេចក្តីស្នេហានោះឡើយ។ ដូច្នេះហើយនាងត្រូវបានប្រៀបប្រដូចទៅនឹងពពកនៅក្នុងវប្បធម៌ខ្មែរ។ពពកមានភាពស្រស់ស្អាត និងគួរឲ្យចាប់អារម្មណ៍។ ប៉ុន្តែពពកនោះក៏អាចប្រែទៅជាព្យុះភ្លៀងមួយរំពេច។ នៅពេលដែលទឹកភ្លៀងធ្លាក់ដល់ដីវានឹងប្រែទៅជាភក់ជ្រាំ។ សាច់រឿងនេះតំណាងឲ្យតំបន់អន្លង់វែងដែលជា ទីតាំងកាន់កាប់ចុងក្រោយរបស់ចលនាខ្មែរក្រហម ហើយដែលបានទម្លាក់អាវុធចុះ និងប្តេជ្ញាចិត្តរួមរស់ក្នុងសង្គមជាតិ ដោយជំនួសឲ្យការសន្យាមួយ។ បទចម្រៀងនេះបានបង្ហាញថាការសន្យាមិនត្រូវបានបំពេញនោះទេ។*

*បទចម្រៀងទីពីរគឺ «គ្មានឥន្ទធនូស្នេហ៍» ច្រៀងដោយ ស៊ុន ស្រីពេជ្រ គឺមានគោលគំនិតតែមួយ ប៉ុន្តែប្តូរតួអង្គវិញ*

ម្តង។ តួអង្គស្ត្រីគឺតំណាងឲ្យអតីតយោធាខ្មែរក្រហមចំណែកឯប្រទេសកម្ពុជាគឺជាតួអង្គបុរស។ ស្ត្រីម្នាក់ដែលតំណាងឲ្យអតីតយោធាខ្មែរក្រហម មានអារម្មណ៍ថាព្រហ្មលិខិតបានកំណត់ឲ្យខ្លួនជួបបុរសម្នាក់ដែលជាអ្នកទីក្រុង ហើយនាងគឺជាអ្នករស់ក្នុងព្រៃនៅស្រុកអន្លង់វែង។ អ្នកទាំងពីរបានជួបគ្នានៅលើភ្នំដងរែក ដោយសារទេវតា បានចារទុកមក។ បទចម្រៀងទីពីរនេះបានផ្លាស់ប្តូរវេនជានិមិត្តរូប។ បុរស គឺជាឥន្ទធនូដែលនារីរូបនោះ បានស្ងើចសរសើរនិងគយគន់មិនចេះនឿយណាយ។ ប៉ុន្តែឥន្ទធនូក៏បានរលាយបាត់រូបទៅវិញបន្ទាប់ពីរដូវវស្សាបានបញ្ចប់ ដោយទុកឲ្យ នារីរូបនោះរស់នៅកំព្រាឯកោតែម្នាក់ឯង។ បទចម្រៀងនេះ គឺជាន័យធៀបទៅនឹងការតស៊ូរបស់ស្រុកអន្លង់វែងដើម្បីផ្សះផ្សាជាមួយប្រទេសជាតិ។ តំបន់អន្លង់វែងមានភក្តីភាពចង់រួមរស់នៅជាមួយប្រទេសជាតិដូចគ្នាទៅនឹងនារី ដែលប្រាថ្នាចង់រស់នៅជាមួយបុរសដែលជាឥន្ទធនូនោះដែរ។ ប៉ុន្តែឥន្ទធនូបានរសាត់ទៅតាមទឹកភ្លៀងហើយនារី នោះត្រូវបានបង្ខំចិត្តបោះបង់ចោលនិងតស៊ូជម្នះរស់នៅដោយខ្លួនឯងវិញ។

តំបន់អន្លង់វែងត្រូវបាន លើកទឹកចិត្តឲ្យបន្តដំណើរទៅមុខទៀត។នៅពេល ដែលកត្តាសេដ្ឋកិច្ចបានបង្វែរការចាប់អារម្មណ៍ របស់រាជរដ្ឋាភិបាលឲ្យឃ្លាតចាកឆ្ងាយពីស្រុកអន្លង់វែងតំបន់នេះ បានបាត់បង់អត្តសញ្ញាណ របស់ខ្លួន។ មនុស្សជំនាន់ក្រោយជាពិសេសយុវវ័យ ដែលបានកើតនៅក្នុងស្រុកអន្លង់វែងមិនយល់អំពីសារសំខាន់ផ្នែកប្រវត្តិសាស្ត្ររបស់ស្រុកអន្លង់វែងឬតំបន់ផ្សេងទៀត ហើយមានការភ័ន្តច្រឡំនៅពេល ដែលខ្លួនបានស្តាប់ឮការពិភាក្សាអំពីរបបខ្មែរក្រហម។

ប្រទេសកម្ពុជាបានបោះជំហានចាកចេញ ពីប្រវត្តិសាស្ត្រខ្មែរក្រហម។ ការប្តេជ្ញាចិត្តនិងការយកចិត្តទុកដាក់ចំពោះតំបន់ខ្មែរក្រហមជាច្រើនបានរសាត់ និងសាបរលាបទៅបន្តិចម្តងៗដោយសារតែមានការផ្លាស់ប្តូរ ការយកចិត្តទុកដាក់របស់ប្រទេសជាតិដែរ។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជាព្យាយាមនាំយក ប្រវត្តិសាស្ត្រជូនសាធារណជនតាមរយៈ ការអប់រំ សិល្បៈ ចម្រៀង និងវប្បធម៌។ បេសកកម្មរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងគឺដើម្បីផ្សារភ្ជាប់សហគមន៍ ដែលមិនត្រឹមតែសម្រាប់ការយល់ដឹងអំពីប្រវត្តិសាស្ត្រ តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើម្បីបង្កើតគំនិតថ្មីៗ និងល្អៗសម្រាប់បុគ្គលម្នាក់ៗសហគមន៍ និងអត្តសញ្ញាណជាតិទៀតផង។



**២) តើបទចម្រៀងទីពីរ « គ្មានឥន្ទធនូស្នេហ៍ » មានអត្ថន័យដូចម្តេច?**

ដូចបទចម្រៀង«អន្លង់វែងស្នេហា»ដែរ គោលបំណងនៃការផលិតបទចម្រៀង«គ្មានឥន្ទធនូស្នេហ៍»នេះគឺដើម្បីចូលទៅក្នុងទឹកចិត្ត និងព្រលឹងរបស់ប្រជាជននៅក្នុងស្រុកអន្លង់វែង។ បទចម្រៀងនេះគឺជាសារមួយ សម្រាប់អធិប្បាយអំពីការតស៊ូជម្នះរបស់ប្រទេសកម្ពុជា ជាមួយនឹងប្រវត្តិសាស្ត្ររបស់ខ្លួនឯង តាមរយៈសាច់រឿងរបស់បុរសម្នាក់ និងស្ត្រីម្នាក់។ បទចម្រៀងនេះគឺជាសាច់រឿងដែលបង្ហាញអំពីថាតើ




ប្រទេសកម្ពុជា នៅតែបន្តស្វែងរកចម្លើយទៅនឹងអតីតកាលដ៏សែនត្រដាបត្រដួសរបស់ខ្លួនយ៉ាងដូចម្តេច ហើយថាតើទស្សនៈ និងការប្តេជ្ញាចិត្តរវាងអតីតកាល និងអនាគតកាលដែលប្រកបទៅ ដោយភាពសម្បូណ៍បែបនិងខ្សត់ខ្សោយប្រពៃណីនិងទំនើបនិយមអាចផ្សះផ្សាបាន តាមរយៈការជាគ្នាឡើងវិញនិងការស្វែងយល់ អំពីប្រវត្តិសាស្ត្របានយ៉ាងដូចម្តេចទៅ។

បទចម្រៀងទាំងពីរនេះ គឺជាការបង្ហាញពី ក្តីស្រមើស្រមៃរបស់មនុស្សជាតិ ចំពោះអ្វីអាចកើតមានឡើងប្រសិនបើយើងមានការប្តេជ្ញាចិត្ត ដោយបើកចិត្តឲ្យទូលាយមានចិត្តល្អប្រពៃនិងតាំងចិត្តមោះមុត។បទចម្រៀងទីមួយគឺអន្លង់វែងស្នេហាបានរៀបរាប់ អំពីបុរសម្នាក់ ដែលតំណាងឲ្យអតីយោធាខ្មែរក្រហមដែលបានលង់ស្នេហ៍លើនារីដ៏ស្រស់ផូរផង់ដែលតំណាងឲ្យសង្គមកម្ពុជា ទំនើបនាពេលបច្ចុប្បន្ន។បុរសយោធាខ្មែរក្រហមបាន បោះបង់ចោលការតស៊ូរបស់ខ្លួន។ ផ្ទុយទៅវិញនារីក្នុងក្តីស្រមៃ របស់ខ្លួនមិនបានបង្ហាញការប្តេជ្ញាចិត្តចំពោះសេចក្តីស្នេហា ដ៏ផ្អែមល្ហែមមួយនោះឡើយ។ នាងត្រូវបានពន្ធក់ ដោយសង្គមសម័យទំនើបពោរពេញទៅដោយសំភារៈនិយម ហើយសោះអង្គើយ ចំពោះសេចក្តីស្នេហាដ៏បរិសុទ្ធនោះទៅវិញ។ ប្រសិនបើ អ្នកជំនួសតួអង្គយោធាខ្មែរក្រហមម្នាក់នេះទៅ ជាយោធាផ្តាច់ខ្លួនខ្មែរក្រហមហើយជំនួសតួអង្គស្ត្រី ដោយប្រទេសកម្ពុជា សម័យទំនើបពេលនោះអ្នកនឹងយល់អំពីនិមិត្តរូបនៃបទចម្រៀងនេះ ថាតើបទចម្រៀងនេះផ្តោតសំខាន់ទៅលើគោលគំនិតសំខាន់ៗ ជាច្រើនដែលទាក់ទងទៅនឹងប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង។

**៣) បទចម្រៀងទី១ «អន្លង់វែងស្នេហា»ភាគច្រើនដូចជាបទចម្រៀងស្នេហា និងពិពណ៌នាអំពីតំបន់អន្លង់វែងនិងទី**

**បញ្ហាការរបស់ តាម៉ុក នៅលើកំពូលភ្នំ។ ខ្ញុំឆ្ងល់ណាស់ថាតើលោកគិតថាបទចម្រៀងនេះ នឹងផ្សារភ្ជាប់ប្រជាជនកម្ពុជាទៅនឹងទៅទីកន្លែងនោះយ៉ាងដូចម្ដេច? ហើយថាតើអតីតយោធាខ្មែរក្រហម និងអតីតមេដឹកនាំខ្មែរក្រហម រស់នៅទីនោះអស់រយៈពេលជាច្រើនឆ្នាំយ៉ាងដូចម្ដេច? តើនរណាជាតួអង្គស្រ្តីនៅក្នុងបទចម្រៀងដែលអ្នកនិពន្ធបានសរសេរ?តើនរណាជាតួអង្គបុរសនៅក្នុងបទចម្រៀងនេះ ដែលអ្នកនិពន្ធចង់បង្ហាញ?**

ដូចដែលបានជម្រាបជូនខាងលើ តួអង្គស្រ្តីគឺជាសង្គមកម្ពុជាសម័យទំនើបនេះ ដែលប្រៀបដូចជាដុំពពកហើយកំពុងតែប្រឡោមលួងលោម និងទាក់ទាញ ដោយសារតែសម្រស់ដ៏ស្រស់ឆើតឆាយ និងសម្ភារនិយម ហើយកំពុងរសាត់អណ្ដែតបាត់ទៅវិញ ដោយសារតែដុំពពកនោះបានហោះហើរទៅតាមការប្រែប្រួលអាកាសធាតុនិងវាយោបោកបក់។

**៤) តើចម្រៀងទាំងពីរបទនេះ អាចព្យាបាលរបួសផ្លូវចិត្តពីអតីតកាលបានយ៉ាងដូចម្ដេច? ហេតុអ្វីបានជាចម្រៀងនេះអាចព្យាបាលរបួសផ្លូវចិត្តបាន?**

បទចម្រៀង គឺជាមធ្យោបាយមួយសម្រាប់ភ្ជាប់ទំនាក់ទំនងគ្នា រវាងទស្សនវិជ្ជា សីលធម៌ និងសោភ័ណភាព។ សម្រាប់មនុស្សជាតិ បទចម្រៀងអាចតំណាងឲ្យមនោសញ្ចេតនារបស់មនុស្សទាំងអស់ និងលក្ខខណ្ឌ ទាំងឡាយដែលបង្ហាញអំពីសេចក្ដីល្អ និងសេចក្ដីអាក្រក់ សន្តិភាពនិងភាពហិង្សាភាពរីកចម្រើន និងភាពក្រីក្រ ភាពរស់រានមានជីវិតនិងសេចក្ដីស្លាប់។ បទចម្រៀងទាំងពីរនេះ គឺសម្រាប់ប្រាប់ដល់ការតស៊ូរបស់ប្រទេសកម្ពុជា ក្នុងការស្វែងរកការផ្សះផ្សាដែលមិនត្រឹមតែសម្រាប់ខ្លួនឯង ប៉ុន្តែសម្រាប់អតីតកាលនិងអនាគតកាលទៀតផង។ បទចម្រៀងនេះក៏មានគោលបំណងដើម្បីអប់រំ អំពីការតស៊ូ នៅក្នុងប្រវត្តិសាស្រ្តរបស់ប្រទេសកម្ពុជា និងជម្រុញឲ្យប្រទេសកម្ពុជាព្យាយាមរិះរកវិធីសាស្រ្តផ្សេងៗ ដើម្បីជៀសវាង ការដើរតាមគន្លងចាស់នៃប្រវត្តិសាស្រ្តដ៏អាប់អួរនៅក្នុងអតីតកាលជាពិសេសសម្រាប់យុវជនជំនាន់ក្រោយ ឲ្យមានជីវិតរស់នៅបានល្អប្រសើរជាងនេះ។

**៤) តើបទចម្រៀងថ្មីទាំងពីរនេះ អាចចូលរួមចំណែកក្នុងការផ្សះផ្សានៅក្នុងប្រទេសកម្ពុជាបានយ៉ាងដូចម្ដេច?**

ដូចគ្នាទៅនឹងទម្រង់នៃសិល្បៈដទៃទៀតដែរ ចម្រៀងទាំងពីរបទនេះ អាចជ្រៀតចូលក្នុងដួងចិត្តរបស់ប្រជាជនកម្ពុជាទាំងអស់ក្នុងស្ថានភាព ដែលគ្មានសៀវភៅឬក៏ការបង្រៀនណាមួយអាចធ្វើទៅបានឡើយ។ បទចម្រៀងទាំងនេះជួយជម្រុញទឹកចិត្តនិងអប់រំអំពីអ្វី ដែលកើតមានឡើងនិងអ្វីដែលអាចធ្វើទៅបាន។

**៥) តើមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានបំពេញការងារយ៉ាងដូចម្ដេចខ្លះ?**

មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានផ្ដល់ការគាំទ្រនិងយល់ស្របជាមួយនឹងចក្ខុវិស័យ នៃការបង្កើតបទចម្រៀងទាំងពីរបទនេះ។មជ្ឈមណ្ឌលនេះបានប្រើប្រាស់ប្រវត្តិសាស្រ្តដើម្បីអប់រំយុវជន អំពីប្រវត្តិសាស្រ្ត របស់ប្រទេសកម្ពុជានិងតំបន់ដើម្បីធ្វើជាស្ពានក្នុងការកសាង ទំនាក់ទំនងរវាងបុគ្គលសហគមន៍ និងប្រទេសជាតិ។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបាននិងកំពុងសម្រេចគោលដៅ របស់ខ្លួនដោយចាប់ផ្ដើមពីសិស្សម្នាក់ គ្រូម្នាក់ និងសហគមន៍មួយ។

ដូចទស្សនវិទូជនជាតិក្រិកគឺ លោក ផ្លាតូ បាននិយាយថា៖«តន្ត្រីគឺជាច្បាប់សីលធម៌។ តន្ត្រីបានផ្ដល់ព្រលឹងទៅឲ្យចក្រវាឡ ស្លាបហោះហើរសម្រាប់ការគិតពិចារណា និងការស្រមើស្រមៃភាពទាក់ទាញនិងភាពសប្បាយ រីករាយដល់ជីវិតនិងអ្វីៗគ្រប់យ៉ាង»។ ខ្ញុំផ្ទាល់ជឿជាក់ថា តន្ត្រីក៏ដូចជាប្រព័ន្ធផ្សព្វផ្សាយ និងទម្រង់សិល្បៈដទៃទៀតដែរ ពិតជាមានសារសំខាន់ចំពោះប្រវត្តិសាស្រ្ត និងអនាគតរបស់ប្រទេស។ យើងត្រូវតែប្រើរាល់ទម្រង់ផ្សព្វផ្សាយ និងវប្បធម៌ដែលយើងមាន ដើម្បីទទួលបាននូវសក្ដានុពលរបស់ បុគ្គលម្នាក់ៗ សហគមន៍និងប្រទេសជាតិ។ **ឆាំង យុ**

# កាលវិភាគបញ្ចាំងខ្សែភាពយន្តឯកសារ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា







បញ្ចាំងរៀងរាល់ថ្ងៃសុក្រ
វេលាម៉ោង១០:០០ ព្រឹក
ទីតាំងនៅវិចិត្រសាលសិល្បៈ
សហសម័យវិទ្យាស្ថានស្លឹករឹត
វីឡាលេខ១០, ផ្លូវ២៥៦ ភូមិ៣
សង្កាត់ចតុមុខ ខណ្ឌដូនពេញ
រាជធានី ភ្នំពេញ










វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត ដែលមានទីតាំងស្ថិតនៅវីឡាលេខ១០, ផ្លូវ២៥៦, ភ្នំពេញ ជាទីតាំងមួយដើរតួនាទីជាកន្លែងអប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រ និងកេរដំណែលបន្សល់ទុកពីរបបខ្មែរក្រហម ព្រមទាំងជាកន្លែងដែលដាក់បង្ហាញពីស្នាដៃសិល្បៈ និងវប្បធម៌តាមរយៈការតាំងពិព័រណ៍ ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ និងការធ្វើបទបង្ហាញរបស់វាគ្មិននានា។ ជារួម វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត រួមចំណែកដល់ការលើកកម្ពស់និងគាំទ្រដល់វិចិត្រករកម្ពុជាទាំងអស់ ដោយផ្តល់ជូននូវបរិវេណខាងក្នុងបន្ទប់ធំសម្រាប់ការដាក់តាំងពិព័រណ៍ពីកិច្ចការសិល្បៈរបស់ខ្លួន។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង ស៊ាន ចិន្តា ទូរសព្ទលេខ ០២៣ ២១១ ៨៧៥ អ៊ីម៉ែល truthchenda.s@dccam.org

# មើក ស្ងួន សមាជិកវរសេនាតូច២៣៣ វរសេនាធំ២៣ កងពល២៩០តំបន់២១ ភូមិភាគបូព៌ា

នៅក្នុងចម្លើយសារភាព ដែលមានកម្រាស់ ៦៧ ទំព័រ មើក ស្ងួន ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី១២ខែកក្កដា ឆ្នាំ១៩៧៧ ។ស្ងួនត្រូវបានបញ្ជូនមកកាន់ គុកទួលស្លែង និងរងការសួរចម្លើយចំនួនពីរលើក។លើកទីមួយនៅ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៧ និងលើកទីពីរ នៅថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៧៧ ដោយមានអ្នកសួរចម្លើយឈ្មោះស្រ៊ឹម,សេង និង ផុង។ ខាងក្រោមនេះជាចម្លើយសារភាពរបស់មើក ស្ងួន ៖

ខ្ញុំឈ្មោះ មើក ស្ងួន ភេទប្រុស អាយុ៣១ឆ្នាំ (នៅឆ្នាំ១៩៧៧)។ខ្ញុំមានស្រុកកំណើត នៅភូមិវាលម្លូ ស្រុកពញាក្រែក (តំបន់២១ខេត្តកំពង់ចាម។ នៅអាយុ១៣ឆ្នាំ ខ្ញុំបានចូលរៀននៅសាលាវត្តវាលម្លូ។ ក្រោយមកនៅពេលខ្ញុំរៀនដល់ថ្នាក់ទី១០ខ្ញុំ បានឈប់រៀន។ ខ្ញុំ បានមករស់នៅជាមួយឪពុកម្តាយ និងជួយឃ្វាលគោរហូតដល់ ខ្ញុំមានអាយុ១៦ឆ្នាំ។នៅក្នុងឆ្នាំ១៩៦២ខ្ញុំបានមករស់នៅជាមួយបងស្រីស្ថិតនៅភូមិជាំត្រគួន



យោធាខ្មែរក្រហមនៅសមរភូមិ

ឃុំជាំខ្ញុំ(បច្ចុប្បន្ន ឃុំទឹកជ្រៅ ស្រុកទឹកជ្រៅ(បច្ចុប្បន្នស្រុកតំបែ)ដោយជួយធ្វើស្រែចម្ការគាត់។ ពេលខ្ញុំធ្វើស្រែនៅទីនោះក៏បានស្គាល់ឈ្មោះឈន គឺជាមេឃុំ។ ឈន ជាអ្នកដើរទារប្រាក់ពន្ធពីប្រជាជននៅក្នុងភូមិ។ ក្រោយមក ឈន បានហៅខ្ញុំទៅរស់នៅជាមួយគាត់ប៉ុន្តែ ខ្ញុំបានបដិសេធ។ ឈន ក៏បានឲ្យលុយ ខ្ញុំចាយក្នុងគោលបំណងអូសទាញខ្ញុំ។

នៅក្នុងឆ្នាំ១៩៦៣ មេឃុំឈនបានអប់រំខ្ញុំនិងចាត់តាំងខ្ញុំធ្វើជាគិញហើយគាត់ បានឲ្យប្រាក់ខែខ្ញុំចំនួន១៥០០រៀលក្នុង១ខែ។ ពេលនោះ ខ្មែរដែលបាន ចាត់តាំងជាមួយខ្ញុំមានឈ្មោះម៉មលីស្រ៊ាង គឺជាអតីតជាងឈើ(បច្ចុប្បន្នគឺជាលេខាវរសេនាតូចដឹកជញ្ជូនរបស់កងពល២៩០)។ ឈ្មោះ មាសមុំ អតីតប្រធានចម្ការកៅស៊ូក្រែក (បច្ចុប្បន្នលេខាវរសេនាតូច២២១វរសេនាធំ២២ កងពល២៩០)។ ឈ្មោះជាជួនអតីតជាងអាឈើ(បច្ចុប្បន្នសមាជិកវរសេនាតូច របស់តំបន់២១)។សកម្មភាពរបស់ម៉មលីស្រាង, មាសមុំ, ជាជួននិងខ្ញុំគឺស៊ើបរកមើលខ្មែរក្រហមនៅក្នុងភូមិវាលម្លូ ដោយក្លែងធ្វើ ជាអ្នកទិញជ្រូក និងមាន់។ ពេលយកការណ៍បាន ឈន ក៏បាននាំទាហានពីបន្ទាយក្រែកមកវាយឆ្មក់នៅភូមិទឹកជ្រៅ, ភូមិស្រែ-វែងនិង ភូមិស្រឡៅច្រើន (ឃុំវាលម្លូ)។ នៅក្នុងឆ្នាំ១៩៦៥មេឃុំឈនបានហៅខ្ញុំទៅប្រជុំនៅផ្ទះ ប៉ាន់ សាន ដែលមានអ្នកចូលរួមប្រជុំមានឈ្មោះសាន់ ខឿន (សមាជិកកងពល២៩០), ជាជួន,ភីគន់(លេខាវរសេនាតូច២២៤ វរសេនាធំ២២ កងពល២៩០), សុខសាមឿន(សមាជិកកងវរសេនាកងធំភូមិភាគបូព៌ា) និងម៉មលីស្រ៊ាង។ ការប្រជុំនេះមានផែនការៈ បញ្ជាក់ពីសភាពការណ៍ខ្មែរក្រហម ដែលធ្វើសកម្មភាពនៅស្រុកដំបែ, ស៊ើបការណ៍រកក្រុមខ្មែរក្រហមដែលចូលក្នុងភូមិ

និងប្រជាជនទាំងឡាយណា ដែលបានជួយឧបត្ថម្ភដល់ខ្មែរក្រហមៗមេឃុំឈន ក៏ចាត់តាំងឲ្យឈ្មោះ ភឹម គន់,សុកសារឿននិងប៉ាន់សាន(ភ័ស្តុភារកងពល២៩០) ត្រូវរាយការណ៍ឲ្យឈ្មោះសាន់ខឿននៅពេលណា ទទួលបានព័ត៌មានៗ

ចំណែកខ្ញុំ, ជា ដួន, សុខ សាមឿន និង ម៉ម លីស្រ៊ាង បានរាយការណ៍ឲ្យមេឃុំឈនដោយផ្ទាល់តែម្តងៗ

នៅក្នុងឆ្នាំ១៩៦៧ ខ្ញុំនិងបក្ខពួកទាំងអស់មកប្រជុំនៅផ្ទះតាចន្ទូម ហៅ តាស (បច្ចុប្បន្នលេខាស្រុកកញ្ជៀច) ដែលមានអ្នកចូលរួមឈ្មោះទ្រី(លេខាវរសេនាធំ២៣ កងពលលេខ២៩០),រស់សារឿន(សមាជិកកងពល២៩០), ម៉ែន ម៉េង (អនុវរសេនាតូច២៣៣វរសេនាធំ២៩០),ភិន(លេខាកងពលតូច២៣៣កងពលធំ២៩០),សំបុក(លេខាស្រុកពារាំងតំបន់២២),ហង់បូរ(លេខាវរសេនាតូច២៣១ កងពល២៩០)ៗ អ្នកចូលរួមត្រូវបាន ធ្វើការណែនាំឲ្យស្គាល់ ព្រះតេជគុណ គង់ ឈុំ, មាស ម៉ុម,ប៉ាន់ សាន, ជា ដួន, ម៉ម លី ស្រ៊ាង,ភី គន់,សុក សារឿន, មេឃុំ ឈន,សាន់ យឿន និង ញ៉ែមម៉ុនៗ ក្រោយមកតាចន្ទូមក៏ប្រកាសរៀបចំខ្សែនីរសារសម្រាប់ទាក់ទងៗ

នៅក្នុង ឆ្នាំ១៩៦៨ ខ្ញុំបានទៅប្រជុំជាមួយឈ្មោះ រស់ សារឿន, តាចន្ទូម, ទ្រី, ទូច សារឿម, ហង់ បូរ, ម៉ែន ម៉េង, ញ៉ែមម៉ុន,គង់ឈុំ,ជាដួន,ភិគន់,សុកសារឿន,សាន់ ខឿន,ប៉ាន់សាន,មាសម៉ុម, ម៉មលីស្រ៊ាង និងមេឃុំឈនៗ ការប្រជុំនេះប្រព្រឹត្តទៅនៅផ្ទះសា រឿន ស្ថិតនៅភូមិដូនដីស្រុកកញ្ជៀច ដោយលើកឡើងអំពីសកម្មភាពពង្រីកកម្លាំង និងសកម្មភាពកម្ទេចបដិវត្តន៍ៗ អ្នកចូលរួមមាន ឈ្មោះ សារឿន, តា ចន្ទូម (ប្រធាន) និងមានអ្នកទទួលបន្ទាប់មាន ឈ្មោះ សាន់ ខឿន, សំបុក និងមេឃុំឈនៗ

នៅក្នុងឆ្នាំ១៩៧០ ពេលដែលកើតមានរដ្ឋប្រហារខ្សែដែលបង្កប់នៅក្នុងតំបន់២១ បានមកជួបជុំគ្នា មានឈ្មោះ សាន់ ខឿន(ប្រធានកងធំតំបន់)ឈ្មោះកែវម៉ុន(សមាជិកតំបន់តាចន្ទូមជាលេខាស្រុកពញាក្រែក គង់ ឈុំ សមាជិកស្រុកមេមត់ម៉ៃដូ(លេខាស្រុកមេម៉ត់), ទ្រី(កងធំយោធាតំបន់២១) មេឃុំឈន(លេខាឃុំវាលម្លូ),សំបុក(លេខាស្រុកពារាំងតំបន់២២)ៗចំណែកអ្នកក្តោបក្តាប់ឈ្មោះសាន់ខឿន,កែវម៉ុនដោយរកគ្រប់វិធីកម្ទេចកម្លាំងបដិវត្តន៍ក្នុងសមរភូមិ និងបង្កទំនាស់ជាមួយប្រជាជនៗនៅក្នុង ខែកក្កដា ឆ្នាំ១៩៧០ អង្គការ បានរៀបចំយោធាក្នុងវរសេនាតូចតំបន់២១ៗ កែវ ម៉ុន បានចាត់តាំងបក្ខពួកឲ្យចូលគ្រប់គ្រង ក្នុងវរសេនាតូចលេខ១ ដោយមានឈ្មោះសាន់ខឿន(ជាលេខាវរសេនាតូច)ៗ ភិ គន់(អនុយោធាកងធំទី១),ប៉ាន់សាន(ប្រធានយោធាកងធំទី២)ៗ សុខ សារឿន(ប្រធាននយោបាយកងធំទី៣)ៗមាសម៉ម(នយោបាយ), ស្ងួនអនុប្រធាន,ម៉ម លីស្រ៊ាងសមាជិកក្នុងកងធំទី៥ៗនៅក្នុងឆ្នាំ១៩៧១ខ្ញុំមានបក្ខពួកមានឈ្មោះ មាស ម៉ុន, ជា ដួន, តូច សាមឿន,ញ៉ែមម៉ុន និងភីគន់ៗ នៅពេលដែលខ្មាំង វាយចូលមកខ្មាំងខ្ញុំបានបើកផ្លូវឲ្យ ខ្មាំងចូលមកវាតត្បាតប្រជាជនក្នុងភូមិកំពង់ឫស្សី, ភូមិបឹងកំបោរ,ភូមិបឹងព្រួលដោយនាំគ្នាដកកម្លាំងរត់ចោលយុទ្ធជនទុកឱកាស ឲ្យខ្មាំងកម្ទេចកម្លាំងអស់មួយចំនួនៗ នៅក្នុងខែធ្នូ ឆ្នាំ១៩៧២ អង្គការបានបញ្ជូនអង្គភាពរបស់ខ្ញុំមកនៅអង្គភាពរបស់ភូមិភាគបូព៌ាៗ មុនពេលបញ្ជូនឲ្យមកនៅកងពលរបស់ភូមិភាគកែវម៉ុនសាន់ខឿនបានរៀបបក្ខពួកនៅក្នុង កងវរសេនាតូចលេខ១៩ មានឈ្មោះភីគន់ឲ្យទទួលអនុនយោបាយ,ម៉មលីស្រ៊ាងសមាជិកក្រៅពីនេះទទួលកងធំមានឈ្មោះប៉ាន់សាន, មាសម៉ុន, ស្ងួន, ញ៉ែមម៉ុនចំណែក សាន់ ខឿន ទទួលរួមនាំវរសេនាតូចមកភូមិភាគៗកែវម៉ុន ឡើងមកទទួលសមាជិកគណយោធា ភូមិភាគបូព៌ាៗ ចំណែកជា ដួន សុកសារឿន ទទួលជាកងធំកងតំបន់២១វិញៗ

នៅក្នុងឆ្នាំ១៩៧៣ ខ្ញុំ និងបក្ខពួកបានមកនៅក្នុងអង្គភាពភូមិភាគបូព៌ា កាលនោះ សាន់ ខឿន ទទួលជាសមាជិកវរសេនាធំលេខ១៩២ៗនៅក្នុងខែឧសភា កែវ ម៉ុន មានផែនការដកខ្ញុំទៅទទួលជាលេខាកងកាំភ្លើងធំ របស់វរសេនាធំ១៩២ឲ្យញ៉ែមម៉ុនឡើងជំនួសខ្ញុំវិញហើយឈ្មោះតូចសាខឿនជាប្រធានយោធាៗនៅក្នុង ខែកក្កដា ឆ្នាំ១៩៧៣ សាន់ ខឿន

បានដកម៉មលីស្រ៊ានពីវរៈសេនាតូច១៩ ទៅកាន់ភ័ស្តុភារវរសេនាធំ១៩២។កាលនោះខ្វះកម្លាំងដឹក ជញ្ជូនខឿនក៏ទៅសុំកម្លាំងពីឈ្មោះ សំបុក ជាបក្ខពួកនៅក្នុង ស្រុកពារាំង។សំបុកក៏ឲ្យឈ្មោះហង់សំបូរ គឺជាខ្មែរចាស់យុទ្ធជនកងតូចមកខឿន។ខឿនបានឲ្យហង់ សំបូរ នៅជាមួយ ម៉ម លីស្រ៊ានដើម្បីចូលបំផ្លាញបដិវត្តន៍។ នៅក្នុងឆ្នាំ១៩៧៤ វរសេនាធំ១៩២, វរសេនាធំ១២៨, វរសេនាធំ៤៧ រួមគ្នារៀបចំជាកងពលទី២របស់ភូមិភាគបូព៌ា ដោយមាន កែវ ម៉ុន ជាលេខា។នៅពេលដែលកងពលនេះចុះទៅវាយនៅសមរភូមិព្រៃវែងស្វាយរៀង ខ្ញុំ និងបក្ខពួកទាំងអស់ បានជួបជុំខ្មែរចាស់របស់គេពីមុនដែរ។ នៅក្នុងខែសីហា ឆ្នាំ១៩៧៤ អង្គការបានលើកផែនការវាយរំដោះក្រុងស្វាយរៀង ក្នុងរយៈពេល៣ខែឲ្យបានទទួលជោគជ័យដោយបានចាត់តាំងវរសេនាធំ របស់ឈ្មោះ សារឿន, វរសេនាធំរបស់ខឿន។នៅក្នុងខ្ទឹមសារនោះគ្រាន់តែវាយរំខានដើម្បីឲ្យខ្មាំង កម្ទេចកម្លាំងបដិវត្តន៍ ហើយបានធ្វើការខុទ្ទេសនាមខ្មែរនៅមូលដ្ឋានមានឈ្មោះ ឈូក លេខាតំបន់២៤, សាមិតលេខាស្រុកមានជ័យថ្មីតំបន់២៣, យន អនុលេខាស្រុកចន្ទ្រាតំបន់២៣(ត្រូវជាបងថ្លៃរបស់សាន់ខឿន)។ នៅក្នុងឆ្នាំ១៩៧៥កងរបស់ខ្ញុំមកប្រចាំការ នៅសមរភូមិទន្លេមេគង្គក្រោម។ ពេលនោះខ្ញុំ,សុកសាមឿន,ញ៉ែមម៉ុន,ឌុចសុផល,ភីគន់,ប៉ាន់សាន ដែលទទួលផែនការពីសាន់ខឿន ទប់ទល់ការវាយចូលទីក្រុងភ្នំពេញដោយបើកដៃ ឲ្យកប៉ាល់ចូលទីក្រុងភ្នំពេញបាន ដោយមិនបានបាញ់ ថែមទាំង បំផ្លាញគ្រាប់កាណុងធំៗទៀត។

នៅក្នុងឆ្នាំ១៩៧៦ នៅខែដាំពោត និងដីកប្រឡាយ ខ្ញុំ, ភី គន់ បានដាក់ផែនការឲ្យខ្មែរ នៅខាងក្រោមបំផ្លាញពោត ដោយដាក់គ្រាប់ពោតពី១០ទៅ ២០គ្រាប់ បាចតាមគន្លងនង្គ័លធ្វើឲ្យគ្រាប់ពោតអណ្តែតក្រហមពេញដីប្រមាណជា២០ហិចតាដែលអស់ពូជជាង១តោន។នៅក្នុងរដូវធ្វើស្រែប្រាំង ខ្ញុំ,ញ៉ែមមុន,មាសម៉ុន,ឌុកសុផល និង ភី គន់ ក្រោមការក្តាប់របស់សាន់ខឿនបានបន្តការបំផ្លាញបដិវត្តន៍ ដោយមិនឲ្យលើកភ្លឺ,ស្ទូងស្រូវស្រាល លាយស្រូវធ្ងន់, ស្ទូងក្នុងស្រែមានស្មៅ, ស្ទូងក្នុងទឹកជ្រៅ និងដីគោកគ្មានទឹក។ នៅក្នុងខែសីហាឆ្នាំ១៩៧៦ខ្ញុំនិងបក្ខពួកមានឈ្មោះ ឌុក សុផល, ភី គន់, មាស ម៉ុម, ញ៉ែម ម៉ុន, ប៉ែន ពិន, ធារី, នួន សារឿន, ឌី, ស្រេង, ទ្រី, ផែន, សាវុធ, ភិន, ខេន, ម៉ែន ម៉េង, ប៉ាន់ សាន, ម៉េង លី ស្រ៊ាង និង ហង់ បូរ មកទទួលផែនការពី យិន, សារឿន និង សាន់ ខឿន។បងៗបានត្រៀមលក្ខណៈធ្វើរដ្ឋប្រហារផ្តួលរំលំបក្សនៅចុងខែកញ្ញា ឆ្នាំ១៩៧៦ហើយប្រសិនមិនសម្រេចត្រូវលើកទៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៧។ នៅក្នុងឆ្នាំ១៩៧៧ប្រសិនបើអង្គការចាប់បក្ខពួករបស់ខ្ញុំ យើងនឹងរត់ទៅប្រទេសយួន។នៅក្នុងខែកុម្ភៈនៅពេលដែល អង្គការដកកម្មាភិបាលពីវរសេនាធំ២២ ទៅក្តាប់នៅវរសេនាធំ២៣ ស្របពេលនោះសារឿនសមាជិកកងពលក៏បានឲ្យឌុកសុផលសម្រេចដកខ្ញុំ,ញ៉ែមម៉ុន,ទៅក្តាប់វរសេនាតូចលេខ២៣៣នៃវរសេនាធំ២៣ ព្រោះកម្លាំងនៅកន្លែងនោះតិច។ នៅខែមិថុនា សារឿន,ទ្រី,ឌុកសុផលបានមានផែនការដឹកពោតនិងអង្ករយកទៅលាក់នៅក្នុងស្រុកចន្ទ្រា ដោយឲ្យ យន លាក់ពោត៥០បាវអង្ករ៤០បាវដើម្បីត្រៀមវាយបដិវត្តន៍ លើកក្រោយ។ នៅខែកក្កដាសារឿនបានហៅបក្ខពួកទៅប្រជុំនៅវត្តស្ទឹងស្លូតបក្ខពួកដែលប្រជុំមានឈ្មោះឌុកសុផល,មាស ម៉ុន, ភី គន់, សា មិន,ផេន,សាវុធ,ភិន,ម៉េង,ហង់ បូ, ប៉ាន់ សាន, ម៉ម លីស្រ៊ាង និងខ្ញុំ។ កិច្ចប្រជុំបានផ្តោតទីលើការពង្រឹកកម្លាំងសេ.អ៊ី.អាថ្មីនិងចាស់ហើយបន្តផែនការបំផ្លាញបដិវត្តន៍ ប្រឆាំងបដិវត្តន៍បន្តទៀត។រហូតមកដល់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៧៧អង្គការបានចាប់ខ្លួនខ្ញុំតែម្តង។

**កំណត់ចំណាំ** ៖ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១សុទ្ធតែ ឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរ ចម្លើយរបស់ខ្មែរក្រហមដូច្នេះយើងមិនអាចសន្និដ្ឋាន បានថាចម្លើយរបស់ មើក ស្វូន ពិតប្រាកដយ៉ាងណានោះទេ។

**ដារ៉ារដ្ឋ មេត្តា**

# ថោង ឈឺន ប្រធានសន្តិសុខស្រុកកោះង៍យ តំបន់២៨ ភូមិភាគបូព៌ា

ឈ្មោះ ថោងឈឺន ភេទប្រុស អាយុ៩១ឆ្នាំមានកន្លែងកំណើតនៅភូមិស្នាយព្រីម ឃុំពញាលឿង ស្រុកត្របែក (បច្ចុប្បន្នស្រុកព្រះស្តេច)ខេត្តព្រៃវែង។ ខ្ញុំមានតួនាទីជាប្រធានសន្តិសុខស្រុកកោះង៍យតំបន់២៨។ ខ្ញុំធ្លាប់បាន បួសជាព្រះសង្ឃអស់រយៈពេល៣ព្រះវស្សា នៅវត្តទួលស្តើង ស្ថិតនៅក្នុងភូមិស្នាយព្រីម។ ក្រោយមកខ្ញុំក៏បានលាចាកសិក្ខាបទវិញ ដើម្បីមកជួយធ្វើស្រែឪពុកម្តាយ។

នៅក្នុងឆ្នាំ១៩៤៩ រហូតដល់ឆ្នាំ១៩៥២ ខ្ញុំបានចូលរួមតស៊ូចលនាជាមួយខ្មែរឥស្សរៈដើម្បីវាយបារាំង។ក្រោយមកខ្ញុំបានឈប់ចូលរួមជាមួយខ្មែរឥស្សរៈ និងបានវិលត្រឡប់មកជួយធ្វើស្រែប្រពន្ធវិញ។ នៅក្នុងឆ្នាំ១៩៥៦ ឈ្មោះ សំ ភួង (មេឃុំពញាលឿង) បានចាត់តាំងឲ្យខ្ញុំធ្វើជាគិញឲ្យគាត់ ដោយធ្វើការតាមដានក្រុម ខ្មែរឥស្សរៈចាស់ៗ។ ក្នុងនោះខ្ញុំត្រូវទទួលភារកិច្ចតាមដានក្រុមឥស្សរៈហើយប្រសិនបើមានការបះបោររបស់ក្រុមឬក្រុមនេះ មានសកម្មភាពប្រឆាំងជាមួយរាជការត្រូវរាយការណ៍ទៅឈ្មោះភួងឲ្យបានដឹង។ខ្ញុំបានយល់ព្រមតាមសំណើរបស់ភួង ព្រោះប្រសិនបើខ្ញុំមិនយល់ព្រមតាមសុំណើរបស់គាត់ទេ គាត់នឹងរាយការណ៍ប្រាប់រាជការឲ្យចាប់ខ្ញុំដាក់គុកមិនខាន។ នៅក្នុងឆ្នាំ១៩៦៧ ឈ្មោះទកស៊ិន(កសិករភូមិព្រីង)ដែលជាអ្នកជិតខាងខ្ញុំបាននាំឈ្មោះឈូក (ភ្លាប់មិនបាន) មកផ្ទះខ្ញុំ។ ឈូក ក៏បានធ្វើការអប់រំខ្ញុំឲ្យស្រឡាញ់បដិវត្តន៍ និងធ្វើបដិវត្តន៍នៅក្នុងភូមិស្នាយព្រីម។

នៅក្នុងឆ្នាំ១៩៦៨ ឈូក បាននាំឈ្មោះ ទិត ដោត (លេខាឃុំពញាលឿងថ្មី ក្រោយមកស្លាប់ដោយសារជំងឺនៅក្នុងឆ្នាំ១៩៦៨) និងឈ្មោះទិតឈុំ (កូនទិតដោត) មកផ្ទះខ្ញុំទៀត។ឈូកបានធ្វើការអប់រំខ្ញុំ, ទិត ដោត និង ទិត ឈុំ។ នៅ



កងទ័ពខ្មែរក្រហមដែលបានផ្តាច់ខ្លួនចេញពីកម្ពុជាប្រជាធិបតេយ្យ ដើម្បីទៅចុះចូលជាមួយកងទ័ពវៀតណាមនៅតាមព្រំដែនកម្ពុជា - វៀតណាម ក្នុងឆ្នាំ១៩៧៨

ក្នុងខ្ទឹមសារនោះរៀបរាប់ពីការធ្វើបដិវត្តន៍ មិនមានប្រាក់ខែ, លំបាក គ្មានបានផលប្រយោជន៍អ្វីសម្រាប់ខ្លួនឯងៗ ចំណែកការធ្វើជាខ្មែរសេរីមានប្រាក់ខែ, មានបុណ្យស័ក្តិ, មិនលំបាក និងបានផលប្រយោជន៍ច្រើនដល់ខ្លួនៗ យើងទាំង៣នាក់បានយល់ស្របតាមឈូកព្រោះបានប្រាក់ខែផងៗ ឈូកក៏បានណែនាំឲ្យអនុវត្តភារកិច្ចធ្វើយ៉ាងណាមិនឲ្យយុវជនធ្វើបដិវត្តន៍ និងឃោសនាប្រជាជនមិនឲ្យជឿលើបដិវត្តន៍ៗ

ក្រោយពីចប់ប្រជុំឈូកបានខ្ញុំនិងអ្នកដែលបានចូលរួមប្រជុំទៅទាក់ទងឈ្មោះ ឈឹម (នៅក្នុងឆ្នាំ១៩៧០ ធ្វើការនៅសេដ្ឋកិច្ចតំបន់២៨)ៗក្រោយមក ឈឹម បានហៅខ្ញុំទៅប្រជុំនៅផ្ទះរបស់ឈ្មោះ ទេព អ៊ុច (អតីតឥស្សរៈ នៅក្នុងភូមិធ្នង់ ឃុំពញាលៀង បច្ចុប្បន្នស្ថិតនៅក្នុងឃុំស្តៅកោង)ៗអ្នកដែលចូលរួមប្រជុំមានៈឈ្មោះឈឹម,ទេពអ៊ុច,សុខប៉ូ(អតីតឥស្សរៈ),ហោប៊ុន(អតីតមេភូមិធ្នង់),ស៊ាប(សមាជិកឃុំពញា លៀង) និងខ្ញុំៗ នៅក្នុងឆ្នាំ១៩៦៩ ខ្ញុំបានចាត់តាំងកម្លាំងបាន២នាក់ឲ្យជួយធ្វើការឃោសនាអប់រំប្រជាជន យុវជនមិនឲ្យជឿលើការឃោសនាពីបដិវត្តន៍ៗ ក្នុងនោះមានឈ្មោះ ថោង ឆន (ជាប្អូនប្រុសរបស់ខ្ញុំ) និងឈ្មោះ អ៊ួង យឹន (ជាក្មួយជីទួតមួយរបស់ខ្ញុំ)ៗនៅឆ្នាំ១៩៧០ខ្ញុំបានអប់រំ បានឈ្មោះ ហោ ទ្រី (នៅឆ្នាំ១៩៧៣ ហោ ទ្រី បានក្លាយជាគណៈកម្មាធិការភូមិស្នាយព្រីមៗ ហោ ទ្រី ជាមនុស្សខិលណាស់ខាងលួចស៊ីផឹក និងលេងល្បែង)ៗ ខ្ញុំ, ថោង ឆន និង អ៊ួង យឹន បានបំផុសប្រជាជនមិនឲ្យចូលធ្វើបដិវត្តន៍ៗ នៅក្នុងខែមីនា និង មេសា ឆ្នាំ១៩៧១ ខ្ញុំចាំមិនច្បាស់ ឈូក បានហៅខ្ញុំទៅជួបនៅភូមិក្រសាំងទងឃុំពញាលៀង (ខ) ដោយ ឈូក បានឲ្យខ្ញុំរាយការណ៍ពីកម្លាំងដែលកសាងបានៗ

នៅឆ្នាំ១៩៧១ ដដែល ឈឹម បានចុះមកជួបខ្ញុំនៅភូមិធ្នង់ឃុំពញាលៀង (ក) ដែលក្នុងដែលក្នុងពេលជួបនោះបានខទ្វេសនាមមនុស្ស៨នាក់ទៀតមានៈ ឈ្មោះសឹង គង់ (អតីតមេភូមិស្ពានជ័យឃុំពញាលៀង),ញ៉ឹក មឿន (កសិករភូមិ



យុទ្ធនារីខ្មែរក្រហមកំពុងដឹកជញ្ជូនស្បៀងពីសមរភូមិមុខទៅទុកនៅសមរភូមិក្រោយនៅភូមិភាគបូព៌ា

ស្ពានជ័យ),យង់ផុង(កសិករភូមិព្រីង ឃុំពញាលៀង),ទុំវេន (កសិករភូមិស្ពានជ័យឃុំពញាលៀង),ទុំរ៉ិន(កសិករភូមិស្ពានជ័យ), ព្រាបគុន (កសិករភូមិស្ពាជ័យ),ហោចន(កសិករភូមិព្រីង) និង ទក ស៊ិន (កសិករភូមិព្រីង)។

នៅខែមករា ឆ្នាំ១៩៧៣ ឈ្មោះ មិ (អនុលេខាស្រុកកោះជ័យក្រោយមកត្រូវអង្គការចាប់ខ្លួន) បានចាត់តាំងខ្ញុំធ្វើជាប្រធានសន្តិសុខស្រុកកោះជ័យ។ ឈ្មោះ មិ មិនដាប់ពាក់ព័ន្ធនឹងការក្បត់អង្គការជាមួយខ្ញុំទេ។ ខ្ញុំរស់នៅក្នុងមន្ទីរសន្តិសុខនេះអស់រយៈប្រហែលជា៤ទៅ៥ខែ។ ក្រោយមក ខ្ញុំ និង ឈ្មោះហង់សុភី ធ្វើការនៅមន្ទីរសន្តិសុខស្រុកកោះជ័យតំបន់២៤ដែរ រស់នៅចុះសម្រុងគ្នាល្អខ្លាំងណាស់។ ខ្ញុំបានធ្វើការអប់រំឈ្មោះហង់សុភី ដាបន្តបន្ទាប់ឲ្យឃើញពីបដិវត្តន៍មានការលំបាក។ ឃើញរបបសេរីរស់នៅស្រួល ហើយប្រជាជនចូលចិត្តរស់នៅជាផកុម្មុយនីស្ត។ ហង់ សុភី ក៏បានឯកភាពជាមួយខ្ញុំដែរ។ក្រោយមកខ្ញុំបានណែនាំ ហង់ សុភី ឲ្យអនុវត្តជាបន្តបន្ទាប់ដោយធ្វើការសួរចម្លើយអ្នកទោស ដេញដោលរកខ្សែឲ្យអស់និងបំផុសអ្នកទោស ឲ្យលួចរត់ចេញពីមន្ទីរ។ ហង់ សុភីបានធ្វើតាមការណែនាំរបស់ខ្ញុំហើយមានអ្នកទោសលួចរត់ជាហូរហែ។

នៅក្នុងឆ្នាំ១៩៧៤ ខ្ញុំបានអប់រំ និងទាក់ទងបានកម្លាំងម្នាក់ឈ្មោះសុខឈឺ( ប្រធានសហករណ៍ភូមិក្អែងគង់នៅក្នុងឆ្នាំ១៩៧៥ អង្គការចាប់ខ្លួន) ដែលធ្លាប់មកទាក់ទងខ្ញុំនៅមន្ទីរសន្តិសុខស្រុកកោះជ័យ ស្ថិតនៅពោធិ៍បូរី ឃុំបឹងដោល ធ្វើការបំផុសប្រជាជននៅតាមព្រំដែនដូចជាប្រជាជននៅក្នុងឃុំក្រាំងតាយ៉ង,បឹងដោល, ព្រះស្តេច និងឃុំបន្ទាយចក្រីឲ្យរត់ទៅស្រុកយួន ជាបន្តបន្ទាប់ អស់ប្រហែលជា៣០ទៅ ៤០ នាក់។ ក្រោយមកទៀតខ្ញុំបានចាត់តាំងឈ្មោះសុខឈឺឲ្យដើរចាត់តាំងកម្លាំងខ្មែរសេរីដែលហៅថា ចលនាក្បាលសឲ្យបន្តសកម្មភាពតទៅទៀតសម្រាប់ជួយឃោសនាប្រឆាំងនឹងបដិវត្តន៍។

ក្រោយមកឈ្មោះ សុខ ឈឺ បានរាយការណ៍ប្រាប់ខ្ញុំថាគាត់បានអប់រំ និងចាត់តាំងកម្លាំងក្បាលសបាន៤នាក់ឲ្យជួយធ្វើសកម្មភាពជាមួយគាត់រួមមាន ៖ គុប(អតីតជាមនុស្សខិលខូចខាងលួច),ប៊ុន(កសិករភូមិបែកឆ្នាំងឃុំឫស្សីស្រុក),វៃ (កសិករភូមិអិតឃុំឫស្សីស្រុក) និង ចាន់ (កសិករភូមិអិត, ឃុំឫស្សីស្រុក)។

នៅក្នុងឆ្នាំ១៩៧៥ ក្រោយរំដោះឈូកបានចុះមកជួបខ្ញុំនិងសុខសែម( អនុប្រធានសន្តិសុខកោះជ័យ) ។ឈូកបានឲ្យខ្ញុំចាត់តាំងកម្លាំងនៅក្នុងមន្ទីរសន្តិសុខ ដោយធ្វើការបំផុសឈ្លើយសឹកឲ្យរត់ទៅផ្ទះ។ បន្ទាប់មកខ្ញុំនិងសុខសែមបានចាត់តាំងកម្លាំងនាក់ ដែលជាបុគ្គលិកនៅក្នុងមន្ទីរសន្តិសុខហើយធ្លាប់មានការទុកចិត្តគ្នាតាំងពីរដើមមកដើម្បីបំផុសឲ្យឈ្លើយសឹករត់ទៅផ្ទះជាបន្តបន្ទាប់ មានឈ្មោះ មឿង សារ៉ន, ឈឹម ធិ, យិន ថា និង គឹម ម៉ែន។

នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៧ ដោយទទួលផែនការក្បត់ពីខ្ញុំ,សុខសែម និងបក្ខពួក៤នាក់ ទៀតបានបំផុសឈ្លើយសឹកនៅមន្ទីរសន្តិសុខ ស្រុកកោះជ័យតំបន់២៤ ស្ថិតនៅក្នុងពោធិ៍បូរីឃុំបឹងដោលឲ្យបះបោរ។ ឈ្លើយសឹកបានវាយដណ្តើមអាវុធពីកងសន្តិសុខបាន៥ដើម ហើយថែមទាំងវាយសម្លាប់យុវជនដាំបាយម្នាក់ទៀត។ ឈ្លើយសឹកទាំងនោះបាននាំគ្នារត់ចូលព្រៃ។ ប៉ុន្តែអង្គការទទួលបានឲ្យព័ត៌មានពីតំបន់ និងស្រុកទាន់ពេលវេលា ក៏បានយកទ័ពទៅឡោមព័ទ្ធបាញ់ និងចាប់យកមកវិញទាំងអស់។ នៅខែកក្កដា ឆ្នាំ១៩៧៧ អង្គការបានចាប់ មឿង សារ៉ន, ឈឹម ធិ, យិន ថា, គឹម ម៉ែន និង សុខ សែម យកទៅបាត់។ ក្រោយមក នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៧៧ អង្គការក៏ បានចាប់ខ្លួន ខ្ញុំទៀត។

**កំណត់ចំណាំ៖** រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយ របស់ខ្មែរក្រហម។ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ថោងឈឺនពិតប្រាកដឬយ៉ាងណានោះទេ។

**ដារ៉ារដ្ឋ មេត្តា**

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍វិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្ដីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្ដុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរគឺ ជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្ដៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្ដៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុខាងកើតវិមានឯករាជ្យ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ប្រាំបី ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ ដល់ម៉ោង៥។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង យី សុឃី តាមរយៈទូរសព្ទលេខ៖ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល៖ truthsokhy.y@dccam.org។






























# វត្តពោធិ៍កែវព្រះនេត្រព្រះ ៖ អតីតមន្ទីរពេទ្យនៅក្នុងរបបខ្មែរក្រហម

នៅក្នុងសម័យបុរាណកាល វត្តអារាមបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអប់រំ និងបង្ហាត់បង្រៀនដល់កូនចៅ និងប្រជាពលរដ្ឋខ្មែរ។ ជាទម្លាប់ប្រជាជនខ្មែរ បានយកកូនចៅដែលដល់វ័យសិក្សាទៅផ្ញើ នឹងព្រះសង្ឃ ដើម្បីក្រេបយកចំណេះវិជ្ជាផ្សេងៗ។ ក្មេងប្រុសខ្លះ បានបួសជាសាមណេរ និងភិក្ខុ សង្ឃដែលជាការតបស្នងសងគុណដល់មាតាបិតា ព្រមទាំងមានឱកាស សិក្សារៀនសូត្រកាន់ខ្ពង់ខ្ពស់ថែមទៀត ។អ្នកដែលបានបួសរៀននៅពេល ដែលលាចាកសិក្ខាបទនឹងត្រូវបានប្រជាពលរដ្ឋគោរពស្រឡាញ់និងឲ្យតម្លៃយ៉ាងខ្លាំង។

ចាប់តាំងពីពាក់កណ្តាលសតវត្សរ៍ទី១៩មកប្រទេសកម្ពុជាបានស្ថិតនៅក្រោមការគ្រប់គ្រងអាណា និគមនិយមបារាំង។នាពេលនោះសាលារៀនវត្តអារាមបែបប្រពៃណីខ្មែរនៅតែបន្តដំណើរទៅមុខទៀត។ ប៉ុន្តែអាជ្ញាធរបារាំងក៏ចាប់ផ្តើមបង្កើតសាលារៀនបែបទំនើប ដោយចម្លងមួយផ្នែកធំតាមប្រព័ន្ធសិក្សានៅប្រទេសបារាំងពោលគឺ ចម្លងទាំងផ្នែកគរុកោសល្យកម្មវិធីសិក្សា និងបានដាក់បញ្ចូលភាសាបារាំងនៅក្នុងកម្មវិធីសិក្សាជាផ្លូវការរបស់សាលាទៀតផង។ ទាំងនេះដោយសារតែបារាំងត្រូវការមន្រ្តីថ្នាក់តូចៗ ជួយបម្រើការដល់រដ្ឋការអាណានិគមជាពិសេសគឺអ្នកបកប្រែពីភាសាបារាំងមកជាភាសាខ្មែរ និងខ្មែរមកភាសាបារាំង។នៅពេលនោះបារាំងបានខិតខំបញ្ជ្រៀបវប្បធម៌អរិយធម៌ភាសា និងអក្សររបស់ខ្លួនចូលទៅប្រទេសក្រោមអាណានិគម ដូចជាប្រទេសខ្មែរជាដើម។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏វត្តអារាមបានថែរក្សាវប្បធម៌ និងភាសាខ្មែរនៅគង់វង្សរហូតមក។



វត្តព្រះនេត្រព្រះ

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រទេសកម្ពុជាបានធ្លាក់ក្រោមការគ្រប់គ្រងនៃរបបខ្មែរក្រហម។ពេលនោះខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនចេញ ពីទីក្រុងភ្នំពេញលុបបំបាត់រូបិយវត្ថុ មិនឲ្យមានសាលារៀន មិនឲ្យមានផ្សារ មិនឲ្យ មានកម្មសិទ្ធិផ្ទាល់ខ្លួនមិនឲ្យមានតុលាការ បំបិទសាសនានិងបង្ខំឲ្យប្រជាជនទៅធ្វើការបង្កបង្កើនផលទាំងអស់គ្នានៅតាមទីជនបទនានា ដោយមិនប្រាប់ពីហេតុផលអ្វីបន្តិចទាល់តែ



វាលស្រែក្បែរជើងភ្នំស្រះ ក្នុងឃុំព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

សោះ។ រីឯសៀវភៅ គម្ពីរក្បួនខ្នាត វត្តអារាមព្រះពុទ្ធសាសនាជាងពាន់កន្លែងនៅទូទាំងប្រទេស ត្រូវបានខ្មែរក្រហមបំផ្លាញនិងវាយកម្ទេចចោល។វត្តអារាមខ្លះត្រូវបានខ្មែរក្រហមកែប្រែទៅជាមន្ទីរឃុំឃាំង ឃ្លាំងដាក់សម្ភារ កន្លែងចិញ្ចឹមសត្វនិងមន្ទីរពេទ្យ។ ក្នុងនោះ វត្តពោធិ៍កែវព្រះនេត្រព្រះ ដែលប្រជាជនធ្លាប់តែគោរពបូជាត្រូវបានខ្មែរក្រហមប្រែក្លាយទៅជាមន្ទីរពេទ្យ និងជាកន្លែងកប់សាកសពជនរងគ្រោះដែលស្លាប់ដោយសារធ្វើពលកម្មធ្ងន់ធ្ងរ គ្មានអាហារបរិភោគឈឺថ្កាត់គ្មានថ្នាំសង្កូវព្យាបាល និងធ្វើជាកន្លែង ស្នាក់នៅរបស់កង យុវជន ដែលធ្វើការនៅតាមការដ្ឋានការងារ ក្នុងស្រុកព្រះនេត្រព្រះ តំបន់៥ ភូមិភាគពាយ័ព្យ។

យោងតាម ឈិត សាលឿន អាយុ៦៣ឆ្នាំ រស់នៅភូមិស្រះខាងកើតឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះខេត្តបន្ទាយមានជ័យ បានរៀបរាប់ថា «ខ្ញុំគឺជាអតីតពេទ្យនៅវត្តពោធិ៍កែវព្រះនេត្រព្រះ ក្នុងរបបខ្មែរក្រហម។ មុននឹងខ្ញុំចូលធ្វើពេទ្យនៅវត្តពោធិ៍កែវព្រះនេត្រព្រះ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យចៀរសំបកដើមក្រឡាញ់ដើម្បីធ្វើថ្នាំសម្រាប់ព្យាបាលជំងឺ»។ មកដល់ចុងឆ្នាំ១៩៧៦ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យធ្វើពេទ្យប្រចាំការនៅវត្តពោធិ៍កែវព្រះនេត្រព្រះ ដោយពីមុនមកខ្ញុំមិនដែលបានរៀនវិជ្ជាពេទ្យទាល់តែសោះ។

ពេលនោះនៅក្នុងបរិវេណវត្តពោធិ៍កែវព្រះនេត្រព្រះ មិនមានសាលាបាលីសាលាឆាន់ និងមានកុដិច្រើន ដូចសព្វថ្ងៃទេគឺមានតែវិហារមួយនៅចំកណ្តាលបរិវេណវត្ត និងកុដិ

ពីរបីប៉ុណ្ណោះ។ កុដិទាំងនោះ ត្រូវបានខ្មែរក្រហមធ្វើជាកន្លែងពិនិត្យអ្នកជំងឺ ហើយជំងឺភាគច្រើនគឺសុទ្ធសឹងតែជាជំងឺហើមដែលបណ្តាលមកពីខ្វះជីវជាតិ។ អ្នកជំងឺចាប់ផ្តើមស្លាប់ជាបន្តបន្ទាប់ ព្រោះគ្មានថ្នាំពេទ្យសម្រាប់ព្យាបាល គឺមានត្រឹមតែថ្នាំអាចម៍ទន្សាយនិងសំបកដើមក្រឡាញ់តែប៉ុណ្ណោះ។

អ្នកជំងឺបានស្លាប់ជារៀងរាល់ថ្ងៃ។ បន្ទាប់ពីអ្នកជំងឺស្លាប់ខ្ញុំនិងសមមិត្តពេទ្យផ្សេងទៀត មានតួនាទីសែងសាកសពអ្នកជំងឺទាំងនោះ យកទៅកប់នៅជើងភ្នំព្រះនេត្រព្រះដែលមានចម្ងាយប្រហែលមួយគីឡូម៉ែត្រពីមន្ទីរពេទ្យ។ មានពេលខ្លះនៅពេលយើងសែងសាកសព ដល់ពាក់កណ្តាលផ្លូវខ្ញុំនិងសមមិត្តពេទ្យបានឈប់សម្រាក ដោយសារផ្លូវឆ្ងាយ។ នៅពេលទៅដល់គោលដៅ យើងចាប់ផ្តើមជីករណ្តៅដើម្បីបញ្ចុះសាកសព។ ថ្ងៃមួយ ខ្ញុំបានដាក់សាកសពចូលទៅក្នុងរណ្តៅស្រាប់តែសាកសពនោះងើបអង្គុយធ្វើឲ្យខ្ញុំនិងសមមិត្តពេទ្យភិតភ័យយ៉ាងខ្លាំងព្រោះយើងគិតថាខ្មោចលង។ ពេលធ្វើការនៅពេទ្យខ្ញុំតែងតែលួចលាក់អាហារ យកមកឲ្យអ្នកជំងឺហូបព្រោះរបបអាហារដែលអ្នកជំងឺ ទទួលបានគឺមិនគ្រប់គ្រាន់ឡើយ។ ប៉ុន្តែប្រសិនបើខ្មែរក្រហមតាមទាន់ខ្ញុំកំពុងលួចអាហារ ខ្ញុំក៏មិនអាចគេចផុតពីសេចក្តីស្លាប់ដែរ។ មានអ្នកជំងឺមួយចំនួនដែល ខ្ញុំធ្លាប់បានផ្តល់អាហារឲ្យបរិភោគបានរួចផុតជីវិតមកទល់សព្វថ្ងៃ។ ខ្ញុំធ្វើជាពេទ្យរហូតដល់របបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ហើយខ្ញុំក៏មិនផ្លាស់ប្តូរទៅរស់នៅកន្លែងផ្សេងទៀតដែរ»។

## វត្តពោធិ៍កែវព្រះនេត្រព្រះ

វត្តពោធិ៍កែវព្រះនេត្រព្រះចាប់ផ្តើមកសាងឡើងតាំងពីឆ្នាំ១៩៧៣។ ការផ្តួចផ្តើម កសាងដំបូងដោយព្រះតេជគុណកែវ។ ព្រះអង្គបានដាំដើមពោធិ៍បីដើមនៅទិសអាគ្នេយ៍នៃបរិវេណវត្តទើប ប្រជាពុទ្ធបរិស័ទស្រុះស្រួលមូលមតិគ្នាប្រសិទ្ធិនាមថា« វត្តពោធិ៍កែវ» រហូតមកដល់សព្វថ្ងៃ។វត្តពោធិ៍កែវ ព្រះនេត្រព្រះស្ថិតនៅចម្ងាយ២៨ គីឡូម៉ែត្រពីក្រុងសេរីសោភ័ណទីរួមខេត្តបន្ទាយមានជ័យ និងតាមបណ្តោយផ្លូវជាតិលេខ៦។វត្តនេះមានផ្ទៃដីសរុប៧៥.០០០ ម៉ែត្រការ៉េនៅជាប់មាត់អូរនិងវាលស្រែខាងជើងវត្ត។

**ហូ ថុនា**



ឈិត សាលឿន អ្នកស្រុកព្រះនេត្រព្រះដែលជា អតីតគ្រូពេទ្យក្នុងរបបខ្មែរក្រហម

# បូជនីយដ្ឋានតម្កល់អដ្ឋិធាតុជនរងគ្រោះពីរបបខ្មែរក្រហម នៅវត្តកំពង់ត្រាច ខេត្តស្វាយរៀង

បូជនីយដ្ឋានតម្កល់អដ្ឋិធាតុមួយ ត្រូវបានកសាងឡើង នៅអំឡុងទសវត្សរ៍ទី៨០ នៅក្នុងបរិវេណវត្តកំពង់ត្រាច ស្ថិតនៅក្នុងភូមិកំពង់ត្រាច ឃុំកំពង់ត្រាច ស្រុករមាសហែក ខេត្តស្វាយរៀង។ អដ្ឋិធាតុនៅក្នុងបូជនីយដ្ឋាន នេះប្រជាជននិងអាជ្ញាធរមូលដ្ឋាន បានប្រមែប្រមូលពីរណ្តៅសាកសពបីកន្លែងនៃស្រុករមាសហែក នៅអំឡុងឆ្នាំ១៩៨០ ដែលមានចំនួនសរុប៣៩៩អដ្ឋិធាតុ។ អដ្ឋិធាតុទាំងនេះបានបន្សល់ទុកនៅអំឡុងពេល ដែលរបបខ្មែរក្រហម កាន់កាប់អំណាចចន្លោះពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ដែលភាគច្រើនគឺជាអតីតទាហានលន់នល់ និង ជាមន្ត្រីរាជការឬអ្នកដែលជាប់និន្នាការពីរបបចាស់។អ្នកទាំងនេះ ត្រូវបានខ្មែរក្រហមចាត់បញ្ចូលជាក្រុមមូលធននិយម និងសក្តិភូមិនិយម។ ចាប់ពីឆ្នាំ១៩៧៥ខ្មែរក្រហមបាន សម្រិតសម្រាំងនិងកាប់សម្លាប់យ៉ាងរង្គាល អ្នករដ្ឋការនៅក្នុងរបបសាធារណរដ្ឋខ្មែររាប់រយនៅក្នុងខេត្តស្វាយរៀង។ខ្មែរក្រហមធ្វើការសម្លាប់ចាប់ពីថ្នាក់ដឹកនាំជាន់ខ្ពស់រហូតដល់កូនទាហាន។ អ្នកដែលធ្លាប់បម្រើឲ្យរដ្ឋាភិបាលសាធារណរដ្ឋខ្មែរទាំងប៉ុន្មាន គឺជាមុខសញ្ញាដែលត្រូវសម្លាប់ ហើយសូម្បីតែសមាជិកគ្រួសារនិងសាច់ញាតិរបស់អ្នករដ្ឋការទាំងនេះក៏ត្រូវបានសម្លាប់ដែរ។

មានអតីតទាហាន និងមន្ត្រីរដ្ឋការពីរបបចាស់មួយចំនួន បានលាក់អត្តសញ្ញាណរបស់ខ្លួន ហើយបានរួចរស់ជីវិតមកដល់សព្វថ្ងៃនេះ។ បូជនីយដ្ឋាននេះមាន សណ្ឋានជាចេតិយ និងមានទទឹងប្រហែល៤ម៉ែត្រនិងបណ្តោយប្រហែល៨ម៉ែត្រ។បូជនីយដ្ឋាននេះត្រូវបាន លាបថ្នាំពណ៌ស និងគ្មានក្បាច់រចនាបថអ្វីឡើយ។

យោងតាមការរៀបរាប់របស់ លោកតា ចាន់ ផេង អាយុ៧០ឆ្នាំ ដែលជាគណៈកម្មការអាចារ្យវត្តកំពង់ត្រាច បានបញ្ជាក់ថា បន្ទាប់ពីកងទ័ពវៀតណាមវាយផ្តួលរំលំរបប



ចាន់ ផេងគណៈកម្មការអាចារ្យវត្ត កំពង់ត្រាច កំពុងផ្តល់បទសម្ភាស៍ដល់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា

ខ្មែរក្រហមបានរយៈពេលមួយឆ្នាំរួចមក ប្រជាជន និងអាជ្ញាធរភូមិឃុំ ក៏រៀបចំប្រមែប្រមូលសំណល់ឆ្អឹងសាកសពដែលត្រូវបានខ្មែរក្រហមសម្លាប់ ដើម្បីយកមកតម្កល់ទុកនៅក្នុងវត្តកំពង់ត្រាចៗ នៅពេលនោះ រដ្ឋអំណាចនៅក្នុងភូមិឃុំបានចាត់តាំង ឈ្មោះ អ៊ីង (ស្លាប់) គឺជាពេជ្ឈឃាដធ្លាប់សម្លាប់ជនរងគ្រោះទាំងនោះផ្ទាល់ឲ្យទៅជីកកកាយរកឆ្អឹងសាកសពដែលខ្លួនបានសម្លាប់ និងកប់ៗ តាដេងបានបន្តថានៅអំឡុងពេលដែលជីកកកាយរកឆ្អឹងសាកសពចំនួនបីរណ្តៅគឺគ្រោងឆ្អឹងជនរងគ្រោះមានចំនួនលើសពី៣៩៩ ប៉ុន្តែគ្រោងឆ្អឹងនិងលលាដ៏ក្បាលជនរងរគ្រោះមួយចំនួន ត្រូវបានគោក្របីរបស់អ្នកភូមិស៊ីអស់ទៅហើយៗរីឯអដ្ឋិធាតុដែលតម្កល់ទុកមកទល់សព្វថ្ងៃគឺជា អដ្ឋិធាតុដែលនៅមានសភាព ល្អនៅឡើយៗ សូមបញ្ជាក់ថានៅឆ្នាំ ១៩៩៥ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតគម្រោងស្រាវជ្រាវទីតាំង វាលពិឃាដដែលបង្កឡើងដោយរបបខ្មែរក្រហម និងស្រាវជ្រាវឃើញទីតាំងសម្លាប់មនុស្ស ក្នុងទូទាំងប្រទេសកម្ពុជា ចំនួន៣៩០ទីតាំង ដែលមានរណ្តៅកប់សាកសព ចំនួន២៨.៨៣៣ រណ្តៅនិងមន្ទីរសន្តិសុខចំនួន១៩៦កន្លែង ព្រមទាំងបូជនីយដ្ឋានតម្កល់អដ្ឋិធាតុចំនួន៨១កន្លែងៗ



បូជនីយដ្ឋានតំកល់អដ្ឋិធាតុនៅវត្តកំពង់ត្រាច

តាមរយៈផែនទីវាលពិឃាដក្នុងប្រទេសកម្ពុជា ទីតាំងសម្លាប់មនុស្សមន្ទីរសន្តិសុខ និងបូជនីយដ្ឋានតម្កល់អដ្ឋិធាតុបានលេចឡើងនៅគ្រប់ភូមិភាគរបស់ខ្មែរក្រហមៗ ក្នុងនោះភូមិភាគបូព៌ារួមមានខេត្តស្វាយរៀង និងខេត្តព្រៃវែងមានទីតាំងសម្លាប់ចំនួន១១៨ទីតាំង ដែលមានរណ្តៅសាកសពពី៣.០៣៥ទៅ៣.០៧០រណ្តៅ, មន្ទីរសន្តិសុខចំនួន៤៤ និងបូជនីយដ្ឋានតម្កល់អដ្ឋិធាតុចំនួន២៣ៗ សាក្សីដែលបានផ្តល់បទសម្ភាសន៍បានបញ្ជាក់ថាមានចំនួនសាកសព ប្រមាណពី១៧៣.៨៧៣ទៅ២២២.៩០៧ត្រូវបាន កប់នៅក្នុងរណ្តៅនៃទីតាំងសម្លាប់ទាំង១១៨ទីតាំង ក្នុងភូមិភាគបូព៌ាៗ បន្ទាប់ពីបានប្រមែប្រមូលអដ្ឋិធាតុរួចរាល់ហើយអដ្ឋិធាតុទាំងនេះត្រូវបានលាងសម្អាតដើម្បីយកមកតម្កល់ទុកនៅក្នុងបូជនីយដ្ឋាននៃបរិវេណវត្តកំពង់ត្រាចៗ ទោះជាយ៉ាងនេះក្តីអដ្ឋិធាតុទាំងនេះមិនត្រូវបាន បោះបង់ចោលឡើយព្រោះជារៀងរាល់ឆ្នាំនៅថ្ងៃទី២០ ខែឧសភា ដែលជាថ្ងៃនៃពិធីទិវា ការចងកំហឹងប្រជាជននៅក្នុងឃុំកំពង់ត្រាច តែងតែប្រារព្ធពិធីបុណ្យនេះឡើងដោយមានអ្នកចូលរួមពីមន្ត្រីរាជការប្រជាពលរដ្ឋ និងសិស្សានុសិស្សៗទិវានៃការចងកំហឹង ក៏ជាថ្ងៃដែលប្រជាជនខ្មែរមិនអាចបំភ្លេចបាននូវសោកនាដកម្មដ៏ខ្លោចផ្សា និងជាថ្ងៃដែលត្រូវរំឭកឡើងវិញពីអតីតកាលដ៏ខ្មៅងងឹតការធ្វើទារុណកម្មនិងការកាប់សម្លាប់របស់ខ្មែរក្រហម ទៅលើប្រជាជនខ្មែរស្លូតត្រង់ៗ នៅថ្ងៃ២០ ខែឧសភា គឺជាថ្ងៃដែលខ្មែរក្រហមចាប់ផ្តើមអនុវត្តគោលការប្រល័យពូជសាសន៍ឈានដល់ការសម្លាប់មនុស្សដោយចំហរ និងឃោរឃៅព្រៃផ្សៃនៅទូទាំងប្រទេសៗក្រៅពីការប្រារព្ធពិធីទិវានៃការចងចាំនៅពេលដែលពិធីបុណ្យចូលឆ្នាំនិងបុណ្យភ្ជុំបិណ្ឌ មកដល់ពុទ្ធបរិស័ទនៅក្នុងឃុំកំពង់ត្រាចតែងតែនិមន្តព្រះសង្ឃ មកសូត្រមន្តឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធជនរងគ្រោះទាំងនោះៗ

**ហូ ថុនា**

# តុលាការខ្មែរក្រហមជិតបញ្ចប់ខ្ញុំក៏ត្រូវរំសាយកំហឹងដែរ

ទេសភាពដ៏ស្រស់ស្អាត គ្រប់ដណ្ដប់លើស្បែអន្ធការនៃអតីតកាល។ទឹកដីដែលធ្លាប់តែកើតមានជម្លោះការបះបោរ និងការកាប់សម្លាប់ បានផ្លាស់ប្ដូរ ទៅជាទឹកដី ពណ៌ខៀវស្រងាត់អមដោយដំណាំស្រូវ ដែលកំពុងតែលូតលាស់នៅក្រោមដំណក់ទឹកភ្លៀងនារដូវវស្សា។ នៅក្នុងប្រទេសកម្ពុជានាទសវត្សរ៍ឆ្នាំ៧០ ចលនាខ្មែរក្រហមបានពង្រីកកម្លាំង និងរីករាលដាលយ៉ាងឆាប់រហ័សពាសពេញផ្ទៃប្រទេស។ របបខ្មែរក្រហមបានឡើងគ្រប់គ្រងអំណាច នៅចន្លោះពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ប៉ុន្តែ បានសម្លាប់ជីវិតមនុស្សប្រហែល២លាននាក់ចំណែកមនុស្សប្រហែល៥លាននាក់ទៀតដែលបានរួចរស់ជីវិតបន្តរស់នៅ ដោយក្ដីសោកសង្រេងជាមួយនឹងកេរដំណែលនៃរបបនេះ។

នៅក្នុងស្រុកស្វាយអន្ទរ ខេត្តព្រៃវែងមានព្រឹត្តការណ៍២សំខាន់ៗបានកើតឡើង នៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម។ ព្រឹត្តិការណ៍ទី១) គឺជាការបោសសម្អាតជនជាតិភាគតិចខ្មែរ- វៀតណាមដែលបានកើតឡើងនៅក្នុងឃុំស្វាយអន្ទរក្នុងខេត្តព្រៃវែង។ នៅក្នុងឆ្នាំ២០១៦ តុលាការខ្មែរក្រហមបានស្ដាប់នូវការផ្ដល់សក្ខីកម្មទាក់ទងនឹង គោលនយោបាយរបស់ខ្មែរក្រហមចំពោះក្រុមគ្រួសារដែលមានប្រពន្ធឬប្ដីជាជនជាតិវៀតណាម។ គ្រួសារដែលមានប្រពន្ធជាជនជាតិវៀតណាមគឺខ្មែរក្រហមយកប្រពន្ធ និងកូនទៅសម្លាប់។ ចំណែកគ្រួសារដែលមានប្ដីជាជនជាតិវៀតណាមគឺ ខ្មែរក្រហមយកតែប្ដីទៅ



ទិដ្ឋភាពផ្លូវនៅក្នុងភូមិញរ ឃុំញរ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង

សម្រាប់តែប៉ុណ្ណោះ។ ព្រឹត្តការណ៍ទី២) គឺទាក់ទងនឹងការបះបោររបស់កម្មាភិបាលខ្មែរក្រហម ដែលស្ថិតក្រោម ការគ្រប់គ្រងរបស់សោភឹមនៅភូមិភាគបូព៌ា ទៅលើកម្មាភិបាលខ្មែរក្រហម ដែលមកពីភូមិភាគនិរតី។ព្រឹត្តិការណ៍នៃការបះបោរមកពីភូមិភាគនិរតី។ ការបះបោរនោះបានកើតឡើងនៅក្នុងវត្តព្រៃលាយស្ថិតក្នុងភូមិព្រិច ឃុំទឹកថ្លា ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។ការបះបោរបានកើតឡើងត្រឹមរយៈពេល១ ថ្ងៃតែប៉ុណ្ណោះ ប៉ុន្តែព្រឹត្តិការណ៍នោះបានធ្វើឲ្យប្រជាជនជាច្រើនបាន



ប្រាក់ សំបូរ កំពុងផ្តល់បទសម្ភាសន៍ដល់ក្រុមទស្សនាវដ្តីស្វែងរកការពិតនៅក្រោមផ្ទះរបស់គាត់ស្ថិតនៅក្នុង ឃុំញរ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង

នោះបានកើតឡើង នៅក្នុងឃុំទឹកថ្លាស្រុកស្វាយអន្ទរខេត្តព្រៃវែង។ ព្រឹត្តិការណ៍ទាំងពីរនេះបានកើតឡើងនៅក្នុងឆ្នាំ១៩៧៨ដូចគ្នា។ នៅក្នុងរបបខ្មែរក្រហម ប្រជាជនដែលរស់នៅក្នុងឃុំទឹកថ្លាភាគច្រើនត្រូវបានជម្លៀសចេញទៅរស់នៅភូមិភាគពាយ័ព្យ រួមមានខេត្តពោធិ៍សាត់បាត់ដំបង និង បន្ទាយមានជ័យ។ការជម្លៀសប្រជាជនចេញពីឃុំទឹកថ្លា បានកើតឡើងបន្ទាប់ពីមានការបះបោរប្រឆាំងនឹង កម្មាភិបាលខ្មែរក្រហមស្លាប់របួស និងជម្លៀសចេញទៅរស់នៅកន្លែងផ្សេងៗដែលភាគច្រើនមិនបានវិលត្រឡប់មកភូមិស្រុកវិញរហូតដល់ពេលនេះ។ប្រធានសហករណ៍ម្នាក់ ដែលជាអតីត កម្មាភិបាលខ្មែរក្រហមនៅភូមិភាគបូព៌ា និងជាប្រធានដឹកនាំការបះបោរបានចងករសម្លាប់ខ្លួន នៅដើមឫស្សីបន្ទាប់ពីដឹងថាក្រុមបះបោររបស់គាត់មិនអាចយកជ័យជម្នះបាន។ខ្ញុំបានរៀបការនៅក្នុងសម័យសង្គមរាស្ត្រនិយម។ កាលនោះខ្ញុំមានអាយុ១៨ឆ្នាំប្តី

របស់ខ្ញុំឈ្មោះណុបផានគឺជា អ្នកភូមិជាមួយគ្នាៗគាត់គឺជាអតីតទាហានលន់នល់ៗ បន្ទាប់ពីខ្ញុំរៀបការរួចនៅឆ្នាំ១៩៧០ ខ្ញុំ បានចេញទៅទីក្រុងភ្នំពេញ ដោយរស់នៅម្តុំទួលទំពូងៗ ខ្ញុំបានប្រកបមុខរបរ ដាំត្រកួនលក់ចំណែកប្តីរបស់ខ្ញុំធ្វើជាទាហានៗ

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញ ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីផ្ទះសម្បែងៗខ្ញុំនិងប្តីចង់ត្រឡប់មកស្រុកកំណើតវិញព្រោះមានឪពុកម្តាយ និងបងប្អូននៅទីនោះៗខ្ញុំបានធ្វើដំណើរជាមួយប្តីរបស់ខ្ញុំនិងកូនស្រីម្នាក់ទៀតៗ ប្រជាជនខ្លះទៀតក៏បានចាកចេញពីទីក្រុងភ្នំពេញ ដោយធ្វើដំណើរតាមផ្លូវជាតិលេខ១ក្នុងគោលបំណងទៅខេត្តស្វាយរៀងដូចខ្ញុំដែរៗ ខ្ញុំចាំថាខ្ញុំបានធ្វើដំណើរតាមផ្លូវជាតិលេខ រហូតស្រាប់តែទៅដល់កន្លែងមួយខ្មែរក្រហមបញ្ជាខ្ញុំឲ្យបត់ទៅទិសខាងជើងៗ ពេលនោះខ្ញុំឃើញមានប្រឡាយទឹកមួយដែលជីករួចហើយ ក៏បន្តដំណើររហូតដល់ស្រុករមាសហែកៗខ្ញុំបានដើរពីស្រុករមាសហែកកាត់តាមស្រុករំដួលមកភូមិកំណើតនៅស្រុកកំពង់រោទិ៍វិញៗ ប៉ុន្តែខ្មែរក្រហមឃាត់គ្រួសារខ្ញុំ និងកោះហៅទៅ ប្រជុំនៅវត្តស្វាយតាយានៗខ្មែរក្រហមបានប្រាប់ថា« បើនរណាធ្វើទាហាន មិនបាច់ទៅស្រុកកំណើតទេហើយប្រសិនបើពាក់សក្តិ១ ឬសក្តិ២សូមឆ្លើយឲ្យត្រង់មកខ្ញុំនឹងកត់ឈ្មោះទុកដំឡើងសក្តិឲ្យ»ៗខ្ញុំនៅចាំថាកាលនោះ អ្នកដែលធ្វើដំណើរមកជាមួយខ្ញុំឈ្មោះឡេង មានប្រពន្ធឈ្មោះវិន បានប្រាប់ខ្មែរក្រហមថាពាក់សក្តិ៣និងឈ្មោះគុជ មានប្រពន្ធសាលីក៏ពាក់សក្តិ៣ដែរៗឡេងនិង គុជ និងមនុស្សប្រមាណ១០នាក់ ទៀតត្រូវបានខ្មែរក្រហម ដឹកចេញពីវត្តស្វាយតាយានៗ ខ្ញុំមិនដឹងខ្មែរក្រហមយកអ្នកទាំងនោះទៅរៀនសូត្រនៅទីណានោះទេចំណែកអ្នកដែលសួររកប្រវត្តិទាហានទាំងនោះ ឈ្មោះឡូយត្រូវជាបងប្អូនរបស់ខ្ញុំដែរៗ ពេលនោះគ្រាន់តែក្រឡេកឃើញប្តីរបស់ខ្ញុំភ្លាមឡូយ បានស្រែកសួរប្តីរបស់ខ្ញុំថា «អាផានអ្ហែងមានពាក់សក្តិទេ? ប្តីរបស់ខ្ញុំក៏បានឆ្លើយកុហកថាខ្ញុំមិនមានសក្តិទេបង»ៗ ក្រោយមកខ្មែរក្រហម បានរំសាយអង្គប្រជុំហើយបានប្រកាសថា ប្រពន្ធទាហាន ដែលមានសក្តិត្រូវត្រឡប់ទៅស្រុកវិញៗ ចំណែកប្តីរបស់ខ្ញុំ មិនមានសក្តិ ក៏ខ្មែរក្រហមឲ្យត្រឡប់ទៅភូមិកំណើតដែរៗ នៅក្នុងភូមិរបស់ខ្ញុំខ្មែរក្រហមបង្កើតរោងបាយ សហករណ៍ចំនួន២កន្លែងគឺនៅក្នុងវត្តមួយកន្លែង និង នៅជិតដើមពោធិ៍ខាងក្រោភូមិមួយកន្លែងទៀតៗ

ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំង ឲ្យចូលកងចល័តវ័យកណ្តាលដែលមានសមាជិកប្រហែលជា៣០នាក់ទៅ៤០នាក់ៗនៅពេលខ្ញុំចុះស្ទូងម្តងៗ ខ្ញុំលួចចាប់ត្រីអណ្តែង,ត្រីក្រាញ់, ក្តាម,ខ្យង នៅក្នុងស្រែដាក់ក្នុងថ្នក់សំពត់ៗ ពេលទៅដល់ផ្ទះខ្ញុំបានយកត្រី, ក្តាម, ខ្យងទាំងនោះដាក់ស្ងោរលាយជាមួយបបរដែលខ្មែរក្រហមចែកឲ្យដើម្បីឲ្យមានរសជាតិៗ ខ្ញុំស្ទូងបានប្រហែលជា២ខែ ខ្មែរក្រហមបានប្តូរខ្ញុំមកកងកិនស្រូវនិង វែងអង្ករវិញៗ ខ្ញុំក្រោកនៅម៉ោង៥ព្រឹកបុកស្រូវ និងវែងអង្កររហូតដល់ម៉ោ១១ថ្ងៃទើបឈប់សម្រាកហូបបាយៗ ដោយសារផ្ទះរបស់ខ្ញុំជិតរោងបាយខ្ញុំបាន ទៅយករបបអាហារមកហូបនៅផ្ទះរួចទើបត្រឡប់មកធ្វើការវិញ រហូតដល់ម៉ោង៥ល្ងាចទើបឈប់សម្រាកៗប្រធានក្រុមបាន កំណត់ក្នុងមួយថ្ងៃឲ្យខ្ញុំបុកស្រូវ និងវែងអង្ករឲ្យបានតៅៗ នៅក្នុងក្រុមមានសមាជិកតែពីនាក់ប៉ុណ្ណោះ ដូច្នេះយើងត្រូវផ្លាស់ប្តូរវេនគ្នាបុកស្រូវនិងវែងអង្ករៗប្រសិនបើខ្ញុំធ្វើមិនបានតាមការកំណត់ទេខ្ញុំនឹងត្រូវយកទៅកសាងមិនខានៗ ខ្ញុំឃ្លានខ្លាំងណាស់ប៉ុន្តែមិនហ៊ានលួចអង្កហូបឡើយៗ ដោយសារទ្រាំទ្រនឹងការអត់ឃ្លានមិនបានមានសមាជិកកងធ្វើអង្ករខ្លះ បានលួចយកអង្ករដាក់នៅក្នុងថ្នក់សំពត់ៗ ប៉ុន្តែប្រសិនបើឈ្លបខ្មែរក្រហមចាប់ខ្លួន បានអ្នកទាំងនោះនឹងត្រូវបញ្ជូន ទៅឃុំនៅក្នុងគុកឬស្សីសាញ់មិនខានៗគុកឬស្សីសាញ់គឺ ជាកន្លែងកសាងកម្មាភិបាលនិងប្រជាជន ដែលបានធ្វើខុសវិន័យអង្គការហើយមានជនរងគ្រោះជាច្រើនត្រូវបានសម្លាប់នៅទីនោះៗ

**ដារ៉ារដ្ឋ មេត្តា**

# ក្មេងស្រី គួច សុឃីម មានសំណាងនៅរស់ដោយសារសាច់ញាតិយោធាខ្មែរក្រហមដែលបានសម្លាប់សមាជិកក្រុមគ្រួសាររបស់ខ្លួនយកទៅចិញ្ចឹម

ថ្ងៃមួយនៅដើមឆ្នាំ១៩៧៦ ក្រុមគ្រួសារក្មេងស្រីឈ្មោះគួចសុឃីមរួមមានជីដូនឈ្មោះ ម៉ាញៀប ម្ដាយមីងឈ្មោះរ៉ូចគាងបងប្រុសឈ្មោះមុយ បងស្រី ឈ្មោះងីម បងប្រុសតូចឈ្មោះង៉ា និងក្មេងស្រី សុឃីម បានរត់គេចពីស្រុកភ្នំក្រវាញដោយឆ្លងកាត់ព្រៃភ្នំ ក្នុងគោលបំណងឆ្លងទៅរស់នៅក្នុងប្រទេសថៃ។ ប៉ុន្តែជាអកុសលក្រុមគ្រួសារនេះ បានដាច់ខ្សែសង្វាក់ពីអ្នកនាំផ្លូវ និងមិនបាន ស្គាល់ភូមិសាស្ត្រច្បាស់លាស់ ក៏បានវង្វេងផ្លូវ និងធ្វើដំណើរមកដល់ភូមិវាលវែង(សព្វថ្ងៃភូមិគៀនជង្រុក ឃុំអូរសោមស្រុកវាលវែង)។នៅខណៈពេលនោះកងទ័ពតំបន់៦ នៃភូមិភាគពាយ័ព្យរបស់ខ្មែរក្រហមដែលឈរជើង នៅម្តុំទួលម្កាក់ក្នុងភូមិវាលវែងបានចាប់ខ្លួនក្រុមគ្រួសាររបស់ សុឃីម នៅម៉ោងប្រហែលជា៣រសៀល។ សុឃីម មានសំណាងបានរស់រានមានជីវិតដោយសារមានគ្រួសារ សាច់ញាតិរបស់កងទ័ពខ្មែរក្រហមម្នាក់ដែលមិនមានកូនស្រីបានសុំ សុឃីម យកទៅចិញ្ចឹម។ ចំណែកសមាជិកក្រុមគ្រួសារផ្សេងៗទៀតត្រូវបានកងទ័ពខ្មែរក្រហមយកទៅសម្លាប់នៅព្រលប់ថ្ងៃដដែលនោះ។



គួច សុឃីម ហៅ ផា

គួចសុឃីមហៅផា ហៅសំណាងមានអាយុប្រហែល៥០ឆ្នាំ(មិនចាំអាយុពិតប្រាកដ) មានប្តីឈ្មោះ សួង សុផាត អាយុ៥៣ឆ្នាំ មានកូន៤នាក់ ប្រុស៣ ស្រី១ រស់នៅ ភូមិព្រៃខ្លុងឃុំព្រៃរកាតស្រុកភ្នំក្រវាញខេត្តពោធិ៍សាត់បានរៀបរាប់ប្រវត្តិរបស់ខ្លួននិងក្រុមគ្រួសារដូចខាងក្រោម ៖

### គ្រួសាររបស់ គួច សុឃីម នៅមុនឆ្នាំ១៩៧០

ជីដូនរបស់សុឃីម មានឈ្មោះម៉ាញៀប និងជីតាឈ្មោះកុងយុហុង(ដាប់ខ្សែស្រឡាយចិន។ ជីដូនជីតារបស់សុឃីមមានកូនចំនួន៤នាក់គឺទី១) រ៉ូចង៉ៅ(ម្តាយរបស់សុឃីម) ទី២)រ៉ូចស៊ីម(ស្រី)ទី៣)រ៉ូចគាង(ស្រី)ទី៤)ឈ្មោះឈី(ប្រុស)។ ម៉ាញៀបមានស្រុកកំណើតនៅភូមិព្រៃស្នាច ឃុំលាច ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ កាលពីមុនរដ្ឋប្រហារឆ្នាំ១៩៧០ ម៉ាញៀប ជាអ្នកលក់ឥវ៉ាន់ចាប់ហួយនិងទិញផ្លែក្រវាញដង្កោដ័រ៉ុង ពីបងប្អូនជនជាតិជង និងព័រដែលរស់នៅស្រុកលើដូចជា(វាលវែងអូរសោមត្រពងពង្ស ទួលគ្រួសស្រែតាំងយ៉ស្រែពាំងប្រម៉ោយជាដើម។ ម៉ាញៀបគឺជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភម្នាក់នៅផ្សារលាច ស្រុកភ្នំក្រវាញ។គាត់មានចម្ការក្រូចពោធិ៍សាត់ជាច្រើនហិចតា នៅក្នុងភូមិព្រៃកក្នុងឃុំលាច។កាលពីពេលមុនរដ្ឋប្រហារឆ្នាំ១៩៧០ ម៉ាញៀបបានលក់

ផ្លែក្រូចពោធិ៍សាត់ បានលុយច្រើនរហូតទិញផ្ទះល្វែងនៅផ្លូវកម្ពុជាក្រោមក្រុងភ្នំពេញបានចំនួន៣ ល្វែងថែមទៀតផងៗ ចំណែកសុឃីម មានឪពុកឈ្មោះហួង និងម្តាយឈ្មោះវួច ង៉ោ(សព្វថ្ងៃរស់នៅប្រទេសអូស្ត្រាលីៗ សុឃីមមានបងប្អូនបង្កើត៥ នាក់( បងទី១ ) ប្រុសឈ្មោះមៀនបងទី២ ) ប្រុសឈ្មោះមុយបងទី៣)ស្រីឈ្មោះងឹម បងទី៤) ប្រុសឈ្មោះង៉ា និងទី៥) សុឃីមដែលជាកូនពៅៗកាលពីពេលមុនរដ្ឋប្រឆ្នាំ ១៩៧០ ឪពុកម្តាយសុឃីមក៏បានប្រកបរបបលក់ឥវ៉ាន់ចាប



ឪពុកម្តាយបង្កើតរបស់ គួច សុឃីម សព្វថ្ងៃរស់នៅប្រទេសអូស្ត្រាលី

ហួយ និងមានផ្ទះនៅក្បែរផ្សារលាច ដូចជីដូនជីតា របស់ សុ ឃីម ដែរៗ

### គ្រួសាររបស់គួចសុឃីម ចន្លោះពីឆ្នាំ១៩៧០ ដល់ ឆ្នាំ១៩៧៥

បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅឆ្នាំ១៩៧០ កម្លាំងចលនាខ្មែរក្រហមបានចូលមកដល់ឃុំលាចស្រុកភ្នំក្រវាញ និងកើតមានសង្គ្រាមរវាងកងទ័ពខ្មែរក្រហម និងទាហានលន់នល់នៅក្នុងស្រុកភ្នំក្រវាញនេះៗ នៅខណៈពេលនោះ ប្រជាជនមួយចំនួនធំត្រូវបានខ្មែរក្រហមកៀរយកទៅជាមួយៗចំណែកមួយចំនួនទៀតបានមករស់នៅក្រុងពោធិ៍សាត់ជាមួយរបបលន់នល់ៗគ្រួសារសុឃីមរួមមានជីដូនជីតា មីងមាឪពុកម្តាយនិងបងប្អូនបង្កើតរបស់សុឃីមបានភៀសខ្លួនមករស់នៅទីក្រុងភ្នំពេញៗ

បន្ទាប់មកឪពុកម្តាយ និងបងប្រុសទី១របស់សុឃីមឈ្មោះមៀនបានផ្លាស់ទៅរកស៊ីទិញលក់ត្បូងនៅក្រុងប៉ៃលិន រីឯសុឃីម និងបង ប្រុសស្រីចំនួន៤នាក់ផ្សេងទៀត បានរស់នៅរៀនសូត្រនៅទីក្រុងភ្នំពេញ ជាមួយជីដូនជីតារហូតដល់ខ្មែរក្រហម កាន់កាប់ទូទាំងប្រទេស នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ៗ ដោយសារសង្គ្រាមរវាងកងទ័ពខ្មែរក្រហមនិងទាហានលន់នល់ចន្លោះពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ តំបន់ភាគច្រើនបានប្រែជាតំបន់រំដោះ ដែលគ្រប់គ្រងដោយខ្មែរក្រហមៗ ឪពុកម្តាយរបស់ សុឃីមពិបាកក្នុងការធ្វើដំណើរពីប៉ៃលិនមកលេងឪពុកម្តាយនិងកូនចៅនៅភ្នំពេញៗ

### សុឃីម និងគ្រួសារត្រូវបានជម្លៀសពីភ្នំពេញមក ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

បន្ទាប់ពី បានចូលដល់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហម បានជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុងៗ ក្រុមគ្រួសាររបស់ សុឃីមរួមមានជីដូនជីតាម្តាយមីងនិងបងប្រុសស្រីចំនួន៣នាក់ បាននាំគ្នាធ្វើដំណើរសំដៅមករកស្រុកកំណើតនៅភូមិព្រៃស្វាច់ ឃុំលាច ស្រុកភ្នំក្រវាញខេត្តពោធិ៍សាត់ៗ ប៉ុន្តែ ក្រុមគ្រួសាររបស់សុឃីមមិនបានមកដល់ស្រុកកំណើតទេ គឺខ្មែរក្រហមចាត់តាំងឲ្យក្រុមគ្រួសារសុឃីម រស់នៅក្នុងឃុំព្រងិល ស្រុកភ្នំក្រវាញដែលមានចម្ងាយប្រមាណជាង១០គីឡូម៉ែត្រពីស្រុកកំណើតរបស់សុឃីមៗខណៈពេលរស់នៅ ក្នុងឃុំព្រងិលខ្មែរក្រហមបានចាត់តាំងម៉ាញ៉ៅបឲ្យត្បាញសំពតក្រមាចំណែកសមាជិកផ្សេងៗទៀត ត្រូវបានខ្មែរក្រហម ចាត់តាំងឲ្យធ្វើការងារតាមកង

ផ្សេងៗ។ នៅចុងឆ្នាំ១៩៧៥ឬដើមឆ្នាំ១៩៧៦ ដោយសារមានភាពអត់ឃ្លាននិងខ្លាចខ្មែរក្រហមយកទៅសម្លាប់ម៉ាញ៉ៀបបានសម្រេច នាំសមាជិកក្រុមគ្រួសារ ទាំងអស់រត់ភៀសខ្លួនទៅប្រទេសថៃ។ ប៉ុន្តែ ការរត់គេចខ្លួនរបស់ម៉ាញ៉ៀបត្រូវបានខ្មែរក្រហមតាមទាន់និងចាប់បានប្តីរបស់គាត់ (យុ ហេង) នៅភូមិព្រៃពាយ ឃុំលាចហើយខ្មែរក្រហមក៏បានសម្លាប់តាយុហេងចោលទៅ។ ចំណែកម៉ាញ៉ៀប រួមជាមួយកូនស្រីឈ្មោះវួចគាងនិងចៅៗបានរត់ចូលក្នុងព្រៃ ហើយដោយធ្វើដំណើរយូរទៅៗ មិនមានបាយហូប ក៏នាំគ្នាបេះស្លឹកឈើផ្លែមៀនព្រៃហូប ដើម្បីបន្តដំណើរទៅមុខទៀត។ ម៉ាញ៉ៀបកូនស្រីនិងចៅៗ បានធ្វើដំណើរមកដល់ភូមិវាលវែង (អូរសោម) ក៏ត្រូវបានប្រជាជនរាយការណ៍ឲ្យកងទ័ពខ្មែរក្រហមដែលប្រចាំការនៅទួលម្កាក់ក្នុងភូមិវាលវែងចាប់ខ្លួនតែម្តង។

**ការចាប់ និងសម្លាប់ក្រុមគ្រួសាររបស់តួចសុឃឹមនៅដើមឆ្នាំ១៩៧៦**



យ៉ឹង ហ៊ុម ប្អូនប្រុសឪពុកចិញ្ចឹមរបស់ សុឃឹម

ថ្ងៃមួយនៅដើមឆ្នាំ ១៩៧៦ មេដឹកនាំខ្មែរក្រហមប្រចាំនៅស្រុកពាមព្រស តំបន់៦ ក្នុងភូមិភាគពាយ័ព្យបានឡើងមកភូមិវាលវែងដែលជាភូមិដាច់ស្រយាលមួយ ដើម្បីកោះហៅប្រជាជនឲ្យចូលរួមធ្វើមីទ្ទីញ។ មីទ្ទីញបានចប់នៅម៉ោងប្រហែលពរសៀលថ្ងៃដដែលនោះ ស្រាប់តែមានព្រឹត្តិការណ៍មួយកើតឡើងដោយសារយោធាខ្មែរក្រហមចាប់បានក្រុមគ្រួសារមួយមានគ្នាប្រហែលជា៦នាក់ មានប្រុស មានស្រី។ នៅខណៈពេលនោះហ៊ំ (ត្រូវជាប្អូនប្រុសឪពុកចិញ្ចឹមរបស់សុឃឹម)និងត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើកងឈ្លបប្រចាំភូមិវាលវែង បានស្គាល់សមាជិកខ្លះ នៃក្រុមគ្រួសារជនរងគ្រោះដូចជា ម៉ាញ៉ៀប ចែគាង និងកូនចឹកហួង (បងស្រីរបស់សុឃឹមឈ្មោះងឹម) ព្រោះកាលទៅរៀននៅល្វាចក្នុងស្រុកភ្នំក្រវាញ ហ៊ំ បានស្នាក់នៅផ្ទះចិនឆៅឈ្មោះ ចឹក ចុងឈឹមហើយផ្ទះកូនស្រីម្នាក់របស់ ចឹកចុងឈឹម ស្ថិតនៅជិតផ្ទះរបស់ម៉ាញ៉ៀបៗ ហ៊ំ ឲ្យដឹងថាក្រុមគ្រួសារម៉ាញ៉ៀបមានបំណងរត់ចេញទៅប្រទេសថៃ ប៉ុន្តែចៃដន្យគាត់ បានដាច់ខ្សែរយៈអ្នកនាំផ្លូវផង និងបានដាច់បាយដាច់ទឹកផងនោះទើបពួកគាត់បានដើរសំដៅចូលមកភូមិវាលវែង និងត្រូវយោធាតំបន់ដែល មានប្រធានកងអនុសេនាតូច ឈ្មោះវឿន អនុប្រធានឈ្មោះខ្មៀមនិងយោធាផ្សេងៗទៀតចាប់បាន យកទៅដាក់ក្នុងផ្ទះមួយដែលគ្មានមនុស្សរស់នៅ។ យោធាខ្មែរក្រហមក៏បានបញ្ជាឲ្យម្តាយរបស់ហ៊ំ ដាំបាយធ្វើម្ហូបឲ្យក្រុមគ្រួសារម៉ាញ៉ៀបហូប បន្ទាប់ពីបាយសម្ងរឆ្អិន ហ៊ំ ជាអ្នកយកបាយទៅឲ្យក្រុមគ្រួសារម៉ាញ៉ៀបហូបៗ នៅប្រហែលជាម៉ោង៧ ទៅ៨យប់មានយោធាប្រហែលជា៦ ទៅ៧ នាក់បានបណ្តើរក្រុមគ្រួសារ ម៉ាញ៉ៀប ទៅសម្លាប់ចោលនៅក្បែរអូរជិតមាត់ស្ទឹងៗ ពេលព្រឹកថ្ងៃបន្ទាប់ យោធាខ្មែរក្រហមឲ្យបញ្ជាឲ្យកងឈ្លបឈ្មោះហ៊ំ ឈ្មោះមុំ ឈ្មោះមុន និងកងឈ្លប២ទៅ៣នាក់ទៀតទៅជីករណ្តៅកប់នៅជិតមាត់ស្ទឹងនោះ។ ហ៊ំ បានឃើញសាកសពស្ត្រីពីរនាក់ស្លាប់ដោយអាវរក និងគ្មានសម្លៀកបំពាក់

ចំណែកបងស្រីរបស់សុឃីម ឈ្មោះ ងឹម គឺស្លាប់ដោយសារគ្រាប់កាំភ្លើងហើយអ្នកផ្សេងទៀតគឺស្លាប់ ដោយសារវាយនឹងដំបង។ អ្នកដឹកនាំការសម្លាប់មានឈ្មោះ រឿន ជាប្រធានរួមជាមួយឈ្មោះខ្មៀមឈ្មោះសៀបឈ្មោះលុម (ប្អូនថ្លៃឪពុកចិញ្ចឹមសុឃីម) និងយោធាខ្មែរក្រហមផ្សេងទៀតៗក្នុងចំណោមយោធាទាំងនោះមានឈ្មោះ រឿន បានចាប់រំលោភបងស្រីសុឃីមឈ្មោះងឹមមុនពេលសម្លាប់។ កងយោធាខ្មែរក្រហម



មាស ខ្មៀម អតីតអនុប្រធានអង្គភាពយោធា ប្រចាំនៅទួលម្កាក់ ក្នុងភូមិវាលវែងស្រុកវាលវែង ខេត្តពោធិ៍សាត់ ត្រូវជាប្អូនជីដូនមួយ ឪពុកចិញ្ចឹមរបស់ សុឃីម

ក៏បានសម្រាតយកខោអាវជនរងគ្រោះទាំងអស់ដែរ។ ហ៊ំដឹងថាមានតែក្មេងស្រីម្នាក់(ឈ្មោះសុឃីមហៅថា ហៅ សំណាង) ដែលត្រូវជាចៅរបស់ម៉ាញ៉េបបានរួចផុតពីការ សម្លាប់នេះ។ បន្ទាប់ពីសម្លាប់មនុស្សអស់ហើយ យោធាបានប្រមូលយកទ្រព្យសម្បត្តិមានតម្លៃពីក្រុមគ្រួសារ ម៉ាញ៉េប ដូចជាមាសពេជ្រផ្លាកទីនចំនួនមួយកំសៀវ និងនាឡិការដៃចំនួនមួយកំសៀវទៀត។ យោធាខ្មែរក្រហមយកពេជ្រ ផ្លាកទីនទៅចែកឲ្យអ្នកភូមិដោយពួកគេគិតថា (ពេជ្រ និងផ្លាកទីន) មិនសូវមានតម្លៃដូចនាឡិកានិងមាស។

## គួច សុឃីម ត្រូវបានសុំយកទៅចញ្ចឹម និងការរស់នៅជាមួយឪពុកម្តាយចិញ្ចឹម

សុឃីម មានសំណាងបានរស់ដោយសារមានឪពុកចិញ្ចឹមឈ្មោះ ហុក ម្តាយឈ្មោះ ធុល មិនមានកូនស្រីហើយបានសុំសុឃីមពីយោធាតំបន់ឈ្មោះ រឿន និង ខ្មៀម ដែលត្រូវជាបងប្អូនជីដូនមួយជាមួយខ្លួន។ នៅពេលដែលកងយោធាបណ្តើរក្រុមគ្រួសារ ម៉ាញ៉េប ទៅសម្លាប់នៅពេលព្រលប់ថ្ងៃនោះយោធាឈ្មោះ ខ្មៀម ក៏បានពារក្មេងស្រីឈ្មោះ សុឃីម (ចៅរបស់ ម៉ាញ៉េប) យកមកប្រគល់ឲ្យបងជីដូនមួយរបស់ខ្លួនឈ្មោះ ហុក ហើយយោធាផ្សេងៗទៀត ក៏បានបន្តនាំយកក្រុមគ្រួសារ ម៉ាញ៉េប ទៅកន្លែងសម្លាប់តែម្តង។ នៅខណៈពេលនោះសុឃីមមានជំងឺនិងអត់បាយផងនោះ សុឃីមមិនអាចដើរអង្គុយនិងនិយាយស្តីបានឡើយ គឺត្រូវឪពុកម្តាយចិញ្ចឹមព្យាបាលនិងមើលថែរប្រមាណ១ទៅ២ខែទើបសុឃីមអាចអង្គុយដើរ និងនិយាយស្តីបាន ប៉ុន្តែសុឃីម ហាក់មិនបានចងចាំអំពីអ្វី ដែលខ្លួនបានរស់នៅជាមួយជីដូនជីតានៅភ្នំពេញការជម្លៀសពី ទីក្រុងភ្នំពេញមកនៅស្រុកភ្នំក្រវាញ និងការរត់គៀសខ្លួនចេញពីស្រុកភ្នំក្រវាញមកដល់ភូមិវាលវែងនេះឡើយ។

សុឃីម មានសំណាងដែលបានឪពុកចិញ្ចឹមស្រឡាញ់ ពេលឪពុកទៅណាមកណាភាគច្រើន តែងយក សុឃីម ទៅជាមួយ និងឲ្យសុឃីម ឡើងជិះកគាត់។ សុឃីម ដឹងថាឪពុកចិញ្ចឹម សុឃីម នៅក្នុងសម័យខ្មែរក្រហមមិនបាននៅផ្ទះទេ។ គាត់ច្រើនដើរធ្វើការជាមួយកម្មាភិបាលខ្មែរក្រហម និងទៅទិញថ្នាំពេទ្យនៅ ប្រទេសថៃយកមកឲ្យខ្មែរក្រហម។ នៅឆ្នាំ១៩៧៧ ប្រជាជនទាំងអស់នៅស្រុកវាលវែង ត្រូវបាន

ខ្មែរក្រហមជម្លៀសចេញមករស់នៅស្រុកលាច (ស្រុកភ្នំក្រវាញ)វិញ។ កាលនោះឪពុកម្តាយចិញ្ចឹមសុឃីមត្រូវអង្គការខ្មែរក្រហមបញ្ជូនទៅមុន ចំណែកសុឃីមត្រូវរស់នៅជាមួយយាយចិញ្ចឹមបន្តមួយរយៈទៀត។ សុឃីមតែងតែឆ្ងល់ថាយាយចិញ្ចឹមម៉េចក៏ចេះតែធ្វើបាបគាត់ហើយពេលគាត់ធ្វើអ្វីតែងតែមានកំហុស ចំណែកចៅៗផ្សេងទៀតមិនដែលត្រូវបានស្តីបន្ទោសនិងត្រូវរំពាត់ដូចខ្លួនឡើយ។ពេលខ្មែរក្រហមជម្លៀសមកនៅស្រុកល្វាចទើប សុឃីម បានជួបឪពុកម្តាយចិញ្ចឹមនិងរស់នៅជាមួយពួកគាត់វិញ។ ពេលស្នាក់នៅស្រុកលាច សុឃីម ត្រូវបានអង្គការ បានចាត់តាំងឲ្យចូលកងកុមារដើរកាប់ទន្រ្ទានខែត្រ កាប់ដីបូកដើម្បីយកទៅធ្វើជី។ នៅពាក់កណ្តាលឆ្នាំ១៩៧៨សុឃីមឮម្តាយចិញ្ចឹមប្រាប់ថា ឪពុកត្រូវខ្មែរក្រហមចាត់តាំងឲ្យទៅទិញថ្នាំពេទ្យ នៅប្រទេសថៃ។ ឪពុករបស់ សុឃីម តាំងពីចេញទៅបាត់ខ្លួនរហូត មិនឃើញត្រឡប់មកវិញទេ។ សុឃីម រស់នៅជាមួយម្តាយរហូតដល់កងទ័ពវៀតណាមចូលមកនៅ ឆ្នាំ១៩៧៩។

## ជីវិតរបស់ គួច សុឃីម ក្រោយឆ្នាំ១៩៧៩

ពេលកងទ័ពវៀតណាមចូលមកដល់ប្រទេសកម្ពុជា នៅឆ្នាំ១៩៧៩ សុឃីម និងម្តាយចិញ្ចឹមមិនរត់ចូលព្រៃទេ គឺរស់នៅក្នុងភូមិព្រែក៣ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ នៅឆ្នាំ១៩៧៩ប្រជាជននៅក្នុងភូមិមានសិទ្ធិសេរីភាពក្នុងការនិយាយស្តីហើយអ្នកជិតខាង បានហៅសុឃីមថាសំណាង។។ នៅឆ្នាំ១៩៨០ សុឃីមបានចូលរៀននៅសាលាបឋមសិក្សាភូមិព្រែក ពេលនោះមានមនុស្សប្រុសពីរនាក់បានជិះកង់មករកសុឃីម ប៉ុន្តែសុឃីម បានរត់គេចពីបុរសទាំងពីរនាក់នោះព្រោះគិតថាប្រម៉ាត់ប្រមង់មករកចាប់កូនក្មេង។។ ក្រោយមកអ្នកគ្រូឈ្មោះកាយ បានប្រាប់ថាបុរសទាំងពីរនាក់នោះមករកសុឃីម។ ប៉ុន្តែសុឃីមនៅតែមិនដឹងថាបុរសម្នាក់ក្នុងចំណោមពីរនាក់ ដែលជិះកងមករកខ្លួននោះគឺជាឪពុកបង្កើតឡើយ ពីព្រោះគាត់បានមករកសុឃីមតែម្តងហើយក៏បាត់ដំណឹងរហូត។ នៅដើមឆ្នាំ១៩៨០ អតីតកងយោធាខ្មែរក្រហមឈ្មោះសៀបដែលបាន សម្លាប់បង។ យាយ និងមីងរបស់សុឃីមបានមករស់នៅក្នុងភូមិជាមួយសុឃីម។ សៀបជាអ្នករកខ្មីមចាន់យកទៅលក់ឲ្យថៃហើយសៀបតែងតែមកជិតនិងឲ្យលុយសុឃីម ចាយជាហូរហែព្រោះសៀបក៏ជាសាច់ញាតិម្នាក់របស់ឪពុកចិញ្ចឹមសុឃីមដែរ។ អ្នកភូមិព្រែក ដែលធ្លាប់រស់នៅភូមិវាលវែងជាមួយឪពុកម្តាយចិញ្ចឹមរបស់ សុឃីម តែងតែនិយាយចំអន់លេងថា ឯងមានសំណាងណាស់ដែលបានរស់នៅមកសព្វថ្ងៃនេះ។ សុឃីម ចេះតែឆ្ងល់នឹងសំដីអ្នកភូមិដែលនិយាយរឿងរ៉ាវរបស់ខ្លួនជាញឹកញាប់។ សុឃីម ក៏ចាប់ផ្តើមបានដឹងរឿងរ៉ាវរបស់ខ្លួនខ្លះៗ និងបានដឹងច្បាស់នៅក្នុងឆ្នាំ១៩៨៦។ ចំណែកម្តាយចិញ្ចឹមរបស់ សុឃីម តែងតែព្យាយាមលាក់ព័ត៌មានទាំងនេះ មិនឲ្យសុឃីមដឹងពីរឿងរ៉ាវរបស់ខ្លួនឡើយ។

## គួចសុឃីមយល់សប្តិឃើញយាយ និងបានដឹងការពីការសម្លាប់ក្រុមគ្រួសារ

នៅឆ្នាំ១៩៨៦ សុឃីម បានយល់សប្តិឃើញយាយរបស់ខ្លួនមកហៅឲ្យទៅរស់នៅជាមួយគាត់នៅក្នុងស្ទឹងមួយ។ នៅពេលព្រឹកថ្ងៃបន្ទាប់សុឃីមបានដើរទៅផ្ទះឪពុកមាចិញ្ចឹមម្នាក់ឈ្មោះ ហឿង ដែលជាអតីតយោធាខ្មែរក្រហមផ្នែកដឹកជញ្ជូនតាមដំរី។ សុឃីម បាននិយាយរៀបរាប់ពីការយល់សុបិនប្រាប់ ហឿង ថា ពូខ្ញុំបានយល់សប្តិថា យាយខ្ញុំស្លាប់នៅជិតមាត់ស្ទឹង។ពេលនោះ ពូហឿងភ្ញាក់ខ្លួនព្រឺតហើយសួរខ្ញុំវិញថានរណានិយាយប្រាប់ឯង? ខ្ញុំឆ្លើយប្រាប់ថាខ្ញុំយល់សប្តិឃើញយាយរបស់ខ្ញុំ ហឿង ក៏បាននិយាយប្រាប់ខ្ញុំថាយាយនិងបងប្អូនឯងត្រូវបានយោធាយកទៅសម្លាប់ ជិតមាត់ស្ទឹងប្រហែលជា១០០ម៉ែ្រតពីវត្តវាលវែងចាស់។ ពូហឿងក៏បាន ប្រាប់ខ្ញុំអំពីឈ្មោះយោធា ដែលបានសម្លាប់ក្រុមគ្រួសារខ្ញុំនិងរំលោភបងស្រីខ្ញុំទៀតផង។ យោធាដែលបានសម្លាប់និងរំលោភក្រុមគ្រួសារខ្ញុំ គឺភាគច្រើនសុទ្ធតែជាសាច់ញាតិខាងឪពុកចិញ្ចឹមខ្ញុំ។

## ការរៀបការ និងការរកឃើញឪពុកម្តាយបង្កើតរបស់គួច

## សុឃីម

សុឃីម បានឈប់រៀននៅឆ្នាំ១៩៨៤ បន្ទាប់មក សុឃីម បានជួយធ្វើការងារស្រែ ចម្ការម្ដាយចិញ្ចឹម និងស៊ីឈ្នួលអ្នកស្រុកអ្នកភូមិបានកម្រៃបន្តិចបន្តួចដើម្បីចិញ្ចឹមជីវិត ។សុឃីមបានរៀបការជាមួយប្ដីឈ្មោះសុផាតនៅឆ្នាំ១៩៨៨ ។សុផាត មានស្រុកកំណើតនៅខេត្តតាកែវ និងបាន មកធ្វើកងទ័ពខាង របបសាធារណរដ្ឋប្រជាមានិតកម្ពុជាប្រចាំនៅស្រុកភ្នំក្រវាញនៅក្នុងឆ្នាំ១៩៨៤-១៩៨៥។ នៅពេលឈរជើងនៅភូមិព្រែកនេះសុផាតក៏បានជួប និងស្រឡាញ់សុឃីម ។បន្ទាប់មកអ្នកទាំងពីរក៏សម្រេចចិត្តរៀបការ។ ដោយសារភាពក្រីក្រសុឃីមនិងសុផាតបានរៀបចំពិធីរៀបការតែបន្តិចបន្តួចដោយមានសាច់ញាតិ និងមិត្តភក្តិចូលរួម តែបួនដប់នាក់ប៉ុណ្ណោះ។នៅឆ្នាំ១៩៩០ សុឃីម បានសុំឲ្យម្ដាយចិញ្ចឹម និយាយការពិតថា តើគាត់មានបានដឹងថាឪពុកម្ដាយបងប្អូនបង្កើតរបស់ខ្លួននៅទីណាទេ? បើគាត់បានដឹងសូមឲ្យគាត់ជួយស្វែងរកផង។ កាលនោះម្ដាយចិញ្ចឹម សុឃីម បានឃើញសុឃីមមានការលំបាកផ្នែកជីវភាពពេក គាត់ក៏យល់ព្រមជួយប្រាប់ដំណឹងរបស់ សុឃីម ទៅខាងសាច់ញាតិរបស់ សុឃីម នៅខាងភូមិព្រៃស្នាច់ឃុំលាចស្រុកភ្នំក្រវាញ។

នៅឆ្នាំ១៩៩០បងប្អូនជីដូនមួយរបស់ សុឃីម មានឈ្មោះពិសិដ្ឋនិងឈ្មោះប៉េងបានធ្វើដំណើរមកដល់ផ្ទះ សុឃីមហើយបានថតរូបសុឃីមផ្ញើទៅឪពុកម្ដាយបង្កើតនៅប្រទេសអូស្ត្រាលី។

នៅឆ្នាំ១៩៩២ ម្ដាយរបស់ សុឃីម ឈ្មោះ វ៉ូចង៉ោ បានមកលេងស្រុកខ្មែរ ប៉ុន្តែគាត់មិនហ៊ានមកស្រុកកំណើត ព្រោះមិនទាន់សុវត្ថិភាព។ ម្ដាយបង្កើតរបស់ សុឃីម ក៏បានណាត់សុឃីមឲ្យឡើងមកជួបនៅភ្នំពេញ។ សុឃីម បានធ្វើដំណើរមកជាមួយប្ដីនិងម្ដាយចិញ្ចឹម។នៅខណៈពេលសុឃីម បានជួបនឹងម្ដាយបង្កើតនៅភ្នំពេញ ដំបូងម្ដាយហាក់ដូចជានៅមានការសង្ស័យ ម្យ៉ាងទៀត មានសាច់ញាតិនិយាយប្រាប់គាត់ថា ប្រសិនបើ សុឃីម ជាកូនស្រីគាត់បង្កើតមែននោះម្ដេចក៏មានសម្បុរខ្មៅ ហេតុអ្វីសម្បុរសមិនដូចគាត់។ ទោះបីជាម្ដាយចិញ្ចឹម សុឃីម បាននិយាយរឿងរ៉ាវប្រាប់ក៏ដោយក៏គាត់នៅតែមិនអស់ចិត្ត ហើយបានហៅគ្រូពេទ្យនៅភ្នំពេញម្នាក់ឈ្មោះ ង៉ុយ មកបូមឈាម សុឃីម យកទៅពិនិត្យមើលដោយកុហកថាបូមឈាមយកទៅមើលមេរោគ។

នៅពេលរសៀលថ្ងៃដដែលនោះ គ្រូពេទ្យបានយកលទ្ធផលឈាមមកឲ្យបន្ទាប់ពីមើលលទ្ធផល ឈាមហើយម្ដាយសុឃីមបានស្ទុះមកជិតសុឃីមហើយយំឱបគ្នា និងបានស្នាក់នៅជាមួយគ្នានៅទីក្រុងភ្នំពេញ រហូតដល់ម្ដាយសុឃីមត្រឡប់ទៅប្រទេសអូស្ត្រាលីវិញ។

នៅឆ្នាំ១៩៩៧ ឪពុកបង្កើតរបស់ សុឃីម បានមកលេងស្រុកខ្មែរម្ដងនិងបានណាត់សុឃីមឲ្យមកជួបនៅវត្តស៊ីងមានជ័យទីក្រុងភ្នំពេញ។ ម្ដាយសុឃីម បាននិយាយថាឪពុកសុឃីមមិនឆាយជឿរណាឆាយៗទេ។ គាត់បាននិយាយប្រាប់យាយៗនៅក្នុងវត្តថា បើខ្ញុំជាកូនគាត់មែនគាត់ប្រាកដជាស្គាល់ពេលខ្ញុំចុះពីលើឡានទូរីសមក ឪពុកបង្កើតរបស់ខ្ញុំភ្ញាក់មាត់ថាខ្ញុំពិតជាកូនរបស់គាត់មែន ពេលនោះយាយៗនៅក្នុងវត្តស៊ីងមានជ័យនាំគ្នានិយាយថា មិនមែនកូនយ៉ាងម៉េចបើមុខដូចឪពុកចឹង។

សុឃីម បានជួបឪពុកម្ដាយបង្កើតវិញ ប៉ុន្តែសុឃីមហាក់ដូចជាគ្មានភាពសិទ្ធិស្នាល ឪពុកនឹងកូន ឡើយព្រោះសុឃីមបានបែកពី ឪពុកម្ដាយ តាំងពីនៅតូចៗមកម្ល៉េះគឺតាំងពីជំនាន់ លន់ នល់ ជំនាន់ខ្មែរក្រហមរហូតដល់ស្រុកមានសន្តិភាពគឺមិនដែលបានរស់នៅជាមួយគ្នាឡើយ។ឪពុកម្ដាយរបស់សុឃីមបានភៀសខ្លួន ទៅរស់នៅប្រទេសអូស្ត្រាលីតាំងពីអំឡុងឆ្នាំ១៩៨០ហើយសព្វថ្ងៃ ឪពុកម្ដាយ សុឃីមចាស់ជរាណាស់ទៅហើយគឺម្ដាយមានអាយុ៨៩ និង ឪពុកមានអាយុ៩៣ឆ្នាំមិនអាចធ្វើដំណើរមកលេងប្រទេសកម្ពុជាបានដូចមុនទៀតឡើយ។ សព្វថ្ងៃសុឃីម ទាក់ទងនិយាយទៅកាន់ឪពុកម្ដាយតែតាមរយៈទូរសព្ទប៉ុណ្ណោះ។

***ឡុង ដានី និង សុខ វណ្ណៈ***

# កូនប្រុសត្រូវចេញតស៊ូបម្រើបដិវត្តន៍

នៅក្នុងសង្គមខ្មែរតាមប្រពៃណីពីបុរាណ កូនប្រុសត្រូវបួសជាព្រះសង្ឃដើម្បីសងគុណឪពុកម្តាយ ដែលបានខិតខំចិញ្ចឹមបីបាច់ថែរក្សាខ្លួន ហើយក៏ជាឱកាសដែលអាចរៀនអក្សរសាស្ត្រធម៌វិន័យ ក្នុងព្រះពុទ្ធសាសនាក្នុងរយៈពេលខ្លួនបួសជាព្រះសង្ឃ និងចូលរួមកសាងសង្គមបន្ទាប់ពីលាចាកសិក្ខាបទ។ ប៉ុន្តែដោយឡែកនៅក្នុងសម័យសង្គ្រាមក្នុងអំ


ហឹម សួន កំពុងអង្គុយនៅរោងដាក់សម្ភារ ក្នុងបរិវេណវត្តសុវណ្ណគិរី ស្ថិតនៅឃុំទឹកថ្លា ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង

ឡុងទសវត្សរ៍ ឆ្នាំ១៩៦០ ដំណាក់កាលបដិវត្តន៍របស់ក្រុមខ្មែរក្រហម កម្លាំងយុវជនគឺចាំបាច់បំផុត។ យុវជនគឺត្រូវហ៊ានលះបង់និងកាន់អាវុធចូលក្នុងសមរភូមិប្រយុទ្ធជាមួយសត្រូវៗមានយុវជនជាច្រើន នៅក្នុងភូមិរបស់ខ្ញុំ បានរត់ចូលព្រៃដើម្បីតស៊ូជាមួយបដិវត្តន៍។ យុវជនទាំងនោះទទួលការអប់រំពីមេភូមិ ចំណែកខ្ញុំបានទទួលការអប់រំពីម្តាយរបស់ខ្ញុំថា«កូនប្រុសដាច់ខាតត្រូវតែចូលរួមបម្រើបដិវត្តន៍»។

ខ្ញុំឈ្មោះ ហឹម សួន ភេទប្រុស សព្វថ្ងៃអាយុ៧០ឆ្នាំ កើតនៅ ឃុំទឹកថ្លា ស្រុកព្រៃវែង (បច្ចុប្បន្ន ស្រុកស្វាយអន្ទរ) ខេត្តព្រៃវែង។ ខ្ញុំមានឪពុកឈ្មោះ កែន បឹម និង ម្តាយឈ្មោះ យឹម យ៉ែន។ខ្ញុំមានបងប្អូនបង្កើតចំនួន៨នាក់គឺស្រី៤និងប្រុស៤នាក់។ ខ្ញុំបានរៀនសូត្រត្រឹមថ្នាក់ទី៧ នៅសាលាឈើកាច់ ស្ថិតនៅក្នុងស្រុកបាភ្នំ។ បន្ទាប់មកនៅពេលខ្ញុំមានអាយុ១៧ឆ្នាំ ខ្ញុំបានឈប់រៀន ទៅជួយធ្វើការងារ ឪពុកម្តាយវិញ។ នៅក្នុងរបបខ្មែរក្រហម ឃុំទឹកថ្លា ត្រូវបានបែកចេញជាពីរផ្នែកគឺភាគខាងត្បូងរួមមាន(សង្កែជ្រុំ, ក្រោកតាប៉ាង, ប្រអួលទឹកស្ថិតនៅក្នុងស្រុកបាភ្នំ ចំណែកភាគខាងជើងគឺឃុំទឹកថ្លាស្ថិតនៅក្នុងស្រុកព្រៃវែង។ នៅក្នុងឆ្នាំ១៩៦៦ ខ្ញុំមានអាយុ១

៨ឆ្នាំ។ខ្ញុំបានរៀបការជាមួយឈ្មោះ ខៀវ ម៉ុនដែលជាអ្នកភូមិជាមួយគ្នា។បន្ទាប់ពីរៀបការបានរយៈពេលបាន១ឆ្នាំ ខ្ញុំនិងប្រពន្ធរបស់ខ្ញុំបានរស់នៅបែកផ្ទះពីឪពុកម្តាយ។ មុនពេលកើតមានរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តមសីហនុ ខ្ញុំមានកូនចំនួន២នាក់។ ពេលនោះខ្ញុំបានឃើញខ្មែរក្រហមចូលមកក្នុងភូមិឃោសនាបញ្ចុះបញ្ចូលប្រជាជនជាញឹកញាប់។ ក្រោយមកខ្ញុំក៏បានស្ម័គ្រចិត្តចូលរួមបម្រើបដិវត្តន៍នៅក្នុងឆ្នាំ១៩៦៧ តាមការលើកទឹកចិត្តពីម្តាយខ្ញុំនិងការអប់រំពីមេភូមិ។ក្រោយមកឆ្នាំ១៩៦៨-១៩៦៩ ខ្ញុំក៏ត្រូវបានជ្រើសរើសធ្វើជាយោធានៅក្នុងស្រុកអូរាំងឪតំបន់២២។ ខ្ញុំមិនបានយកប្រពន្ធកូនទៅជាមួយទេ។ ប្រពន្ធរបស់ខ្ញុំនៅផ្ទះធ្វើស្រែនិងមើលថែកូន។

នៅពេលមានបាតុកម្មទាមទារ អំណាចឲ្យសម្តេចព្រះនរោត្តម សីហនុ នៅក្នុងឆ្នាំ១៩៧០ ខ្ញុំបានចូលរួមទាមទារជាមួយអ្នកភូមិដែរ។ ខ្ញុំត្រូវបានប្រធានភូមិចោទប្រកាន់ថាគឺជាមេដឹកនាំបាតុកម្ម។ ខ្ញុំក៏ត្រូវបាននាំខ្លួនបញ្ជូនទៅកាន់គុកភ្នំថ្ពកដែលមានទីតាំងនៅជិតភ្នំឈើកាច់។ ប៉ុន្តែខ្ញុំ និងបក្ខពួក៩នាក់ទៀតបានរត់គេចខ្លួន ព្រោះខ្ញុំបានស្គាល់ឈ្មោះល្វៃដែលមានតួនាទីគ្រប់គ្រងគុកនៅទីនោះ។ ក្រោយមកឆ្នាំ១៩៧៤ ខ្ញុំត្រូវបានបញ្ជូនឲ្យត្រឡប់មកឃុំទឹកថ្លាវិញ ដែលមានតួនាទីជាយោធាស្រុកស្វាយអន្ទរ។ នៅដើមឆ្នាំ១៩៧៥ វត្តសុវណ្ណគិរីដែលទើបត្រូវបានសាងសង់នៅក្នុងឆ្នាំ២០០២ ស្ថិតនៅក្នុងឃុំទឹកថ្លាគឺជាទីតាំងដែល មានការទម្លាក់គ្រាប់បែកយ៉ាងខ្លាំង។ ចំណែកអ្នកភូមិ ក៏បាននាំគ្នារត់ទៅរស់នៅលាក់ខ្លួននៅក្នុងព្រៃ។

ខ្ញុំនៅតែបន្តសកម្មភាពបម្រើឲ្យបដិវត្តន៍ រហូតដល់ចុងឆ្នាំ១៩៧៨ខ្ញុំក៏ត្រូវបានបញ្ជូនទៅខេត្តពោធិ៍សាត់។ អ្នកភូមិទឹកថ្លាភាគច្រើនដែលមានបងប្អូនសាច់ញាតិជាយោធា ក៏ត្រូវបានបញ្ជូនទៅខេត្តពោធិ៍សាត់ដែរ ដោយអង្គការប្រាប់ថាទៅរស់នៅដីខ្សាញ់ ប៉ុន្តែតាមពិតប្រជាជនទាំងនេះត្រូវបានចោទប្រកាន់ថា «ក្បាលយួនខ្លួនខ្មែរ»។ ខ្ញុំបានទៅជាមួយអ្នកភូមិផ្សេងទៀតដែរ។ ខ្ញុំត្រូវបានចាត់តាំងជាប្រធានក្រុមមើលការខុសត្រូវប្រជាជនប្រមាណជា១០០នាក់ ដែលត្រូវបញ្ជូនទៅខេត្តពោធិ៍សាត់។ អ្នកភូមិត្រូវបានបញ្ជូនទៅព្រៃកខ្សាយដើម្បីជិះកាណូតបន្តទៀត។ ខ្ញុំឃើញប្រជាជនរាប់ពាន់នាក់ទៅឈប់នៅច្បារអំពៅ ហើយអ្នកខ្លះទៀតឈប់នៅផ្សារថ្មី។ ខ្មែរក្រហមបានប្រើវិធីសាស្ត្រឃោសនាប្រាប់ប្រជាជនឲ្យជឿទុកចិត្ត គឺប្រជាជនទាំងអស់មានការផ្គត់ផ្គង់ មានបាយហូប, កន្លែងស្នាក់នៅ,ថ្នាំពេទ្យ និងមានខោអាវស្លៀកពាក់សមរម្យ។ខ្ញុំបានស្នាក់នៅភ្នំពេញរយៈពេល៣ថ្ងៃ ក៏បន្តដំណើរតាមរថភ្លើងទៅកាន់ខេត្តពោធិ៍សាត់។ ខ្ញុំ និងប្រជាជនផ្សេងទៀតទៅឈប់នៅម៉ុំអូរតាប៉ោងស្ថិតនៅឃុំអូរតាប៉ោងស្រុកបាកាន។បន្ទាប់មកខ្មែរក្រហមបានបញ្ជូនខ្ញុំទៅត្រពាំងជង, បត់គគីរ, ឃ្លោកទោល, បាក់ចិញ្ចៀនក្នុងស្រុកភ្នំក្រវាញ។នៅពេលយប់ខ្មែរក្រហមបានរាប់មនុស្សដើម្បីយកទៅសម្លាប់ដោយរាប់ចំនួន ១,២,៣ រហូតដល់គ្រប់ចំនួនដែលត្រូវសម្លាប់ទើបឈប់រាប់។ នៅក្នុងមួយយប់ប្រជាជនដែលត្រូវបានយកទៅសម្លាប់យ៉ាងតិចណាស់ចំនួន១០០នាក់។ ប្រជាជនភាគច្រើនដែលបានបញ្ជូនទៅខេត្តពោធិ៍សាត់ ភាគច្រើនមកពីខេត្តព្រៃវែង ស្វាយរៀង និងខេត្តតាកែវ។

នៅឆ្នាំ១៩៧៩ ខ្ញុំបានធ្វើដំណើរត្រឡប់មកភ្នំពេញវិញ ដោយបានចំណាយរយៈពេល២៨ថ្ងៃ។ ខ្ញុំរស់នៅទីក្រុងភ្នំពេញបានរយៈពេល២ខែប៉ុន្តែដោយសារខ្ញុំនឹកស្រណោះស្រុកកំណើតខ្លាំងក៏ត្រឡប់មកវិញ។ ការធ្វើដំណើររបស់ខ្ញុំពីភ្នំពេញត្រឡប់មកខេត្តព្រៃវែង ចំណាយពេល៣ថ្ងៃ។ មកដល់ស្រុកកំណើតទើបខ្ញុំដឹងព័ត៌មានថា ឪពុករបស់ខ្ញុំស្លាប់នៅក្នុងរបបខ្មែរក្រហម ដោយសារមានជំងឺ គ្មានថ្នាំព្យាបាល។ បីឆ្នាំក្រោយមកម្តាយរបស់ខ្ញុំក៏បានស្លាប់ទៀត។ ចំណែកប្អូនប្រុសពៅរបស់ខ្ញុំឈ្មោះ ប៊ឹម ប៊ិន និងបងថ្លៃឈ្មោះ ហូ ស៊ូ ដែលជាអតីតយោធាខ្មែរក្រហមក៏ស្លាប់ដែរ។ ក្រោយមកខ្ញុំបានចូលបម្រើការងារនៅអង្គការស្បៀងអាហារ ពិភពលោក បន្ទាប់មកខ្ញុំក៏បានជាប់ជាសមាជិកក្រុមប្រឹក្សាឃុំទឹកថ្លារហូតដល់សព្វថ្ងៃ។ **ដារ៉ារដ្ឋ មេត្តា**

# ទស្សនៈយល់ឃើញរបស់ខ្ញុំអំពីអត្ថន័យ ឃ្លាន នៅក្នុងរបបខ្មែរក្រហម

«ឃ្លាន» ត្រូវបានសម្តេចសង្ឃរាជជួនណាតឲ្យនិយមន័យថា «ចង់បរិភោគអាហារ»។ ពាក្យ «ឃ្លាន» នេះត្រូវបានមនុស្សគ្រប់គ្នានិយាយរហូតមកមិនថា ក្មេង ចាស់ ប្រុសស្រីឡើយ រាល់ពេលដែលអ្នកទាំងអស់នោះចង់បរិភោគអាហារណាមួយដើម្បីតម្រូវការក្រពះ។ វាមិនខុសទេគ្រាន់តែនិយាយពាក្យថាឃ្លាន លើសពីនេះអ្វីដែលមិនខុសនោះគឺបរិភោគអាហារតាមចំណង់ចំណូលចិត្ត ដោយសមស្របតាមលទ្ធភាពរបស់យើងមានព្រោះជីវិតមនុស្សគ្រប់រូបត្រូវការបរិភោគជាចាំបាច់។ វាអាចជាកំហុសប្រសិនបើយើងមិនបរិភោគអាហាររាល់ពេលយើងឃ្លាន ព្រោះថាសារពាង្គកាយ ឬកោសិកាអាចធ្វើចលនាបានល្អគឺអាស្រ័យលើការ បរិភោគគ្រប់គ្រាន់និងមានជីវជាតិល្អ។

យើងអាចដឹងថា ក្នុងចន្លោះឆ្នាំ១៩៧៥ - ១៩៧៩ បញ្ហាអត់ឃ្លានបានកើតឡើងចំពោះប្រជាជនខ្មែរ។ បើនិយាយអំពីពេលវេលាអតីតកាលមួយនេះប្រជាជនខ្មែរស្ទើរតែទាំងអស់គឺបានដឹង និងចងចាំជានិច្ច ពិសេសប្រជាជនធ្លាប់ឆ្លងកាត់ប្រវត្តិសាស្ត្រដ៏ជូរចត់មួយនេះ។ បីឆ្នាំប្រាំបីខែម្ភៃថ្ងៃ គឺជាពេលដែលរបបកុម្មុយនីស្តកម្ពុជា ឬខ្មែរក្រហមបានឡើងកាន់អំណាចនៅក្នុងប្រទេសខ្មែរ ហើយវាក៏ជាពេលមួយដែលប្រជាជនជួបបញ្ហាអត់ឃ្លានយ៉ាងធ្ងន់ធ្ងរបំផុត។



កងកុមារហូបបាយរួម បន្ទាប់ពីធ្វើពលកម្មនៅតាមការដ្ឋានការងារ នៅឆ្នាំ១៩៧៨

ខ្មែរក្រហមបានរំលោភសិទ្ធិ និងបញ្ជាឲ្យប្រជាជនធ្វើការនៅតាមវាលស្រែក្រោមភ្លៀង និងកម្តៅថ្ងៃ។ ប្រជាជនបានប្រើប្រាស់កម្លាំងធ្វើការស្ទើរតែដើរលែងរួចដើម្បីទទួលបានរបបអាហារសម្រាប់ខ្លួន និងគ្រួសារ ប៉ុន្តែរបបអាហារដែលប្រជាជនទទួល។ ក្នុងមួយថ្ងៃប្រជាជនទទួលបានរបបត្រឹមតែបបរមួយចានក្នុងមួយពេល ដែលសម្បូរទៅដោយទឹកច្រើនជាងកាកបាយប៉ុណ្ណោះ។ នៅពេលខ្លះទៀត ប្រជាជនស្ទើរតែគ្មានទឹកសម្រាប់ផឹកនៅពេលធ្វើការនៅតាមការដ្ឋាន។

យើងសាកស្រមៃថា តើមានរឿងអ្វីកើតឡើងនាពេលនោះ? បញ្ហាគ្មានអាហារបរិភោគបានប៉ះពាល់យ៉ាងខ្លាំងដល់សារពាង្គកាយ និងអារម្មណ៍ដូច្នេះប្រជាជនចាប់ផ្តើមហ៊ានធ្វើអ្វីៗគ្រប់យ៉ាង ដើម្បីធ្វើឲ្យជីវិតរបស់ខ្លួនបន្តរស់ទៅមុខទៀតទោះបីមានពេលខ្លះអាចឈានដល់ការបាត់បង់ជីវិតរបស់ខ្លួន។ ប្រជាជនមួយចំនួនធ្លាប់តែជាមនុស្សដែលស្មោះត្រង់ និងមានក្រមសីលធម៌ នៅក្នុងខ្លួនបានប្រែក្លាយជាមនុស្សចេះលួចលាក់ និងចេះនិយាយកុហក ហើយពេលខ្លះប្រែទៅជាកាចសាហាវក៏ព្រោះតែបំពេញតម្រូវការក្រពះ ជាចាំបាច់។ប្រជាជនភាគច្រើនដែលបានឆ្លងកាត់របប ដ៏ឃោរឃៅនេះសុទ្ធតែធ្លាប់លួចលាក់នូវចំណីអាហារបន្តិចបន្តួចមកបរិភោគបន្ថែម ព្រោះមិនអាចទ្រាំបាននូវការស្រេកឃ្លានបាន។ យើងក៏អាចសួរខ្លួនឯងថាប្រសិនបើស្ថិតនៅក្នុងកាលៈទេសៈមិនមានអាហារបរិភោគ តើយើងដោះស្រាយយ៉ាងណា? វាអាចជាកំហុសរបស់យើងចំពោះការមិនគោរពវិន័យរបស់ ខ្មែរក្រហមប៉ុន្តែវាកាន់តែខុសថែមទៀតព្រោះថា យើងបានក្បត់នូវក្រពះដែលកំពុងស្រេកឃ្លានអាហាររបស់យើង។

ប្រជាជនដែលបានរស់នៅ ក្នុងរបបខ្មែរក្រហមបានឆ្លងកាត់នូវរឿងរ៉ាវផ្សេងៗគ្នា ប៉ុន្តែមានរឿងមួយ ដែលដូចគ្នាគឺការហូបមិនគ្រប់គ្រាន់ និងភាពអត់ឃ្លាន ហើយដែលរឿងរ៉ាវទាំងនេះស្ថិតនៅក្នុងការចងចាំរបស់ប្រជាជនរហូតមកដល់សព្វថ្ងៃ។

លោកតា ឈឹន ឆួយ មានអាយុ៧២ឆ្នាំ រស់នៅភូមិស្រះខាងកើតឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះខេត្តបន្ទាយមានជ័យបានរៀបរាប់ថា« នៅពេលដែលខ្ញុំត្រូវបានបញ្ជូនឲ្យទៅកាប់ដើមពពេល ខ្ញុំបានឃើញក្មេងប្រុសអាយុ៦ឬ៧ឆ្នាំម្នាក់បានដើរទៅដកដំឡូងយកមកដុត ដើម្បីបរិភោគ។ នៅពេលនោះ មានបុរសយាមចម្ការចំណាស់ម្នាក់ដែលមាន



រូបទី១រាប់ពីស្តាំ ឃិន សិលា, ហូ ថុនា បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជារួមទាំង និស្សិតប្រវត្តិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ចុះសម្ភាសន៍ប្រជាជនពីរបបខ្មែរក្រហមនៅឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

ដងខ្លួនពេញទៅដោយសាក់ និងមានសម្បុរខ្មៅដែលមើលទៅហាក់ដូចជាមិនមែនមនុស្ស បានមកចាប់ចងក្មេងប្រុសនោះដាក់នៅនឹងគល់ឈើងាប់មានកម្ពស់ ត្រឹមចង្កេះមនុស្សចាស់និងពេញទៅដោយ ស្រមោចក្រហមឬស្រមោចភ្លើង។ បុរសយាមចម្ការនោះបានដាក់ឲ្យស្រមោចខាំក្មេងនោះពេញខ្លួន។ បន្ទាប់មកបុរសនោះបានស្រាយយកក្មេងនោះចេញ និងបានទាត់ក្មេងនោះពីរបីដងដើងពេញទំហឹង។ បណ្តាលឲ្យក្មេងនោះដួលបួនប្រាំត្រឡប់ ប៉ុន្តែក្មេងនោះមិនបានយំឡើយ។ «ដោយសារតែឃ្លានស្រេកឃ្លានខ្លាំង និងអស់កម្លាំងខ្លាំងពេក ឪពុករបស់ខ្ញុំបានដេកនៅលើគ្រែ។ គាត់បានយកកំបិតមកឆ្កឹះយកសាច់ដូងដែលទុកចោលមកហូប ប៉ុន្តែដោយសារតែគាត់គ្មានអាហារហូបច្រើនថ្ងៃមកហើយ ក៏បណ្តាលឲ្យគាត់ស្លាប់នៅលើគ្រែបន្ទាប់ពីហូបដូងរួច ដោយមានទាំងកាំបិតនៅលើទ្រូងរបស់គាត់»។ សារ៉េត បានបន្ថែមថា «ខ្ញុំរស់បានមកដល់សព្វថ្ងៃនេះគឺដោយសារតែហូប ត្រួយដំឡូងហើយ ពេលខ្លះខ្ញុំមានមើមដំឡូងមីមួយមើម ខ្ញុំសឹងថា មិនហ៊ានលេប



លោកតា ឈឹន ឆួយ មានអាយុ៧២ឆ្នាំ រស់នៅភូមិស្រែះខាងកើត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ



ពេញ សារ៉េត មានអាយុ៥៨ឆ្នាំ រស់នៅភូមិស្រែះខាងកើត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

ពេលឃើញបែបនេះ ខ្ញុំមិនហ៊ាននិយាយឡើយ ហើយខ្ញុំក៏ដើរចេញទៅព្រោះថាអាណិតក្មេង។ ខ្ញុំគិតក្មេងនោះប្រហែលជាមិនរស់។ដោយសារ ស្រេកឃ្លានក្មេងនោះហ៊ានប្រថុយជីវិតទៅដកដំឡូង។

ពេញ សារ៉េត មានអាយុ៥៨ឆ្នាំ រស់នៅភូមិស្រែះខាងកើតឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះខេត្តបន្ទាយមានជ័យបានរៀបរាប់សាច់រឿងឪពុករបស់គាត់ទាំងទឹកភ្នែកថា ចូលក្នុងពោះផង»។

ភាពអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម បានបណ្តាលឲ្យប្រជាជនរងទុក្ខវេទនានិងស្លាប់អស់ជាច្រើន។ រឿងរ៉ាវនៃភាពអត់ឃ្លាននៅតែដក់ជាប់នៅក្នុងចិត្ត របស់ប្រជាជនដែលធ្លាប់ឆ្លងកាត់របបនេះ និងត្រូវបានលើកយកមកនិយាយរហូតដល់ពេលបច្ចុប្បន្ន។

**ឃិន សិលា**

# រឿងរ៉ាវរបស់ ពុត សុផល ជនជាតិជង រស់នៅស្រុកវាលវែង ខេត្តពោធិ៍សាត់

ជនជាតិជងគឺជាជនជាតិ ភាគតិច របស់ខ្មែរដែលរស់នៅតាមព្រៃភ្នំ ក្នុងស្រុកវាល វែងស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា។ ជនជាតិជងបានរស់នៅជា កុលសម្ព័ន្ធមានមេស្រុម (ព្រឹទ្ធាចារ្យក្នុងភូមិ) ដឹកនាំនិងមានជំនឿទៅលើធម្មជាតិខ្យល់ផ្គររន្ទះអារក្សអ្នកតាម្ចាស់ទឹកម្ចាស់ដី ព្រៃភ្នំព្រលឹងដូនតាជាដើម។ជនជាតិជងមានជំនឿអរូបីយផ្សេងៗដូចជាមុនពេលដែលក្រុមរបស់គាត់ ចូលទៅក្នុងព្រៃរកខ្លឹមឈើឬរកជ័រវេន្តម្តងៗក្រុមរបស់គាត់តែងតែអញ្ជើញមេស្រុមម្នាក់



ពុត សុផល កំពុងអង្គុយនៅក្រោមផ្ទះរបស់គាត់

មកជួយរៀបចំពិធីសែនព្រេនដើម្បីសុំអនុញ្ញាតពីម្ចាស់ទឹកដីព្រៃ ភ្នំឲ្យតាមថែរក្សាបញ្ចៀសសត្វសាហាវរកជ័រនិងខ្លឹមឲ្យបានច្រើន។

ពុត សុផល គឺជាជនជាតិជង រស់នៅឃុំ អូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់ បានរៀបរាប់ថាកាលខ្ញុំមានអាយុប្រហែលជា១០ឆ្នាំ មានខ្លាមួយក្បាលបានចូលមកភូមិរបស់ខ្ញុំនិងបានលាក់ខ្លួននៅក្រោមទ្រើងល្ពៅ និងននោងៗនៅពេលយាយរបស់ខ្ញុំទៅបេះស្លឹកគ្រៃនៅក្រោយផ្ទះសត្វខ្លានោះក៏ហក់មកស្រគ្រប់ខាំយាយខ្ញុំស្លាប់និងបានពាំសាកសពរបស់យាយខ្ញុំទៅបាត់។ នៅពេលដែលតារបស់ ខ្ញុំត្រឡប់មកពីធ្វើចម្ការវិញមិនឃើញយាយរបស់ខ្ញុំ ក៏តាមរករហូតឃើញសាកសព។ចំណែកសត្វខ្លាពេលឃើញ តារបស់ខ្ញុំទៅដល់ក៏រត់ចូលទៅក្នុងព្រៃបាត់។ លោកតា បានយកសពរបស់យាយមកផ្ទះវិញ។ខ្ញុំនៅចាំបានថានៅក្នុងភូមិរបស់ខ្ញុំមានព្រឹទ្ធាចារ្យម្នាក់បានចេះមន្តអាគមនិងខ្លាំងពូកែ ប៉ុន្តែនៅពេលដែលមានហេតុការណ៍ខ្លាចូលមកខាំយាយរបស់ខ្ញុំ គាត់មិនបាននៅក្នុងភូមិទេគឺគាត់ទៅធ្វើចម្ការនៅលើភ្នំ។ តារបស់ខ្ញុំបានទៅអញ្ជើញគ្រូមន្តអាគមនោះមកចូលរួមបុណ្យប៉ុន្តែគ្រូមន្តអាគមនោះត្រូវធ្វើដំណើររយៈ៣ ថ្ងៃទើបមកដល់ភូមិ។គ្រូមន្តអាគមនោះអាចមានសមត្ថភាពហៅឈ្មោះ សត្វខ្លាទាំងអស់នៅក្នុងព្រៃ ប៉ុន្តែពេលនោះគាត់ ហៅយ៉ាងណាក៏ដោយក៏មិនឃើញសត្វខ្លានោះចេញពីព្រៃមកដែរ។ ក្រោយមកមានព្រះសង្ឃមួយអង្គដែលមកចូលរួមពិធីបុណ្យដែរ មានសង្ឃដីកាថាអាត្មាឃើញសត្វខ្លាមួយកាលពីប៉ុន្មានថ្ងៃមុន ចូលមកក្នុងវត្តហើយអាត្មាក៏បានដេញសត្វខ្លានោះទៅវិញ។ សត្វខ្លានោះបានហែលឆ្លងទៅស្ទឹងម្ខាងទៀត។ក្រោយមកទើបតារបស់ខ្ញុំបានដឹង

ថាខ្លានោះបានរួចទ្រុងពីប្រទេសថៃមកចូលដីខ្មែរ។ពេលនោះគ្រូមន្តអាគមក៏ចាប់ផ្តើមហៅឈ្មោះសត្វខ្លាម្តងទៀត។ បន្តិចក្រោយមកខ្លានោះក៏ដើរចេញពីក្នុងព្រៃ ដែលធ្វើឲ្យអ្នកភូមិមានការភ័យខ្លាចគ្រប់គ្នានិងនាំគ្នារៀបចំអន្ទាក់ ដើម្បីចាប់សត្វខ្លានោះសម្លាប់ចោល។ ដោយសារខ្ញុំឃើញហេតុការណ៍ជាក់ស្តែងដូច្នេះទើបខ្ញុំជឿទៅលើចាស់ៗនៅក្នុងភូមិដែលចេះមន្តអាគមប៉ុន្តែបច្ចុប្បន្ន មិនមានអ្នកចេះវិជ្ជាមន្តអាគមនេះទៀតទេ។ ជំនឿមួយចំនួនក៏សាបរលាបទៅដែរព្រោះចាស់ៗខ្លាមិនខាំដែរ។ រឿងរ៉ាវនេះបានកើតឡើងបន្ទាប់ពីរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩ ដោយក្រុមរបស់ខ្ញុំមានសមាជិក៣នាក់ចងអង្រឹងដេកក្រោមដើមឈើមួយដើម។ពេលខ្ញុំនិងមិត្តម្នាក់ទៀតកំពុងដេក ខ្ញុំបានឮសំឡេងមិត្តម្នាក់ទៀតធាក់អង្រឹងនិងស្រែកតិចៗប៉ុន្តែខ្ញុំមិនបានចាប់អារម្មណ៍ឡើយ។មួយរយៈក្រោយមកខ្ញុំ ភ្ញាក់និងងាកទៅមើលអង្រឹងមិត្តភក្តិម្នាក់នោះ ស្រាប់តែឃើញរហែក។ ខ្ញុំក៏បាននិយាយទៅកាន់មិត្តភក្តិនោះថា«យី!អានេះធ្វើអីបានជារហែកអង្រឹង ស្រាប់តែខ្ញុំក្



ផ្ទះប្រជាជនក្នុងស្រុកវាលវែង

ពីជំនាន់មុនមិនបានបង្រៀន វិជ្ជាមន្តអាគមនេះដល់កូនចៅជំនាន់ក្រោយឡើយ។

ជនជាតិជងកាលពីសម័យ មុនមានជំនឿទៅលើអ្នកតានិងនិស្ស័យរបស់មនុស្សបើមនុស្សណាត្រូវ អស់ជីវិតដោយសារសត្វខ្លាខាំទោះគេចទៅណា ក៏ខ្លាតាមទៅស៊ីបានប៉ុន្តែបើមិនទាន់អស់ជីវិតទេទោះ ជាអ្នកនោះដេកកណ្តាលព្រៃក៏រោកដើរទៅមើលឃើញឈាមហូរចេញពីក្នុង អង្រឹងនិងឃើញស្នាមជើងខ្លាខាំអូសមិត្តភក្តិរបស់ខ្ញុំ ចូលទៅក្នុងព្រៃ។ ខ្ញុំបានតាមទៅរកមើលមិត្តភក្តិរបស់ខ្ញុំ តែមិត្តម្នាក់នោះស្លាប់បាត់បង់ជីវិតទៅហើយ»។

ជនជាតិជងនៅក្នុងភូមិកំណើតរបស់ខ្ញុំ ត្រូវខ្មែរក្រហមជម្លៀសទៅនៅដីផាតក្នុងស្រុកថ្មបាំងខេត្តកោះកុងចំណែក

ប្រជាជនដែលជម្លៀសមកពីភ្នំពេញក៏ទៅរស់នៅទីនោះដែរ។ ទាំងប្រជាជនថ្មីនិងអ្នកមូលដ្ឋានរស់នៅជុំគ្នា។ នៅទីនោះមានការខ្វះខាតស្រូវអង្ករនិងអាហារសម្រាប់បរិភោគ យ៉ាងខ្លាំង ហើយក៏មានការយកមនុស្សទៅសម្លាប់ដែរ ដោយខ្មែរក្រហមចោទប្រកាន់ថាជាភ្នាក់ងារសេ.អ៊ី.អា ដែលភាគច្រើនគឺជាប្រជាជនថ្មីៗខ្មែរក្រហមបាន ជ្រើសអ្នកមូលដ្ឋានឲ្យធ្វើពេទ្យ ឈ្លបឬប្រធានសហករណ៍ ហើយខ្មែរក្រហមក៏មិនសូវតឹងរឹងចំពោះអ្នកទាំងនេះដែរ។នៅពេលកងទ័ពវៀតណាមវាយចូលមកក្រុមគ្រួសារខ្ញុំបានត្រឡប់មកភូមិកំណើតវិញ។ពេលនោះ អ្នកភូមិបានដណ្តើមយកស្រូវ ដែលខ្មែរក្រហមបានប្រមូលចខ្លួនចូលទៅក្នុងព្រៃដោយ មិនមានគោលដៅច្បាស់ឡើយ។ ចំណែកប្រជាជនខ្លះទៀតបាន រត់ទៅដល់ព្រំដែនថៃនិងបានចូលទៅរស់នៅក្នុងជំរំ។

នៅឆ្នាំ១៩៨១ទើបមានការ បើកផ្សារលក់ដូរទំនិញនៅតាមព្រំដែនខ្មែរ-ថៃហើយជនជាតិជង ដែលរកជ័ររង្គនិងខ្លឹមឈើបានក៏បាន យកទៅលក់ឲ្យឈ្មួញថៃ។ ជ័ររង្គគឺជាជ័រដែលមានសណ្ឋានរាវដូចជ័រកៅស៊ូប៉ុន្តែមានពណ៌លឿង។ជនជាតិជងចៀរដើមរង្គឲ្យហូរជ័រ បន្ទាប់មកត្រងយកទៅរម្ងាស់និងកូររហូតដល់ខះរឹងទើប យកមកចាក់ក្នុងពុម្ពជាដុំៗ។ ជនជាតិជងបានប្រមូលជ័ររង្គដាក់ក្នុងបាវរួចស្ពាយយកទៅលក់




ផ្លូវលំក្នុងឃុំអូសោម ស្រុកវាលវែង

ទុកនៅក្នុងជម្រុកនៅតាម សហករណ៍ផ្សេងៗប្រជាជននៅក្នុងភូមិរបស់ខ្ញុំខ្លះបានស្លាប់ ដោយសារអត់បាយ។ពេលមកដល់ភូមិដំបូងប្រជាជនបានដើរដឹកដំឡូងព្រៃនិងមើមក្តួចមកហូបបន្ថែមទៀត។ ទោះបីយ៉ាងណា នៅក្រោយឆ្នាំ១៩៧៩តំបន់របស់ខ្ញុំរស់នៅមិនទាន់មាន សន្តិភាពទេគឺនៅពេលកងទ័ពវៀតណាមជួបប្រទះយោធាខ្មែរក្រហម ដែលរស់នៅក្នុងព្រៃម្តងៗការប្រយុទ្ធគ្នា ក៏ចាប់ផ្តើមផ្ទុះឡើងធ្វើឲ្យប្រជាជនរត់គេឲ្យឈ្មួញថៃដោយក្នុងមួយគីឡូក្រាមលក់បានតម្លៃ៨០០បាត។ជនជាតិជងបានយកប្រាក់ទាំងនោះ ទៅទិញអំបិល ស្ករប្រហុក យកមកផ្ទះវិញ។ ជនជាតិជងអាចរកជ័ររង្គនៅរដូវដែលមានធ្លាក់ភ្លៀងធ្លាក់ច្រើន។ ក្រៅពីចៀរជ័ររង្គជនជាតិជងបានដើររកខ្លឹមឈើដាំស្រូវដាំដំណាំ ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។

**រី លក្ខិណា**

# គម្រោងប្រកួតជ្រើសរើសស្នាដៃតែងនិពន្ធរឿងខ្លីពានរង្វាន់អក្សរសិល្ប៍ស្ទឹករីតលើកទី១ ឆ្នាំ២០២០

សមាគមអ្នកនិពន្ធខ្មែរ គឺជាសមាគមជាតិ ឯករាជ្យ បង្កើតឡើងនៅថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៥៦។ ក្រោយសង្គ្រាមស៊ីវិលប្រល័យពូជសាសន៍ បីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃសមាគមនេះបានបង្កើតឡើងវិញនៅឆ្នាំ១៩៩៣ដោយបានសុំច្បាប់ពីព្រះករុណាអង្គម្ចាស់ជីវិតលើត្បូង ក្នុងឋានៈព្រះអង្គជាព្រះប្រធានឧត្តមក្រុមប្រឹក្សាជាតិ និងបានសុំច្បាប់ពីរដ្ឋអំណាច “រដ្ឋកម្ពុជា”។បន្ទាប់មកតាមសេចក្តីស្នើសុំពីគណៈកម្មាធិការកណ្តាលនៃសមាគមអ្នកនិពន្ធខ្មែរ សម្តេចព្រះបាទ នរោត្តម សីហនុ ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ គង់ប្រថាប់ជាព្រះប្រធានកិត្តិយសនៃសមាគម អ្នកនិពន្ធខ្មែរឡើងវិញដូចកាលពីសម័យសង្គមរាស្ត្រនិយម។ ពីឆ្នាំ១៩៩៤ រហូតដល់ចុងឆ្នាំ១៩៩៦សមាគមអ្នកនិពន្ធខ្មែរ ដែលទើបនឹងរស់រានមានជីវិតឡើងវិញជាថ្មី គឺដឹកនាំដោយសាស្ត្រាចារ្យ យូ បូ ដែលមានទីស្នាក់កណ្តាលក្នុងបរិវេណវត្តបទុមវតីវិថីឧកញ៉ាស៊ូស្រ៊ុន៧ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

នៅចុងឆ្នាំ២០១៧ សមាគមអ្នកនិពន្ធខ្មែរបានផ្តើមហាសន្និបាត របស់ខ្លួនជ្រើសរើសថ្នាក់ដឹកនាំថ្មីដើម្បីដំណើរការ និងចុះបញ្ជីសមាគមអ្នកនិពន្ធខ្មែរក្នុងបញ្ជីអង្គការសមាគមនៃក្រសួងមហាផ្ទៃនៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៨។ ក្នុងអាណត្តិទី១០សមាគមអ្នកនិពន្ធខ្មែរ ដឹកនាំដោយ ឯកឧត្តមព្រឿងប្រណីត កំពុងមានសកម្មភាពបណ្តុះបណ្តាលសិក្ខាកាមអ្នកនិពន្ធជំនាន់ថ្មីជាបន្តបន្ទាប់។ ក្រៅពីនេះទៀតសមាគមមានការប្រកួតស្នាដៃ ពានរង្វាន់អក្សរសិល្ប៍ ទន្លេមេគង្គនិងជ្រើសរើសអ្នកនិពន្ធឆ្នើម ទៅទទួលពានរង្វាន់អាស៊ីអាគ្នេយ៍ជារៀងរាល់ឆ្នាំ។ ជាងនេះទៅទៀត សមាគមអ្នកនិពន្ធខ្មែរបានចូលរួមជាគណៈកម្មការវាយតម្លៃ ស្នាដៃនិពន្ធ ក្នុងការប្រកួតជ្រើសរើសស្នាដៃនៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងធម្មការ និងសាសនា និងសហការជាមួយសមាគមអ្ននិពន្ធខ្មែរនៅបរទេសប្រចាំប្រទេសបារាំង ប្រកួតពានរង្វាន់អក្សរសិល្ប៍សន្តិភាពផងដែរ។

ដើម្បីសម្រេចទៅតាមទស្សនវិស័យរួមគឺ ការតែងនិពន្ធស្រាវជ្រាវបោះពុម្ពនិងនវានុវត្តន៍ ប្រកបដោយគុណភាពឧត្តមភាពលើកកម្ពស់វិស័យតែងនិពន្ធនៅកម្ពុជា សមាគមអ្នកនិពន្ធខ្មែរកំពុងស្វែងរកដៃគូសហការជាមួយស្ថាប័នផ្សេងៗដែលមានគោលបំណងរួម ក្នុងការលើកស្ទួយគាំទ្រការស្រាវជ្រាវនិងវិស័យតែងនិពន្ធ។ ដោយយល់ឃើញថាមជ្ឈមណ្ឌលឯកសារកម្ពុជា មានគោលបំណងចូលរួមក្នុងការលើកស្ទួយ គាំទ្រការស្រាវជ្រាវនិងវិស័យតែងនិពន្ធសមាគមអ្នកនិពន្ធខ្មែរបានសហការជាមួយ មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីរៀបចំការប្រកួតជ្រើសរើសស្នាដៃ ពានរង្វាន់រឿងខ្លីអំពីជីវិតរស់នៅប្រចាំថ្ងៃ របស់ប្រជាជនកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត។

ការបង្កើតគម្រោងប្រកួតជ្រើសរើសស្នាដៃ តែងនិពន្ធរឿងខ្លីពានរង្វាន់អក្សរសិល្ប៍ស្ទឹករីត លើកទី១ឆ្នាំ២០២០នេះឡើងក្នុងគោលបំណង១)ដើម្បីលើកកម្ពស់ការស្រាវជ្រាវនិពន្ធអំពីជីវិតរស់នៅប្រចាំថ្ងៃ របស់ប្រជាជនកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យប៉ុលពត។ ២)ដើម្បីរួមចំណែករក្សាឯកសារប្រវត្តិសាស្ត្រ នៃជីវិតមនុស្សជាតិរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត តាមរយៈស្នាដៃតែងនិពន្ធរបស់អ្នកនិពន្ធខ្មែរអ្នក ដែលរស់រានមានជីវិត និងអ្នកដែលធ្លាប់បានឮរឿងរ៉ាវ ដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត។ **សមាគមអ្នកនិពន្ធខ្មែរ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមអ្នកនិពន្ធខ្មែរ
Khmer Writers Association
លេខ...៣០/១៩...ស.អ.ខ.

# សេចក្តីជូនដំណឹង
## ការប្រកួតជ្រើសរើសស្នាដៃតែងនិពន្ធរឿងខ្លី ពានរង្វាន់អក្សរសិល្ប៍ស្លឹករឹត លើកទី១ ឆ្នាំ២០២០

## សមាគមអ្នកនិពន្ធខ្មែរ

សូមប្រគេន ជម្រាបជូនដំណឹងដល់សមាជិក សមាជិកានៃសមាគមអ្នកនិពន្ធខ្មែរ និងសាធារណជនទូទៅមេត្តាជ្រាបថា ក្នុងគោលបំណងរួមចំណែកថែរក្សាឯកសារប្រវត្តិសាស្ត្រនៃជីវិតរស់នៅរបស់ប្រជាជនខ្មែរក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត តាមរយៈស្នាដៃតែងនិពន្ធ និងដើម្បីលើកស្ទួយតម្លៃអក្សរសាស្ត្រជាតិខ្មែរ។ សមាគមអ្នកនិពន្ធខ្មែរសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំប្រកួតជ្រើសរើសស្នាដៃតែងនិពន្ធរឿងខ្លី **"ពានរង្វាន់អក្សរសិល្ប៍ស្លឹករឹត"** លើកទី១ ឆ្នាំ២០២០ ប្រធានបទ **"ជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត"**។

**លក្ខខណ្ឌនៃការជ្រើសរើសវាយតម្លៃ**

១. ខ្លឹមសាររឿងខ្លី ជាស្នាដៃនិពន្ធថ្មី ត្រូវតែនិយាយអំពីជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត ប៉ុន្តែមិនសង្កត់ទៅលើតែប្រធានបទឧក្រិដ្ឋកម្មយង់ឃ្នងកាប់សម្លាប់។
២. ចំនួនពី៥ ដល់ ១៥ទំព័រ (អត្ថបទវាយដោយកុំព្យូទ័រ ឬសំណេរដៃពី១០ ដល់២០ទំព័រ)។
៣. ក្រដាស អេ៤ ពុម្ពអក្សរ ខ្មែរ អូ.អេស សៀមរាប(Khmer OS Siemreap) ទំហំ១២ មិនដាក់ក្បាលឬជើងទំព័រ។

**បេក្ខជនដែលអាចចូលរួមប្រកួតបានគឺ**

១. អ្នកនិពន្ធ និងសាធារណជនទូទៅ ជាជនជាតិខ្មែរ ឬ បរទេស (មានសមត្ថភាពអក្សរសិល្ប៍)។
២. អ្នករស់រានមានជីវិតពីសម័យ ប៉ុល ពត និងធ្លាប់មានរឿងរ៉ាវនៅក្នុងសម័យនោះ។
៣. អ្នកឮរឿងរ៉ាវពិតដែលរៀបរាប់ឡើងវិញដោយអ្នករស់រានមានជីវិតពីសម័យ ប៉ុល ពត។

ស្នាដៃរឿងខ្លីចំនួន១០រឿង នឹងត្រូវជ្រើសរើសផ្តល់ពានរង្វាន់រួមមាន ពានកិត្តិយស វិញ្ញាបនបត្រ និងថវិកា។ ស្នាដៃដែលបានជ្រើសរើសនឹងត្រូវបោះពុម្ព និងពិចារណាផលិតជាភាពយន្តខ្លី ឬចម្រៀង។

សមាជិកសមាជិកានៃ ស.អ.ខ និងសាធារណជនទូទៅ ដែលមានបំណងចូលរួមប្រកួត សូមផ្ញើស្នាដៃមកកាន់សមាគមអ្នកនិពន្ធខ្មែរចាប់ពីថ្ងៃ១ ខែតុលា ដល់ថ្ងៃទី៣០ ខែវិច្ឆិកាឆ្នាំ២០១៩ វេលាម៉ោង ១៧.០០នាទី ជាកំណត់។

ទីកន្លែងទទួលស្នាដៃ ទីស្នាក់ការសមាគមអ្នកនិពន្ធខ្មែរ ក្នុងបរិវេណវត្តបទុមវតី រាជធានីភ្នំពេញ ឬផ្ញើតាមសារអេឡិចត្រូនិចៈ Khmerwriterkwa@gmail.com ឬទាក់ទងទូរសព្ទលេខ ០៨៩ ៨៥៦ ៧៦៤, ០១២ ៧៩២៩៥៩ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ២០១៩
ប្រធានសមាគមអ្នកនិពន្ធខ្មែរ

KHMER WRITER'S ASSOCIATION

ព្រឿង ប្រណីត

សមាគមអ្នកនិពន្ធខ្មែរ អាសយដ្ឋានៈ វត្តបទុមវតី វិថីឧកញ៉ាសួ ស្រុន ៧ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
Add: Khmer Writers Association: Wat Badum Wadey Oknha Sousrun 7, Khan Daun Penh, Phnom Penh CAMBODIA
Email: khmerwriterkwa@gmail.com FB: Khmer Writers Association, Tel: 012 792 959, 092 788 990

# ដំណឹងជ្រើសរើសនិស្សិតស្ម័គ្រចិត្ត

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវការជ្រើសរើសនិស្សិតស្ម័គ្រចិត្តចំនួន០៥រូប (អ្នកសរសេរអត្ថបទ ២រូប អ្នកបកប្រែ ២រូប និងក្រាហ្វិកកុំព្យូទ័រ ១រូប) ក្នុងចំណោមនិស្សិតសាកលវិទ្យាល័យនានាឲ្យមកបម្រើការងារចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៩ ដល់ខែមករា ឆ្នាំ២០២០ ហើយអាចបន្តទៅតាមគុណភាពការងារ។

១) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការបកប្រែអត្ថបទពីភាសាអង់គ្លេសមកជាភាសាខ្មែរ ឬពីភាសាខ្មែរទៅភាសាអង់គ្លេស។ អត្ថបទដែលនឹងត្រូវបកប្រែគឺអត្ថបទខ្លីនិងវែង ដែលមានលក្ខណៈប្រវត្តិសាស្ត្រ ច្បាប់ និងអត្ថបទពិភាក្សានានា សរសេរដោយមេធាវី សាស្ត្រាចារ្យ អ្នកស្រាវជ្រាវបរទេស ឬសរសេរ ដោយប្រជាជនកម្ពុជា។

២) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការសរសេរអត្ថបទ សម្រាប់បោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដី «ស្វែងរកការពិត» និងគេហទំព័រ http://www.khmerrougehistory.org

៣) អ្នកក្រាហ្វិកកុំព្យូទ័រ ឬរចនាទស្សនាវដ្ដី តម្រូវឲ្យចេះប្រើប្រាស់កម្មវិធី InDesign និងកម្មវិធីផ្សេងៗទៀត ដែលទាក់ទងនឹងការរចនាទស្សនាវដ្ដី។

ក្នុងអំឡុងពេលធ្វើការងារស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជា និស្សិតស្ម័គ្រចិត្តទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យដាក់ពាក្យចូលរួមវគ្គបណ្ដុះបណ្ដាល និងបន្តការសិក្សានៅតាមសាកលវិទ្យាល័យនានា ដែលជាដៃគូសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដូចជា ព្រះរាជាណាចក្រថៃ ហ្វីលីពីន ហុងកុង ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក ជាដើម។

## លក្ខខណ្ឌសម្រាប់និស្សិតដែលអាចដាក់ពាក្យបាន មានដូចខាងក្រោម ៖

១) និស្សិតកំពុងសិក្សាតាមសាកលវិទ្យាល័យរដ្ឋ និងឯកជននានា ដែលអាចប្រើប្រាស់ភាសាអង់គ្លេស។

២) មានអត្តចរិតថ្លៃថ្នូរ ម៉ឺងម៉ាត់ ព្យាយាម និងមានទំនួលខុសត្រូវចំពោះការងារ។

៣) មានចំណាប់អារម្មណ៍ផ្នែកការងារប្រវត្តិសាស្ត្រ ច្បាប់ និងសារព័ត៌មាន។

និស្សិតដែលមានលក្ខណៈសម្បត្តិដូចខាងលើ ហើយមានចំណាប់អារម្មណ៍នឹងការងារស្ម័គ្រចិត្តនេះ សូមផ្ញើពាក្យសុំបម្រើការងារមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី៣១ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង៥ល្ងាច។

## សូមភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម ៖

១) លិខិតសុំធ្វើការងារ១មួយច្បាប់ (Cover Letter) ដោយបញ្ជាក់អំពីទឹកចិត្តផ្ទាល់ខ្លួនចំពោះការងារឲ្យបានច្បាស់លាស់ និងក្បោះក្បាយ ដែលសរសេរដោយសាម៉ីខ្លួន។

២) ប្រវត្តិរូបសង្ខេប១ច្បាប់ (Resume)។

សូមផ្ញើមកកាន់អាសយដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឬ អ៊ីម៉ែល truthbunthorn.s@dccam.org។ ប្រសិនបើមានចម្ងល់ សូមទូរសព្ទមកលេខ ០២៣ ២១៨ ០០៩ ឬ ០១២ ៩៩៦ ៧៥០។

សូមអរគុណ!

# អង្គជំនុំជម្រះសាលាដំបូង
# សេចក្តីសង្ខេបសាលក្រមសំណុំរឿង០០២/០២

## *ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម*

(តចប់)

***៧១.*** *អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ជនជាប់ចោទនួនជាមានពិរុទ្ធដែលបានប្រព្រឹត្តនៅលើទឹកដីនៃប្រទេសកម្ពុជាចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥រហូតដល់ថ្ងៃទី០៦ខែមករាឆ្នាំ១៩៧៩ ដូចបានរៀបរាប់ដោយ សង្ខេបខាងលើនិងដោយលម្អិតនៅក្នុងសាលក្រមជាលាយលក្ខណ៍អក្សរតាមរយៈអំពើសកម្ម និងអសកម្មចំពោះ ខក្រិដ្ឋកម្មទាំងឡាយដូចខាងក្រោម៖*

***-ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ*** *តាមរយៈការធ្វើមនុស្សឃាតការសម្លាប់រង្គាល ការនិរទេសការធ្វើឲ្យទៅជាទាសករការដាក់ក្នុងមន្ទីរ ឃុំឃាំង ការធ្វើទារុណកម្មការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ របស់មនុស្សអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ អំពើអមនុស្សៗធម៌ផ្សេងទៀត ក្រោមទម្រង់ជាការជម្លៀសដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោម*



*កងកុមារកំពុងជីកប្រឡាយនៅក្នុងរបបខ្មែរក្រហមអំឡុងឆ្នាំ១៩៧៥-១៩៧៩*

ទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទនៅក្នុងបរិបទនៃ ការរៀបអាពាហ៍ពិពាហ៍ ដោយបង្ខំ អនុលោមតាមបទបញ្ញត្តិមាត្រា៥មាត្រា២៩(ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក.។

- ***ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ*** តាមរយៈ ការ ធ្វើមនុស្សឃាត ដោយចេតនាការធ្វើទារុណកម្មការធ្វើបាប ដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួ ស ធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ ដល់រាងកាយឬសុខភាព ការដកហូតដោយចេតនា ពីឈ្លើយសឹក ឬជនស៊ីវិលដោយខុសច្បាប់អនុលោមតាមមាត្រា៦ មាត្រា២៩(ថ្មី)និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក.។

***ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍***តាមរយៈការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជនជាតិវៀតណាមនិងជនជាតិចាមអនុលោមតាមមាត្រា៤មាត្រា២៩(ថ្មី)និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក.។

***៧២.*** អង្គជំនុំជម្រះសាលាដំបូងរកឃើញថាជនជាប់ចោទ ខៀវ សំផន មានពិរុទ្ធដែលបានប្រព្រឹត្តនៅលើទឹកដីនៃប្រទេសកម្ពុជាចន្លោះពី ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូត



**កងកុមារកំពុងលើកភ្លឺស្រែនៅក្នុងរបបខ្មែរក្រហមអំឡុងឆ្នាំ១៩៧៥-១៩៧៩**

ដល់ ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដូចបានរៀបរាប់ដោយសង្ខេបខាងលើនិងដោយលម្អិត នៅក្នុងសាលក្រមជាលាយលក្ខណ៍អក្សរតាមរយៈអំពើសកម្ម និងអសកម្ម ចំពោះឧក្រិដ្ឋកម្មទាំងឡាយដូចខាងក្រោម៖

-***ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ*** តាមរយៈ ការធ្វើមនុស្សឃាតការសម្លាប់រង្គាល ការនិរទេស ការធ្វើឲ្យទៅជាទាសករការដាក់ក្នុងមន្ទីរឃុំឃាំងការធ្វើទារុណកម្មការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការជម្លៀសដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗ ទៀតក្រោមទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ ដោយបង្ខំ អនុលោមតាមបទបញ្ញត្តិ មាត្រា៥ មាត្រា២៩(ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក.។

- ***ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ*** តាមរយៈការធ្វើមនុស្សឃាតដោយចេតនាការធ្វើទារុណកម្មការធ្វើបាប ដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ ដល់រាងកាយឬសុខភាពការដកហូត ដោយចេតនា ពីឈ្លើយសឹកឬជនស៊ីវិលដោយខុសច្បាប់អនុលោមតាមមាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

- ***ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍*** តាមរយៈការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជនជាតិ វៀតណាម និងជនជាតិចាមអនុលោមតាមមាត្រា៤មាត្រា២៩(ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក.។

***៧៣.*** អង្គជំនុំជម្រះរកឃើញថាជនជាប់ចោទ នួន ជា

និង ខៀវ សំផន មិនមានពិរុទ្ធចំពោះបទចោទផ្សេងទៀតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចឲ្យ ជនជាប់ចោទទាំងពីរនាក់រួចផុតពីបទចោទប្រកាន់ទាំងនេះ។

*៧៤.* អង្គជំនុំជម្រះ បានពិចារណាទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មរួមទាំងទំហំនិងភាពសាហាវព្រៃផ្សៃ ក៏ដូចជាចំនួននិងភាពទន់ខ្សោយរបស់ជនរងគ្រោះ ដែលជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធ រួមទាំងស្ថានទម្ងន់ទោស និងស្ថានសម្រាលទោសនានាដែលពាក់ព័ន្ធ។

*៧៥.* អង្គជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទ នួន ជា ដាក់ពន្ធនាគារអស់មួយជីវិត។ដោយពិចារណាទៅលើការផ្តន្ទាទោស ដាក់ពន្ធនាគារអស់មួយជីវិតចំពោះគាត់ នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះរួមបញ្ចូលគ្នានូវការផ្តន្ទាទោសទាំងពីរ ទៅជាការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតតែមួយ។

*៧៦.* អង្គជំនុំជម្រះសម្រេចផ្តន្ទាទោស ជនជាប់ចោទ ខៀវសំផនដាក់ពន្ធនាគារអស់មួយជីវិត។ដោយពិចារណាទៅលើការផ្តន្ទាទោស ដាក់ពន្ធនាគារអស់មួយជីវិតចំពោះគាត់ នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះរួមបញ្ចូលគ្នានូវការផ្តន្ទាទោសទាំងពីរ ទៅជាការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតតែមួយ។

*៧៧.* ប្រកាសថាដើមបណ្តឹងរដ្ឋប្បវេណី ដែលរួមបញ្ចូលជាក្រុមដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលជាឧបសម្ព័ន្ធ២ ពិតជាបានទទួលរងព្យសនកម្មដែលជាផលវិបាកដោយផ្ទាល់ ដែលកើតចេញពីឧក្រិដ្ឋកម្មដែលនួនជានិងខៀវសំផនត្រូវបានរកឃើញថាមានពិរុទ្ធ និងដោយអនុលោមតាមវិធាន២៣ស្ទួនបួន (១)(៣) នៃវិធានផ្ទៃក្នុងរបស់អ. វ. ត. ក. អង្គជំនុំជម្រះសម្រេចទទួលយកផ្នែកខ្លះនៃសសំណើសុំសំណងផ្លូវចិត្ត និងជាសមូហភាព ដូចមានចែងលម្អិតនៅក្នុងផ្នែកទី២ ១ នៃសាលក្រមជាលាយលក្ខណ៍អក្សរអង្គជំនុំជម្រះ សម្រេចទទួលយកនូវគម្រោងសំណងដែលមានលក្ខណៈសមស្រប និងអនុវត្តបានចំនួន១៣គម្រោងដែលទាក់ទងនឹងទិវា នៃការចងចាំចំពោះជនរងគ្រោះ និងពិធីរម្លឹកផ្សេងៗចំពោះការឈឺចាប់ដែលពួកគាត់បានទទួលរង វិធីព្យាបាលតាមរយៈការចងក្រងនូវសក្ខីកម្មនិងការព្យាបាលផ្លូវចិត្តដល់ជនរងគ្រោះ និងការតាំងពិព័រណ៍ឯកសារ និង គម្រោងអប់រំ។ អង្គជំនុំជម្រះសម្រេចបដិសេធគម្រោងសំណងដែលបានស្នើសុំចំនួន២ (មួយបដិសេធទាំងស្រុងនិងមួយទៀតបដិសេធផ្នែកខ្លះ ដែលមិនស្រប តាមលក្ខខណ្ឌតម្រូវនៃវិធាន ២៣ស្ទួនបួន(១) (៣)នៃវិធានផ្ទៃក្នុងរបស់ អ. វ.ត.ក.ដូចមានចែងលម្អិតនៅក្នុងផ្នែកទី២១ នៃសាលក្រមជាលាយលក្ខណ៍អក្សរ។

*៧៨.* សាលក្រមនេះប្រកាសជាសាធារណៈនៅក្នុងសាលសវនាការធំនៃ អ.វ.ត.ក. នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០១៨ ហើយបើកផ្លូវឲ្យភាគីប្តឹងសាទុក្ខតាមការកំណត់នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក.។

*៧៩.* អង្គជំនុំជម្រះសាលាដំបូង សូមបញ្ជាក់ថាអនុលោមតាមវិធាន១០៧(៤)នៃវិធានផ្ទៃក្នុងនិងមាត្រា ៨.៥ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខអ.វ. ត.ក.រយៈពេលកំណត់សម្រាប់ ការដាក់សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ ប្រសិនបើមាន នឹងត្រូវចាប់ផ្តើមរាប់មួយថ្ងៃបន្ទាប់នៃថ្ងៃប្រក្រតីទិន ក្រោយពីការបញ្ជូននូវការជូនដំណឹងពីសាលក្រមជាលាយលក្ខណ៍អក្សរដែលមានសំអាងហេតុពេញលេញជាភាសាខ្មែរ និងភាសាផ្លូវការណាមួយផ្សេងទៀតរបស់អ. វ. ត. ក. ដែលភាគីនីមួយៗបានជ្រើសរើសដោយអនុលោមទៅតាមមាត្រា២.២នៃសេចក្តីណែនាំអនុវត្ត។

*៨០.* លោកចៅក្រម យូរ ឧត្តរា មានមតិដោយឡែកពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលមានភ្ជាប់ជាមួយនឹងសាលក្រម។

*៨១.* អង្គជំនុំជម្រះប្រកាសបិទបញ្ចប់សវនាការលើសំណុំរឿង ០០២/០២។

***អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា***

# បដិមាអ្នកតាព្រះភក្ត្រ៨

សៀវភៅមានចំណងជើង«អំពើប្រល័យពូជសាសន៍និងការសម្លាប់រង្គាលក្នុងប្រវត្តិសាស្ត្រពិភពលោក» ជាភាសាខ្មែរ បានបញ្ជូនចូលរោងពុម្ព ដើម្បីបោះពុម្ពនៅក្នុងសប្តាហ៍នេះហើយបន្ទាប់ពី បានចំណាយរយៈពេល៤ឆ្នាំ ក្នុងការសិក្សាស្រាវជ្រាវតាមលក្ខណៈវិទ្យាសាស្ត្រ រវាងមជ្ឈមណ្ឌលឯកសារកម្ពុជានិងក្រសួង អប់រំយុវជន និងកីឡា។ សៀវភៅនេះរៀបរាប់ពីប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលនៅក្នុងប្រទេសចំនួន៥គឺ ប្រទេសអាមេនី,អាល្លឺម៉ង់,កម្ពុជា,បូស្នី-ហឺហ្សេហ្គោវីន និងរវ៉ាន់ដាដែលត្រូវបានចាត់ថ្នាក់ជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាពឧក្រិដ្ឋកម្មសង្គ្រាមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងការរំលោភបំពាន លើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។ ការបង្រៀនប្រវត្តិសាស្ត្រ ប្រទេសទាំង៥ខាងលើគឺជាឧទាហរណ៍នៃការសិក្សាប្រៀបធៀប នៅក្នុងថ្នាក់រៀនកម្ពុជាស្តីអំពីប្រវត្តិសាស្ត្រជាតិតំបន់ និងពិភពលោក ដើម្បីបង្កើនចំណេះដឹងបន្ថែម ដល់សិស្សានុសិស្ស ពីព្រឹត្តិការណ៍ពិភពលោកនាពេលអតីតកាល ក្នុងការឆ្ពោះទៅរកការអភិវឌ្ឍប្រទេសជាតិ ចៀសផុតពីប្រវត្តិសាស្ត្រប្រាំដែល។ សៀវភៅនេះនឹងធ្វើការចែកចាយដោយឥតគិតថ្លៃ ជាលើកដំបូងក្នុងខែវិច្ឆិកាឆ្នាំ២០១៩ ខាងមុខនេះ សម្រាប់សិស្សានុសិស្សកម្រិតវិទ្យាល័យ ចំនួនប្រមាណ៥០០នាក់ក្នុងរាជធានីភ្នំពេញនិងបន្តចែកចាយបន្ថែមទៀត ក្នុងខែបន្តបន្ទាប់តាម



រូបបដិមាអ្នកតាព្រះភក្ត្រ៨នៅលើក្របសៀវភៅ «អំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលក្នុងប្រវត្តិសាស្ត្រពិភពលោក»

*រយៈកម្មវិធីអប់រំមួយ ចំនួនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។*

*រូបថតក្របមុខសៀវភៅនេះគឺជាបដិមាអ្នកតាព្រះភក្ត្រ៨ស្ថិត នៅលើជម្រាលភ្នំដងរែកត្រង់ចំណុចពយតាម៉ុកជាប់នឹងទីតាំងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជាថតដោយគ្រីស្តូហ្វ័រឌៀរីង។ យោងតាមការរៀបរាប់របស់លោកប៉ុកលក្សរាសីនេះ គឺជាបដិមា មួយក្នុងចំណោមបដិមាអ្នកតាព្រះភក្ត្រ៨ ជាច្រើនអង្គដែល លោកលីស៊ុយបានកសាងឡើងចាប់តាំងពីឆ្នាំ២០០៨ មកម្ល៉េះ។ ជាពលរដ្ឋខ្មែរម្នាក់ដែលមានជំនឿលើបារមី ស័ក្តិសិទ្ធិ នៃបុព្វបុរសខ្មែរលោកលីស៊ុយបានកសាងបដិមាទាំងនេះ ដើម្បីតំណាងឲ្យមេទ័ព៨ទិសនៃសម័យអង្គរ ហើយយកមកតម្កល់តាមព្រំដែនសីមានៃប្រទេសកម្ពុជា ក្នុងជំនឿថាមហិទ្ធិឫទ្ធិនៃបុព្វបុរសខ្មែរនឹងមកជួយការពារទឹកដីខ្មែរ ឲ្យមានសន្តិភាពរួចផុតពីការឈ្លានពានរបស់ប្រទេសជិតខាង។ លោកប៉ុកលក្សរាសីបានរៀបរាប់ទៀតថាមុខទាំង៨ ដែលមានពណ៌ខុសៗគ្នាគឺតំណាងឲ្យកងទ័ពទាំង៨ ទិសដែលមានពណ៌ទង់សម្គាល់ខុសៗគ្នាហើយក៏បង្ហាញពីការឯកភាពនៃកម្លាំងពលរដ្ឋ ទោះបីជាមានជំនឿឬពណ៌សម្បុរខុសគ្នាក៏អាចរស់នៅ ជាមួយគ្នាបានដែរឲ្យតែចេះគោរពអត់ឱនឲ្យគ្នាទៅវិញទៅមក នឹងតម្កល់ផលប្រយោជន៍ជាតិជាធំៗក្នុងន័យម្យ៉ាងទៀត ព្រះភក្ត្រដែលមានពណ៌ខុសៗគ្នាទាំងនេះ អាចបញ្ជាក់អំពីអត្តចារិកល្អនិងអាក្រក់របស់មនុស្ស និងអាចបង្ហាញពីភាពខ្លាំងដែលអាចទប់ស្កាត់នូវរាល់អំពើអយុត្តិធម៌ នៅក្នុងសង្គម។ សន្តិភាពការសណ្តោសប្រណីនិងក្តីសង្ឃឹមអាច បញ្ឈប់ នូវរាល់ទម្រង់នៃភាពស្អប់ខ្ពើមអំពើហិង្សា និងភាពភ័យខ្លាចៗបដិមានេះក៏តំណាងឲ្យអ្នកដែលមានអំណាចខ្លាំងក្លា តែប្រកាន់បាននូវសុចរិតយុត្តិធម៌មិនបំពានឬ ដើរធ្វើបាបអ្នកដទៃ។សរុបមកបដិមានេះបង្ហាញថា «ការគោរពនិងអត់ឱនឲ្យគ្នានាំមកនូវសាមគ្គីជាតិឯកភាពជាតិនាំមកនូវអំណាចរឹងមាំ អំណាចសុចរិតនាំមកនូវសន្តិភាពហើយភាពសុខសាន្តនាំមកនូវវឌ្ឍនភាព»។ដាក់ស្តែងការយកមនុស្សពីទិសទាំង៨ មកដាក់ក្នុងរាងកាយតែមួយបានធ្វើឲ្យបុព្វបុរសខ្មែរ កសាងបាននូវអារ្យធម៌អង្គរដ៏ល្អអស្ចារ្យសម្រាប់មនុស្សជាតិ ហើយការបំបែកមនុស្សចេញពីរាងកាយតាមរយៈ ពណ៌សម្បុរបានធ្វើឲ្យសង្គមខ្មែរធ្លាក់ក្នុងភាពខ្មៅងងឹតបំផុតនៃប្រវត្តិសាស្រ្តមនុស្សជាតិគឺរបបប្រល័យពូជសាសន៍ឯង ខ្មែរក្រហម។*

*ប្រវត្តិសាស្រ្តបានបញ្ជាក់ថា គ្មានសង្គមណាមួយអាចគេចផុតពីអំពើអមនុស្សធម៌ ជ្រុលហួសហេតុបានឡើយ។ អំពើប្រល័យពូជសាសន៍ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ហួសប្រមាណអាចកើតមានឡើងវិញ។ ដូនកាលអំពើទាំងនេះអាចកើតមានឡើងជាបន្តបន្ទាប់ នៅក្នុងសង្គមដែលប្រកបដោយសមិទ្ធផលខ្ពស់ ក្នុងវិស័យសិល្បៈវិទ្យាសាស្រ្តនិងការសិក្សា។ក្នុងន័យនេះយើងអាចនិយាយបានថា កម្រិតនៃការយល់ដឹងអំពីវប្បធម៌ការអប់រំ ឬការពលីជីវិត ដើម្បីសម្រេចបានគោលដៅខ្ពស់ណាមួយពុំអាច ការពារមនុស្សជាតិពីទំនោរនៃការបំផ្លាញ ទាំងអស់នេះបានឡើយ។ទីបំផុតមនុស្សជាតិត្រូវប្រឈម នឹងភាពស្មុគស្មាញ នៃស្ថានភាពរបស់ខ្លួន។ សាសនា វិទ្យាសាស្រ្ត និងទស្សនវិជ្ជា ផ្តល់នូវគោលគំនិតសម្រាប់ចំណេះដឹង។ ប៉ុន្តែ ដូចគ្នាទៅនឹងរូបអ្នកតាព្រះភក្ត្រ៨ទិសដែរសមាសធាតុទាំងនេះគឺជាធាតុផ្សំសម្រាប់បំពេញបន្ថែម ចំពោះការយល់ឃើញអំពីប្រទេសនិងពិភពលោករបស់យើង ទោះបីជា ធាតុផ្សំទាំងនេះមិន គ្រប់ជ្រុងជ្រោយយ៉ាងណាក៏ដោយ។ការតស៊ូដើម្បី បញ្ឈប់ស្ថានភាពខាងលើត្រូវតែជាឆន្ទៈ ដ៏មុះមុតរបស់មនុស្សជាតិនៅក្នុងសតវត្សរ៍ទី២១នេះ។ ដូចគ្នានេះដែរអ្នកកសាងរូបតំណាងយល់ឃើញថានៅពេលដែលមនុស្សមានជំនឿថាខ្លួនអាចទប់ស្កាត់អំពើអមនុស្សធម៌នានាបាន នោះទំនុកចិត្តនឹងកើតមានឡើងកាន់តែខ្លាំង ហើយភាពក្លាហានក្នុងការប្រយុទ្ធប្រឆាំងទៅនឹងអំពើទាំងនោះ ក៏ត្រូវបានផុសឡើងកាន់តែខ្ពស់ ក្នុងការការពារអនាគតប្រទេសជាតិដោយគ្មានអំពើប្រល័យពូជសាសន៍និងការសម្លាប់រង្គាល។* **ដេង ពង្សរ៉ាស៊ី**

# «អន្លង់វែងស្នេហា» និង «គ្មានឥន្ទធនូស្នេហ៍» កំពុងទាក់ទាញចំណាប់អារម្មណ៍អ្នកស្តាប់

«អន្លង់វែងស្នេហា» និង «គ្មានឥន្ទធនូស្នេហ៍» គឺជាបទចម្រៀងពីរបទ ដែលទើបនឹងបានថត កាលពីអំឡុងខែកញ្ញា ឆ្នាំ២០១៩ កន្លងមកបន្ទាប់ពីបានចំណាយពេលវេលា៥ខែក្នុងការរៀបចំតាក់តែងនិពន្ធ។ បទចម្រៀងទាំងពីរនេះត្រូវបានផ្សព្វផ្សាយលើបណ្តាញសារព័ត៌មាន ហ្វេសប៊ុកយូធូបនិងកំពុងទាក់ទាញចំណាប់អារម្មណ៍ អ្នកស្តាប់យ៉ាងខ្លាំងជាពិសេសប្រជាជន រស់នៅក្នុងតំបន់អន្លង់វែងដែលជាអតីតតំបន់តស៊ូដ៏រឹងមាំរបស់ ចលនាខ្មែរក្រហមក្នុងអំឡុងទសវត្សរ៍ឆ្នាំ៨០និង៩០។ ចាប់តាំងពីពាក់កណ្តាលខែកញ្ញា ដល់ថ្ងៃទី២១ខែតុលាឆ្នាំ២០១៩នេះមានអ្នកចូលស្តាប់ បទចម្រៀង «អន្លង់វែងស្នេហា» និង«គ្មានឥន្ទធនូស្នេហ៍»កើនដល់៩៣ម៉ឺននាក់រួចមក ហើយតាមរយៈហ្វេសប៊ុកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងតែមួយប៉ុណ្ណោះ ខណៈពេលដែលបទចម្រៀងទាំងពីរនេះមិនទាន់ថតជាវីដេអូរនៅឡើយ។ «អន្លង់វែងស្នេហា» និង«គ្មានឥន្ទធនូស្នេហ៍»គឺជាបទចម្រៀងដំបូងដែលបានបង្កប់នូវពាក្យពេចន៍ខ្លឹមសារ និងអត្ថន័យប្រៀបធៀប យ៉ាងស៊ីជម្រៅនៅក្នុងបរិបទប្រវត្តិសាស្ត្រនិងការផ្សះផ្សាជាតិ។

នៅពេលនិយាយពីអន្លង់វែង ប្រជាជនកម្ពុជាតែងតែគិតថាគឺជាអតីតតំបន់ គ្រប់គ្រងដោយខ្មែរក្រហម និងជាតំបន់ដែលធ្លាប់កើតមានសង្គ្រាម ការកាប់សម្លាប់ អំពើយោ



រូបទី១រាប់ពីខាងឆ្វេង៖ ខី ថាវ៉េន ស៊ុំ សារឿន និង ស៊ុន ស្រីពេជ្រ ឡើងមាននមតិនៅស្ថានីយទូរទស្សន៍ ស៊ី.ធី.អិន

រយៅគ្រាប់មីននិងឆ្ងាយដាច់ស្រយាល។ រយៈពេលជាច្រើនទសវត្សរ៍ប្រជាជននៅក្នុងសហគមន៍អន្លង់វែង បានខិតខំប្រឹងប្រែងយ៉ាងលំបាកនិងត្រូវប្រឈមជាមួយកេរដំណែលប្រវត្តិសាស្ត្រដ៏សោកសង្រេងទាំងនោះ។ ទោះបីយ៉ាងណាក៏ដោយ អន្លង់វែងបានឈានឆ្ពោះទៅមុខយ៉ាងរឹងមាំជាមួយប្រវត្តិសាស្ត្រ ធនធានធម្មជាតិ ព្រៃឈើ និងជួរភ្នំដងរែកដែលហាក់ឈររង់ចាំឃ្លាំមើល ការពារ និងថែរក្សាតំបន់នេះ។ អន្លង់វែងគឺជាទីតាំងសំខាន់មួយ ក្នុងចំណោមទីតាំង ដែលគ្រប់គ្រងដោយខ្មែរក្រហមរួមមានម៉ាឡៃប៉ៃលិននិងសំឡូត។ អន្លង់វែងបានទទួលសន្តិភាពចុងក្រោយនៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៩៩ បន្ទាប់ពីការបែកបាក់ និងសង្គ្រាមរ៉ាំរ៉ៃដែលបានអូសបន្លាយអស់ជាច្រើនទសវត្សរ៍។

«អន្លង់វែងស្នេហា»និង«គ្មានឥន្ទធនូស្នេហ៍» និពន្ធទំនុកច្រៀងនិងបទភ្លេងដោយលោក ស៊ុំសារឿនគឺជាអតីតអ្នកចម្រៀងដើងចាស់ម្នាក់និងជាអតីតអ្នកនិពន្ធប្រចាំផលិតកម្មរស្មីហង្សមាស។ «អន្លង់វែងស្នេហា» ច្រៀងដោយលោក ឌី ថាវ៉េន ម្ចាស់ពានរង្វាន់ចម្រៀងមហោស្រពសិល្បៈឆ្នាំ២០១១។រីឯបទ «គ្មានឥន្ទធនូស្នេហ៍» ច្រៀងដោយអ្នកនាង ស៊ុន ស្រីពេជ្រ អតីតអ្នកចម្រៀងនៅផលិតកម្មហង្សមាស។







លោក ស៊ុំ សារឿន លោក ឌី ថាវ៉េន និងអ្នកនាង ស៊ុន ស្រីពេជ្រ ត្រូវបានស្ថានីយ៍ទូរទស្សន៍ ស៊ី.ធី.អិន អញ្ជើញឲ្យចូលរួមនៅក្នុងកម្មវិធីសោភណ្ឌតន្ត្រី នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៩ និងបានធ្វើការផ្សាយបន្តផ្ទាល់។ បន្ទាប់ពីឡើងច្រៀងបទ«អន្លង់វែងស្នេហា» និង «គ្មានឥន្ទធនូស្នេហ៍»រួចមក លោក ឌី ថាវ៉េន និងអ្នកនាង ស៊ុន ស្រីពេជ្រ ក៏ត្រូវបានពិធីករប្រចាំកម្មវិធីអ្នកនាង យុគ ចិន្តា និងលោកអ៊ឹងវដ្ឋាសំណូមពរឲ្យច្រៀងបទទាំងពីរដោយមិនមានភ្លេងអម ជូនដល់ទស្សនិកជនបានស្តាប់ដោយផ្ទាល់ម្តងទៀត។ បន្ទាប់មក លោកលី

សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានជូនផ្កាទន់លើកទឹកដល់អ្នកចម្រៀងទាំងពីររួមទាំងក្រុមតន្ត្រី ប្រចាំនៅស្ថានីយ៍ ទូរទស្សន៍ ស៊ី.ធី.អិន។

លោក ស៊ុំ សារឿន បានប្រសាសន៍ថា ដោយសារអ្នកចម្រៀងទាំងពីរបានច្រៀងបទ «អន្លង់វែងស្នេហា និង «គ្មានឥន្ទធនូស្នេហ៍» ចេញពីបេះដូងរបស់ខ្លួនផ្ទាល់ទើបធ្វើឲ្យបទចម្រៀងកាន់តែពិរោះខ្លាំងឡើងថែមទៀត។ លោក ស៊ុំ សារឿន បានបន្តថាមូលហេតុ ដែលខ្ញុំចាប់អារម្មណ៍ទៅលើតំបន់អន្លង់វែង ដោយសារអន្លង់វែង គឺជាសម្បុកចុងក្រោយរបស់ចលនាខ្មែរក្រហម។ នៅពេលដែលខ្ញុំបានទៅដល់កាលពីប៉ុន្មានខែមុននេះអន្លង់វែង គឺជាទឹកន្លែងដ៏ស្រស់ស្អាតប្រៀបដូចជាឋានទេពនិមិត្ត ប៉ុន្តែបើយើងក្រឡេកទៅមើលអតីតកាលពេលដែលតំបន់នេះ មិនទាន់ធ្វើសមាហរណកម្មអន្លង់វែងគឺជាតំបន់ដ៏គ្រោះថ្នាក់បំផុត។ ចំពោះបទ «អន្លង់វែងស្នេហា» ដែលច្រៀងដោយលោក ឌី ថាវ៉ែន និយាយអំពីយុវជនដែលជាអតីតយោធាខ្មែរក្រហម នៅពេលមកដល់អន្លង់វែងក៏បានចាប់ចិត្តចំពោះសម្រស់ដ៏ស្រស់ស្អាតនៃទឹកដីអន្លង់វែងហើយក៏បានលង់ស្រឡាញ់នារីម្នាក់នោះ។ សេចក្តីស្រឡាញ់របស់យោធាខ្មែរក្រហម ចំពោះនារីម្នាក់នោះ តំណាងឲ្យការធ្វើសមាហរណកម្ម របស់ខ្មែរក្រហម ជាមួយរាជរដ្ឋាភិបាល។ យុទ្ធជនម្នាក់នេះសុខចិត្តទម្លាក់អាវុធចោល ដើម្បីសារភាពស្នេហ៍នៅអន្លង់វែង។ចំណែកឯបទទីពីរ «គ្មានឥន្ទនូស្នេហ៍» ដែលច្រៀងដោយអ្នកនាង ស៊ិន ស្រីពេជ្រតួអង្គនារីជាខ្មែរក្រហមមានភាពម៉ឺងម៉ាត់ អង់អាចក្លាហាន។ប៉ុន្តែនៅពេលដែលនាងមកដល់អន្លង់វែង ក៏បានលង់ស្នេហ៍បុរសទីក្រុងភ្នំពេញដោយបានលះបង់ទាំងចិត្តទាំងកាយ។ត្រង់នេះចង់សំដៅទៅលើចលនា ខ្មែរក្រហមនៅតំបន់អន្លង់វែង សុខចិត្តដាក់អាវុធ



លោកបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ជូនផ្កាទន់លើកទឹកចិត្តដល់អ្នកចម្រៀង

មករួបរួមជាមួយរដ្ឋាភិបាល។

ជាចុងក្រោយ ខ្ញុំសូមអរគុណចំពោះ ថាវ៉េន និង ស្រីពេជ្រ ដែលបានយកមនោសញ្ចេតនា មកច្រៀងក្នុងស្នាដៃបទចម្រៀងទាំងពីរបទនេះ។ ជាពិសេស ខ្ញុំសូមអរគុណចំពោះលោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលលោកបានជួយកែបទចម្រៀងទាំងពីរបទប្រកបទៅដោយអត្ថន័យដ៏ជ្រាលជ្រៅ។

ស្រឡាញ់ និងដើម្បីបង្ហាញពីការប្ដេជ្ញាចិត្ត ចំពោះសេចក្ដីស្នេហារបស់ខ្លួន។នារីដ៏ស្រស់សោភាបានសន្យាថាមានសេចក្ដីស្នេហា ប៉ុន្តែមិនបានប្ដេជ្ញាចិត្តនឹងលះបង់ចំពោះ សេចក្ដីស្នេហានោះឡើយ។ ដូច្នេះហើយ នាងត្រូវបានប្រៀបប្រដូចទៅនឹងពពកនៅក្នុងវប្បធម៌ខ្មែរ។ ពពកមានភាពស្រស់ស្អាត និងគួរឲ្យចាប់អារម្មណ៍។ ប៉ុន្តែពពកនោះ ក៏អាចប្រែទៅជាព្យុះភ្លៀងមួយរំពេច។ នៅពេលដែលទឹកភ្លៀងធ្លាក់ដល់ដីវា



បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងទស្សនាការប្រគុំតន្ត្រីនៅស្ថានីយ៍ទូរទស្សន៍.ស៊ី.ធី.អិន

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបានមានប្រសាសន៍ថាបទ« អន្លង់វែងស្នេហា» តំណាងដោយសាច់រឿងរបស់បុរសម្នាក់ ដែលជាអតីតយោធាខ្មែរក្រហមហើយបានលង់ស្នេហ៍លើស្ត្រីម្នាក់។ ស្ត្រីរូបនោះគឺតំណាងឲ្យប្រទេសកម្ពុជា។ បុរសដែលជាអតីតយោធាខ្មែរក្រហមបានសុខចិត្តទម្លាក់អាវុធចុះ ដើម្បីមករួមរស់ជាមួយនារីដែលខ្លួននឹងប្រែទៅជាភក់ជ្រាំ។ សាច់រឿងនេះតំណាងឲ្យតំបន់អន្លង់វែងដែលជាទីតាំងកាន់កាប់ចុងក្រោយ របស់ចលនាខ្មែរក្រហមហើយដែលបានទម្លាក់អាវុធចុះ និងប្ដេជ្ញាចិត្តរួមរស់នៅក្នុងសង្គមជាតិ ដោយជំនួសឲ្យការសន្យាមួយ។ បទចម្រៀងនេះបានបង្ហាញថាការសន្យាមិនត្រូវបានបំពេញនោះទេ។

ចំណែក «គ្មានឥន្ទធនូស្នេហ៍» គឺមានគោលគំនិតតែ

*មួយប៉ុន្តែប្តូរតួអង្គវិញម្តង។ តួអង្គដែលជាស្ត្រីគឺតំណាងឲ្យខ្មែរក្រហម ចំណែកឯប្រទេសកម្ពុជាគឺជាតួអង្គបុរសវិញម្តង។ ស្ត្រីម្នាក់ដែលតំណាងឲ្យខ្មែរក្រហមមានអារម្មណ៍ថា ព្រហ្មលិខិតបានកំណត់ឲ្យខ្លួនជួបបុរសម្នាក់ដែលជាអ្នកទីក្រុង ហើយនាងគឺជាអ្នករស់នៅក្នុងព្រៃនៅស្រុកអន្លង់វែង។ អ្នកទាំងពីរបានជួបគ្នាដោយសារទេវតាបានចារទុកមក។បទចម្រៀងទីពីរនេះបានផ្លាស់ប្តូរវេនជានិមិត្តរូប។បុរសគឺជាឥន្ទធនូដែលនារីរូបនោះបានស្ងើចសរសើរ និងគយគន់មិនចេះនឿយណាយ។ប៉ុន្តែឥន្ទធនូ ក៏បានរលាយបាត់រូបទៅវិញបន្ទាប់ពីរដូវវស្សាបានបញ្ចប់ ដោយទុកឲ្យនារីរូបនោះរស់នៅកំព្រាឯកោតែម្នាក់ឯង។ បទចម្រៀងនេះ គឺជាន័យធៀបទៅនឹងការតស៊ូរបស់ស្រុកអន្លង់វែង ដើម្បីផ្សះផ្សាជាមួយប្រទេសជាតិ។ តំបន់អន្លង់វែងមានភក្តីភាពចង់រួមរស់នៅ ជាមួយប្រទេសជាតិដូចគ្នាទៅនឹងនារី ដែលប្រាថ្នាចង់រស់នៅជាមួយបុរសដែលជាឥន្ទធនូនោះដែរ។ ប៉ុន្តែឥន្ទធនូបានរសាត់ទៅតាមទឹកភ្លៀង ហើយនារីនោះ ត្រូវបានបង្ខំចិត្តបោះបង់ចោលនិងតស៊ូជម្នះរស់នៅដោយខ្លួនឯងវិញ។*

*រហូតមកដល់ពេលនេះ អ្នកដែលធ្លាប់បានស្តាប់បទចម្រៀង«អន្លង់វែងស្នេហា» និង «គ្មានឥន្ទធនូស្នេហ៍» បានលើកឡើងនូវការយល់ឃើញរបស់ខ្លួនដូចខាងក្រោម ៖*

*១) អុល មេត្តា ភេទស្រី អាយុ២៣ឆ្នាំ គឺជាអតីតនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មានស្រុកកំណើតនៅក្នុងខេត្តកំពង់ឆ្នាំងបានលើកឡើងថា«ខ្ញុំបានស្តាប់បទចម្រៀងដែលបានផ្សព្វផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។*

*ខ្ញុំគិតថា បទចម្រៀងនេះពិតជាពិរោះ។ បទចម្រៀងនេះបានធ្វើឲ្យខ្ញុំមកចាប់អារម្មណ៍តំបន់អន្លង់វែង និងចង់ទៅទស្សនាតំបន់អន្លង់វែង។ មេត្តាបានបន្ថែមទៀតថា «ខ្ញុំមិនដឹងថាតំបន់អន្លង់វែងគឺជាកន្លែងប្រវត្តិសាស្ត្រដ៏សំខាន់ដែលធ្វើឲ្យប្រទេសកម្ពុជា មានសន្តិភាពឡើយបន្ទាប់ពីការធ្វើសមាហរណកម្ម»។*

*២) បុណ្យ ពេជ្យ ភេទប្រុស អាយុ១៩ឆ្នាំគឺជានិស្សិតនៃសាលាពហុបច្ចេកទេសមកពីខេត្តព្រៃវែង បាននិយាយថា «ខ្ញុំបានស្តាប់បទចម្រៀងអន្លង់វែងស្នេហា។ បទចម្រៀងនេះពិរោះហើយពាក្យពេចន៍នៃបទចម្រៀងអ្នកនិពន្ធបានប្រើន័យធៀបជាមួយប្រវត្តិសាស្ត្រ។ បទចម្រៀងមួយបទនេះបានធ្វើឲ្យប្លែកអារម្មណ៍ខ្លាំងណាស់»។*

*៣) ចាន់ វ៉ានុយ អាយុ២៣ឆ្នាំ កើតនៅរាជធានីភ្នំពេញយល់ថា«បទចម្រៀងនេះពិតជាពិរោះខ្លាំងណាស់។អ្នកនិពន្ធបានរៀបរាប់ពីទីតាំងមួយកន្លែង ក្នុងប្រទេសកម្ពុជាដែលជាកន្លែងប្រវត្តិសាស្ត្ររបស់ តាម៉ុក ដែលជាមេដឹកនាំខ្លាំងជាងគេក្រោយពេលខ្មែរក្រហមដួលរលំ។ ខ្ញុំពិតជាពេញចិត្តបទចម្រៀងនេះខ្លាំងណាស់ទាំងអត្ថន័យបទចម្រៀងទំនុកភ្លេងនិងសំឡេងរបស់អ្នកចម្រៀង ពិតជាស័ក្តិសមទៅនឹងតំបន់ប្រវត្តិសាស្ត្ររបស់ជាតិយើងខ្លាំងណាស់»។*

*៤) ផុន ថេង សព្វថ្ងៃរស់នៅក្នុងស្រុកអន្លង់វែងបានរៀបរាប់ថា «ខ្ញុំពិតជាចូលចិត្តស្តាប់បទចម្រៀងនេះខ្លាំងណាស់។ នៅពេលខ្ញុំស្តាប់បទនេះ ធ្វើឲ្យអារម្មណ៍របស់ខ្ញុំមានក្តីរំភើប។បទចម្រៀងមួយនេះបានរៀបរាប់ពីទីតាំងដែលខ្ញុំធ្លាប់បានស្គាល់ និងរស់នៅ។ ចម្រៀងនេះមិនត្រឹមតែរៀបរាប់ពីប្រវត្តិសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានជួយផ្សព្វផ្សាយពីតំបន់ទេសចរណ៍នៅ អន្លង់វែង ឲ្យប្រជាជនដែលរស់នៅតំបន់ផ្សេងទៀតបានស្គាល់ដែរ។ ខ្ញុំក៏ទន្ទឹងរង់ចាំមើលការថតជាវីដេអូរបស់បទចម្រៀងទាំងនេះ» ដែរ។*

*៥) ឈ្មោះថៃ ដានី ជានិស្សិតឆ្នាំទី៣នៃសាលាពហុបច្ចេកវិទ្យាកម្ពុជា មានស្រុកកំណើតនៅស្រុកអន្លង់វែងបានលើកឡើងថា «បទចម្រៀងទាំងពីរពិតថាពិរោះខ្លាំងណាស់។ នៅពេលស្តាប់បទចម្រៀងនេះ ធ្វើឲ្យខ្ញុំនឹកដល់ស្រុកកំណើតនិងទិដ្ឋភាពទាំងឡាយនៅក្នុងស្រុកអន្លង់វែង។ ខ្ញុំចូលចិត្តឃ្លានៅក្នុងបទចម្រៀងដែលរៀបរាប់ពីពយតាម៉ុកដែលមានអ័ព្ទធ្លាក់សន្ទឹក ដែលជាទេសភាពស្អាតបំផុតនៅលើកំពូលភ្នំដងរែក»។*

***ក្រុមទស្សនាវដ្តីស្វែងរកការពិត***

# បងស្រីរបស់ខ្ញុំឈ្មោះ ផាន់នី និងបងប្អូនផ្សេងទៀត

ខ្ញុំមិនបានចាំឈ្មោះឪពុកម្តាយបងប្អូន និងទីកន្លែងកំណើតច្បាស់លាស់ឡើយដោយសារខ្ញុំនៅវ័យ ក្មេងនៅមុនពេលរបបខ្មែរក្រហម។ប៉ុន្តែ ខ្ញុំនៅចាំបានថាខ្ញុំឈ្មោះ វឿន ហៅ (កា គីសេង) មានបងប្អូនបួននាក់ ប្រុសពានាក់ និងស្រី១នាក់។ បងស្រីទី១) ឈ្មោះផាន់នី, បងប្រុសទី២) មិនចាំឈ្មោះទី៣) ខ្ញុំ (វឿន) និងទី៤) ប្អូនប្រុសពៅឈ្មោះភាវ៉ា។ បងប្អូនខ្ញុំទាំងបួននាក់រស់នៅជាមួយម្តាយ ដែលជាអ្នកចិញ្ចឹមបីបាច់ថែរក្សា។ ចំណែកឪពុករបស់ខ្ញុំធ្វើទាហាន និងមានប្រពន្ធចុងម្នាក់ទៀត។ឪពុករបស់ខ្ញុំបានចុះចោលម្តាយខ្ញុំ និងកូនទៅនៅជាមួយប្រពន្ធចុងរបស់គាត់។ ម្តាយរបស់ខ្ញុំបានប្រកបមុខរបរលក់ដូរនៅផ្សារ។ ថ្ងៃមួយនៅអំឡុងឆ្នាំ១៩៧៤ ពេលដែលម្តាយខ្ញុំកំពុងតែធ្វើដំណើរទៅលក់ដូរនៅផ្សារដូចធម្មតាក៏ត្រូវគ្រាប់ផ្លោងរបស់យោធាខ្មែរក្រហមនិងកងទ័ព លន់ នល់ ដែលបានបាញ់ផ្លោងដាក់គ្នាទៅវិញទៅមក បណ្តាលឲ្យ ម្តាយខ្ញុំស្លាប់បាត់បង់ជីវិតនៅពេលនោះទៅ។

បន្ទាប់ពីម្តាយរបស់ខ្ញុំបាត់បង់ជីវិតទៅ យើងខ្ញុំទាំងបួននាក់ពុំមានអ្នកចិញ្ចឹមមើលថែឡើយ។ ដូច្នេះយាយរបស់ខ្ញុំដែលរស់នៅទីក្រុងភ្នំពេញ បានមកយកយើងខ្ញុំទាំងបួននាក់ទៅរស់នៅជាមួយគាត់បានរយៈពេលប្រហែលមួយខែ។ខ្ញុំនៅចាំបានថាខ្ញុំបានចាកចេញពីទីក្រុងភ្នំពេញ មុនពេលខ្មែរក្រហមឡើងកាន់អំណាច។យាយរបស់ខ្ញុំ បានបំបែកបងប្អូនខ្ញុំទាំងបួនឲ្យរស់នៅបែកពីគ្នា។យាយរបស់ខ្ញុំ បានឲ្យគេយកខ្ញុំ



រូបទីមួយរាប់ពីស្តាំ ៖ ម្តាយចិញ្ចឹម, បងស្រីចិញ្ចឹម និងកូន ព្រមទាំងប្តីរបស់គាត់ និងរូបខាងឆ្វេងបង្អស់ ខ្ញុំឈ្មោះ វឿន ហៅ កា គីសេង ថតនៅជំរំ ប្រទេសថៃ។

និងបងស្រីឈ្មោះដាន់នី ទៅផ្ញើនៅមណ្ឌលកុមារកំព្រានៅម៉ុំ កំបូល ចំណែកឯ បងប្រុសទី២ និងប្អូនប្រុសពៅឈ្មោះភារ៉ា ត្រូវបានយកទៅដាក់កន្លែងផ្សេងទៀត។ លោកយាយ របស់ខ្ញុំបំបែកបងប្អូនខ្ញុំចេញពីគ្នា ព្រោះគាត់បារម្ភខ្លាច ថាបើបងប្អូនខ្ញុំរស់នៅជុំគ្នានៅពេលមាន គ្រោះថ្នាក់កើតឡើង នឹងត្រូវស្លាប់ទាំងអស់គ្នា។យាយរបស់ខ្ញុំបានប្រាប់បងប្អូនរបស់ខ្ញុំថា គាត់មានការសោកស្តាយយ៉ាងខ្លាំង ជាមួយការ ស្លាប់របស់ម្តាយខ្ញុំហើយគាត់ក៏មិនចង់ឲ្យបងប្អូន របស់ខ្ញុំបាត់បង់ជីវិតទៀតដែរមណ្ឌលកុមារកំព្រាពេលនោះបានកំណត់លក្ខខណ្ឌក្នុងការទទួលយកក្មេងចាប់ពី អាយុ៦ឆ្នាំ ទៅ១២ឆ្នាំ។ខ្ញុំមានអាយុ៩ឆ្នាំចំណែកឯ បងស្រីដាន់នី មានអាយុ១៣ឆ្នាំ ដូច្នេះយើងមិនត្រូវបានអនុញ្ញាតឲ្យស្នាក់នៅមណ្ឌលកុមារកំព្រាទេ ។ប៉ុន្តែមានទាហានម្នាក់បានស្គាល់ខ្ញុំ ហើយគាត់ក៏បានកុហកអ្នកគ្រប់គ្រងនៅមណ្ឌលកុមារកំព្រាថា ខ្ញុំមានអាយុ៦ឆ្នាំ ទើបខាង មណ្ឌលកុមារកំព្រាអនុញ្ញាតឲ្យខ្ញុំស្នាក់នៅ។ រីឯបងស្រីរបស់ខ្ញុំដែលមានអាយុលើស១ ឆ្នាំខុសពីគោលការណ៍ដែលមណ្ឌលកុមារកំព្រា បានកំណត់ មិនមានអ្នកណាជួយគាត់ឲ្យបានរស់នៅទីនោះជាមួយខ្ញុំឡើយ។ បងស្រីខ្ញុំត្រូវបានយាយយកទៅដាក់នៅកន្លែងផ្សេង។ ចាប់តាំងពីពេលនោះមកខ្ញុំនឹងបងស្រីក៏បែកគ្នាជារៀងរហូតមក។

នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុងភ្នំពេញ។ ខ្ញុំ និងកុមារដទៃទៀតត្រូវបានយោធាខ្មែរក្រហម ឲ្យឡើងជិះឡានចេញទៅតាមខេត្តផ្សេងៗ ។ លុះធ្វើដំណើរទៅដល់ម្តុំទីទួលភ្នំ មួយប្រហែលនៅក្នុងខេត្តកំពង់ស្ពឺឡានក៏រលត់ ខណៈនោះយោធាខ្មែរក្រហមបានប្រើកុមារដែលជិះនៅលើឡាន ចុះជួយរុញឡានទៅមុខ។ដោយសារតែខ្ញុំហត់នឿយពេក ខ្ញុំក៏មិនបានបន្តដំណើរទៅមុខទៀតដែរ ហើយក៏បានចូលធ្វើការក្នុងកងកុមារប្រហែលនៅម្តុំខេត្តកំពង់ស្ពឺ។ ទោះបីខ្ញុំនៅវ័យក្មេងនៅឡើយ ប៉ុន្តែខ្ញុំត្រូវបានអង្គការប្រើឲ្យធ្វើការនៅតាមការដ្ឋានជាទម្ងន់ ដូចជា រែកដី និងលើកទំនប់។ នៅក្នុងឆ្នាំ១៩៧៨ ខ្ញុំបានជួបបងស្រីរបស់ខ្ញុំវិញ ហើយក៏ ជាលើកចុងក្រោយ ដែរនៅពេលដែលខ្ញុំកំពុងដើរទៅធ្វើការ។ ប៉ុន្តែយើងមិនបាននិយាយរកគ្នាឡើយដោយសារខ្លាចអង្គការដាក់ទោស។

រហូតដល់ដើមខែមករា ឆ្នាំ១៩៧៩ នៅពេលដែលកងទ័ពវៀតណាមវាយចូលមកកងកុមាររបស់ខ្ញុំត្រូវបានរំសាយ ។ខ្ញុំជាកូនកំព្រាឪពុកម្តាយ ហើយខ្ញុំក៏មិនដឹងថាត្រូវទៅទីណាដែរ ទើបអ៊ំស្រីដែលជាអ្នកមើលក្មេងៗនៅក្នុងមណ្ឌលកុមារកំព្រា និងក្រោយមកត្រូវបានខ្មែរក្រហមចាត់ឲ្យមើលកុមារនៅក្នុងកងកុមាររបស់ខ្ញុំ បានយកខ្ញុំទៅនៅជាមួយគាត់រួមជាមួយនឹងក្មេងស្រីម្នាក់ទៀត។ ចំណែកឯក្មេងដទៃទៀត ដែលមានសាច់ញាតិបងប្អូន ក៏ចេញទៅរស់នៅតាមកន្លែងផ្សេងៗ ។ខ្ញុំបានធ្វើដំណើរទៅជាមួយអ៊ំស្រី ដែលខ្ញុំបានចាត់ទុកដូចជាម្តាយចិញ្ចឹមរហូតដល់ជំរំមួយ នៅក្នុងប្រទេសថៃដែលខ្ញុំមិនចាំឈ្មោះ។ ខ្ញុំគ្រាន់តែចាំថាជំរំនោះនៅក្បែរសមុទ្រ។ ក្រោយមកក្មេងស្រី ដែលមកជាមួយខ្ញុំ បានស្រឡាញ់គ្នាជាមួយទាហាននៅក្នុងជំរំនោះ ហើយក៏បានរៀបការនិងចេញទៅរស់នៅជាមួយទាហាននោះ។ ចំណែកខ្ញុំបានរស់នៅតែពីរនាក់ម្តាយចិញ្ចឹមរហូតដល់ចុងឆ្នាំ១៩៨០ ក៏បានចាកចេញពីជំរំទៅកាន់ប្រទេសទីបី។ ខ្ញុំនិងម្តាយចិញ្ចឹមបានទៅដល់ប្រទេសកាណាដា នៅដើមឆ្នាំ១៩៨១។

ប្រសិនបើបងប្អូនដែលមានឈ្មោះ និងព័ត៌មានផ្ទាល់ខ្លួនដូចដែលខ្ញុំបានរៀបរាប់ខាងលើ សូមមេត្តាទាក់ទងមកខ្ញុំបាទតាមរយៈលេខទូរសព្ទ ៖ ០៧៧ ៦១ ៧១ ៨៥

ឬ kyskar@hotmail.com

ឬទាក់មកទស្សនាវដ្តីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា តាមរយៈអាសយដ្ឋាន ៖ ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ឬលេខទូរស័ព្ទ៖ ០១២ ៩៩ ៦៧ ៥០

និងអ៊ីម៉ែល truthbunthorn.s@dccam.org សូមអរគុណ!

**ផាត ចាន់សុនិតា**

# ប្រវត្តិរូប ប៉ែន អុន និងប្រពន្ធឈ្មោះ អ៊ុយ ឈុតណា

ប៉ែន អុន កើតនៅថ្ងៃទី១ ខែសីហា ឆ្នាំ១៩៣៧ នៅខេត្តស្វាយរៀង។ ឪពុករបស់ ប៉ែន អុន ឈ្មោះ ប៉ែន ឃឹម អាយុ៦៥ឆ្នាំ (នៅក្នុងឆ្នាំ១៩៧៦) មានមុខរបរជាកម្មកររបសុពេទ្យរស់នៅខេត្តស្វាយរៀង និងម្តាយឈ្មោះ ឥនធានស្លាប់។ ប៉ែន អុន ពីមុនមានមុខរបរធ្វើទាហាន (អាកាសចរ)បានរៀបការជាមួយប្រពន្ធឈ្មោះអ៊ុយឈុតណា នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៦២។ អ៊ុយ ឈុតណាកើតនៅភ្នំពេញមានមុខរបរធ្វើជាមេផ្ទះស្នាក់នៅផ្ទះទល់មុខទន្លេបាសាក់។ប៉ែនអុន បានចាកចេញពីប្រទេសកម្ពុជានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដោយមូលហេតុភៀសខ្លួនមួយរយៈ ដោយបានស្នាក់នៅប្រទេសថៃនិងសហរដ្ឋអាមេរិក មុនពេលទៅដល់ប្រទេសបារាំង នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៦។ នៅប្រទេសបារាំង ប៉ែន អុន ស្នាក់នៅអូតែលអ៊ុយនី ផ្លូវហ្សូហ្សេII។ ប៉ែន អុន បានស្នើសុំស្ថានតំណាងបេសកកម្មរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាប្រចាំនៅ ប្រទេសបារាំង ដើម្បីប្តូរលិខិតឆ្លងដែន និងសុំត្រឡប់ ចូលស្រុកវិញដោយមានការចុះហត្ថលេខារបស់សាមីខ្លួនផ្ទាល់ ធ្វើនៅប៉ារីស ថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៧៦។

ឯកសារស្នើសុំប្តូរលិខិតឆ្លងដែននេះត្រូវបានចុះលេខ N0602P និងមានក្រសួង ត្រួតពិនិត្យឃើញថា ព័ត៌មានខាងលើនេះត្រឹមត្រូវតាមលិខិតឆ្លងដែនចាស់។ ក្រសួងយល់ព្រមតាមសំណូមពររបស់សាមីជន(ប៉ែន អុន)។ លិខិតនេះធ្វើនៅប៉ារីសថ្ងៃទី១៩ខែមេសា ឆ្នាំ១៩៧៦ ដែលមានអ្នកទទួលខុសត្រូវក្រសួងលិខិតឆ្លងដែន ចុះហត្ថលេខាដោយ ឈ្មោះ គាន់ សម្បត្តិ។

លិខិតឆ្លងដែននេះយល់ស្របព្រមតាមសេចក្តីបញ្ជាក់ខាងលើធ្វើ នៅប៉ារីស ថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៦ ដែលមានអ្នកទទួលខុសត្រូវក្រសួងកម្ពុជា ចុះហត្ថលេខាដោយ ឈ្មោះប៊ីចុងទី។

បេសកកម្មសម្រេចចេញលិខិតឆ្លងដែនឲ្យទៅសាមីជន (ប៉ែន អុន)។ ធ្វើនៅប៉ារីស ថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៦ ចុះហត្ថលេខាដោយឈ្មោះ កែម ធី (ជ.បេសកកម្ម)។

**ក្រៅពីសំណុំបែបបទដើម្បីបំពេញពាក្យសុំលិខិតឆ្លងដែនរបស់ ប៉ែន អុន ក៏ឃើញបែបបទដើម្បីបំពេញពាក្យសុំលិខិតឆ្លងដែនរបស់ប្រពន្ធគាត់ឈ្មោះ អ៊ុយ ឈុតណា ដែលបានកត់ត្រាដូចខាងក្រោម ៖**




ប្រវត្តិរូបសង្ខេបរបស់ ប៉ែន អ៊ុន នៅក្នុងឯកសារ «I» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

អ៊ុយ ឈុតណា កើតនៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៤៥នៅភ្នំពេញ។ឪពុករបស់អ៊ុយឈុតណា ឈ្មោះ អ៊ុយ ឈិត ស្លាប់ និងម្តាយឈ្មោះសាតសែអាយុ៦២ឆ្នាំ ( ក្នុងឆ្នាំ ១៩៧៦ ) រស់នៅខេត្តកំពត។អ៊ុយ ឈិត មានមុខរបរធ្វើជាមេផ្ទះបាន


I10867

...YAL D'UNION

...N FRANCE

FICHE A REMPLIR POUR LA DEMANDE D'UN PASSEPORT

ប្រវត្តិរូបសង្ខេបរបស់ អ៊ុយ ឈុតណា នៅក្នុងឯកសារ «I» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

រៀបការជាមួយប្តីឈ្មោះប៉ែនអុននៅថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៦២។ប៉ែនអុនកើតនៅខេត្តស្វាយរៀង មានមុខធ្វើទាហានអាកាសចរ។អ៊ុយឈុតណា បានចាកចេញពីប្រទេសកម្ពុជានៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ ដោយមូលហេតុភៀសខ្លួនមួយរយៈដោយបានស្នាក់នៅប្រទេសថៃនិងសហរដ្ឋអាមេរិក មុនពេលទៅដល់ប្រទេសបារាំង នៅថ្ងៃទីខែមករា ឆ្នាំ១៩៧៦។នៅប្រទេសបារាំងអ៊ុយឈុតណាស្នាក់នៅអូតែលអ៊ុយនីផ្លូវហ្សូហ្សេII។

អ៊ុយ ឈុតណា បានស្នើសុំស្ថានតំណាងបេសកកម្មរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាប្រចាំនៅប្រទេសបារាំងដើម្បីប្តូរលិខិតឆ្លងដែន និងសុំត្រឡប់ចូលស្រុកវិញ ដោយមានការចុះហត្ថលេខារបស់សាមីខ្លួនផ្ទាល់ធ្វើនៅប៉ារីស ថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៧៦។

ឯកសារស្នើសុំប្តូរលិខិតឆ្លងដែននេះត្រូវបានចុះលេខ N0601P និងមានក្រសួងត្រួតពិនិត្យឃើញថាព័ត៌មានខាងលើនេះត្រឹមត្រូវតាមលិខិតឆ្លងដែនចាស់។ ក្រសួងយល់ព្រមតាមសំណូមពររបស់សាមីជន (អ៊ុយឈុតណា)។ លិខិតនេះធ្វើនៅប៉ារីសថ្ងៃទី១៩មេសា ឆ្នាំ១៩៧៦ ដែលមានអ្នកទទួលខុសត្រូវក្រសួងលិខិតឆ្លងដែន ចុះហត្ថលេខា ដោយឈ្មោះ គាន់ សម្បត្តិ។

លិខិតឆ្លងដែននេះ យល់ស្របព្រម តាមសេចក្តីបញ្ជាក់ខាងលើ ធ្វើនៅប៉ារីសថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៦ ដែលមានអ្នកទទួលខុសត្រូវក្រសួងកម្ពុជា ចុះហត្ថលេខា ដោយ ឈ្មោះ ប៊ី ចុងទី។

បេសកកម្មសម្រេចចេញលិខិតឆ្លងដែនឲ្យទៅសាមីជន (អ៊ុយ ឈុតណា)។ ធ្វើនៅប៉ារីស ថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៦ចុះហត្ថលេខាដោយឈ្មោះកែមធី (ជ.បេសកកម្ម)។

ប្រសិនបើបងប្អូនណាបានស្គាល់ឈ្មោះខាងលើសូមទំនាក់ទំនងមកទស្សនាវដ្តីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈអាសយដ្ឋាន ៖ ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ឬលេខទូរសព្ទ០១២៩៩៦៧៥០

អ៊ីម៉ែលtruthbunthorn.s@dccam.org

សូមអរគុណ!

**សោម ប៊ុនថន**

# បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមចារទុកក្នុងសៀវភៅរំឭកវិញ្ញាណក្ខន្ធនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

**(តពីលេខមុន)**

ឆេង ថៃ ហៅឆាត មានអាយុ២៣ឆ្នាំក្នុងឆ្នាំ១៩៧៧មានស្រុកកំណើតនៅរលាប្អៀរខេត្តកំពង់ឆ្នាំងជាកូនរបស់ ពូ ឌុក កាក់និងមីងនួនឡាយមានប្រពន្ធឈ្មោះសាទ ហៅនី ត្រូវបានខ្មែរ ក្រហមចាប់ខ្លួននៅកងពល៤៥០ថ្ងៃ ទី១៨ ខែកុម្ភៈឆ្នាំ១៩៧៧ហើយសម្លាប់ចោលនៅ ថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពី ជាប់ឃុំឃាំងនៅគុកទួលស្លែង អស់រយៈពេល ២៨ ថ្ងៃ។

ឆេង រិន ហៅអឹម មានអាយុ១៩ឆ្នាំ ក្នុងឆ្នាំ១៩៧៥មានស្រុកកំណើតនៅកណ្តាលស្ទឹង ខេត្តកណ្តាល ជាកូនរបស់ពូប្រាំងហ៊ីម និងមីងឆេងសួនត្រូវបានខ្មែរក្រហមចាប់ខ្លួននៅសាលាស្រុកចំបក់(សាលាស្រុកចាស់)ថ្ងៃទី២៣ ខែវិច្ឆិកាឆ្នាំ១៩៧៥ហើយបញ្ជូនទៅឃុំឃាំង នៅគុកទួលស្លែង ក្នុងផ្ទះក០១បន្ទប់ធំ០១២។កាលបរិច្ឆេទ មកដល់គុកទួលស្លែង មានដល់ទៅពីរគឺថ្ងៃទី២០ខែកុម្ភៈនិងថ្ងៃទី៦ខែមេសាឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ឆេងរិន នៅថ្ងៃទី១៥ខែឧសភាឆ្នាំ១៩៧៦។

ឆេង ហាន មានអាយុ២៦ឆ្នាំ ក្នុងឆ្នាំ១៩៧៥មានស្រុកកំណើតនៅកណ្តាលស្ទឹង ខេត្តកណ្តាល ជាកូនរបស់ពូឆេងហ៊ីម និងមីងប្រាង សួន ត្រូវបានខ្មែរក្រហមចាប់ខ្លួន នៅ(ភូមិ)ចំបក់ថ្ងៃទី១០(ខែធ្នូ)ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះក បន្ទប់ធំ០៧ បន្ទប់តូច៦។ មានកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង ដល់ទៅពីរខុសគ្នាមួយនៅថ្ងៃទី២០ខែវិច្ឆិកាឆ្នាំ១៩៧៥និងមួយទៀតនៅថ្ងៃទី២០ខែកុម្ភៈឆ្នាំ១៩៧៦ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ឆែ ហេង មានអាយុ៣១ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកំពង់ស្វាយខេត្តកំពង់ធំ ជាកូនរបស់អ៊ំ ឆែសេងនិងអ៊ំស្រីកងកែមមានប្រពន្ធឈ្មោះ វ៉ន ស្រឿន ហៅ នី មានកូនស្រី១នាក់ ត្រូវបាន ខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ឆ្វក លួន ហៅយ៉ន មានអាយុ៣៧ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅបារាយណ៍ ខេត្តកំពង់ធំ ជាកូនរបស់អ៊ំឆ្វកយឹមនិងអ៊ំស្រីម៉ាអៀង មានប្រពន្ធឈ្មោះប៉ាត ពូល ហៅយ៉ុម មានកូនប្រុស៤នាក់ និងស្រី៣នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួនពាណិជ្ជកម្មរដ្ឋ ថ្ងៃទី១៧ខែកុម្ភៈឆ្នាំ១៩៧៧។បើយោងតាមឯកសារនៅបណ្ណសារ នៃមជ្ឈមណ្ឌលឯកសារកម្ពុជាដែលយកទៅធ្វើជាបញ្ជីឡើងវិញ ដោយការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជារកឃើញថាឆ្វកលួនហៅយ៉នមានឈ្មោះឆ្វក លួន,ឆ្វក សួន និងឆ្វកលន់ហៅ យ៉ន អាយុ៣៧ឆ្នាំ។ ខ្មែរក្រហមសម្លាប់ឆ្វកលួននៅថ្ងៃទី១២ខែឧសភាឆ្នាំ១៩៧៧បន្ទាប់ពី ជាប់ឃុំឃាំងអស់រយៈពេល៨៥ថ្ងៃ។

ឆ្វង សានសៃ មានអាយុ២៣ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្ទោង ខេត្តកំពង់ធំ ជាកូនរបស់ពូអុងសុននិង មីង ឆ្វងហ៊ត ត្រូវបានខ្មែរក្រហមចាប់ខ្លួនកំពង់ផែកំពង់សោម ថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៧៧ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះង បន្ទប់ធំ០២ បន្ទប់តូច ១០នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ជ ទ្រី មានអាយុ៥២ឆ្នាំ ក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅស្អាងខេត្តកណ្តាលជាកូនរបស់លោក តា ជ និង

លោកយាយមីមានប្រពន្ធឈ្មោះយ៉ាងទ្រី ហៅយីង មានកូនប្រុស៥នាក់ និងស្រី៥នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួន នៅភ្នំស្រុកថ្ងៃទី១២ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះក បន្ទប់ធំ០៧ បន្ទប់តូច៦។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមានពីរខុសគ្នាមួយ នៅថ្ងៃទី១១និងមួយទៀតនៅថ្ងៃទី១២ខែកុម្ភៈឆ្នាំ១៩៧៦។ខ្មែរក្រហមសម្លាប់ជាទ្រីនៅថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៧៦។

ជ សក្តិ ជាយុទ្ធជនស-២១យត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស-២១យថ្ងៃទី១០ខែសីហាឆ្នាំ១៩៧៦។បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារកឃើញថាជសក្តិមានឈ្មោះថាជាសាក់ត្រូវបានចាប់ខ្លួននៅស២១យហើយបញ្ជូនទៅដល់គុកទួលស្លែងនៅថ្ងៃទី៩ ឬ១ ០ ខែសីហា ឆ្នាំ១៩៧៦ ហើយសម្លាប់ចោល នៅថ្ងៃទី៣១ ខែឆ្នាំ ដដែល។

ជន ម៉ឺន ហៅសែមជាយុទ្ធជនកងពលទី៣ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅថ្ងៃទី១ខែកញ្ញាឆ្នាំ១៩៧៦។បើយោងតាមឯកសារនៅបណ្ណសារ នៃមជ្ឈមណ្ឌលឯកសារកម្ពុជាដែលយកទៅធ្វើជាបញ្ជីឡើងវិញ ដោយការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជារកឃើញថាជនម៉ឺន មានឈ្មោះផ្សេង ជិន ម៉ឺន ហៅសែនជាយុទ្ធជនដែលចាប់មកពីកងពលទី៣ខត្តរមកដល់គុកទួលស្លែងនៅថ្ងៃទី១ឬ៥ខែកញ្ញាឆ្នាំ១៩៧៦ហើយសម្លាប់ចោលនៅថ្ងៃទី២៣ខែវិច្ឆិកា ឆ្នាំ១៩៧៦។

ជា កង ហៅ សៀង ជាយុទ្ធជនកងពល៤៥០ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៤៥០ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមបញ្ជូនជាកងមកដល់គុកទួលស្លែងនៅថ្ងៃទី២៩ខែកក្កដា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល៦៨ ថ្ងៃ។

ជា ខន ហៅ ជិន មានអាយុ៣៥ឆ្នាំក្នុងឆ្នាំ១៩៧៧ អតីតនិស្សិតបុគ្គលិកក្រសួងឃោសនាការ មានស្រុកកំណើតនៅកងមាសខេត្តកំពង់ចាម ជាកូនរបស់អ៊ំ ជា ប៊ូ និងអ៊ំស្រី ម៉ៅ អែមត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២ ខែមករា ឆ្នាំ១៩៧៧នៅសាលាបច្ចេកទេសមិត្តភាពភាសាខ្មែរសូវៀតភ្នំពេញហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ឃ បន្ទប់ធំ០៣បន្ទប់តូច៤។ខ្មែរក្រហមសម្លាប់ជាខននៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៦បន្ទាប់ពីជាប់ឃុំឃាំង អស់រយៈពេល ៦៤ថ្ងៃ។

ជា ឆន មានអាយុ៤៣ឆ្នាំ ក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅខេត្តកណ្តាលជាកូនរបស់អ៊ំ អ៊ុច ជា និងអ៊ំស្រី ជា ស៊ុំ មានប្តីឈ្មោះចុល ហៅ វើន ប៉េងគិតមានកូនប្រុស៣នាក់ និងស្រី៥នាក់ ត្រូវបានខ្មែរក្រហម ចាប់ខ្លួននៅកោះអណ្តែត តំបន់២២ ថ្ងៃទី៥ ខែធ្នូ ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះក បន្ទប់ធំ៤។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន២ខុសគ្នា មួយនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៥និងមួយទៀតនៅថ្ងៃទី១៨ខែមករា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ជាឆននៅថ្ងៃទី២៣ខែឧសភា ឆ្នាំ១៩៧៦។

ជា ឆយ ហៅ ពេជ មានអាយុ២៧ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកងមាស ខេត្តកំពង់ចាម ជាកូនរបស់ពូជាញឹម និង មីង ប៉ុលជឺន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ជាឆយនៅថ្ងៃទី១៧ខែមីនា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល២១ថ្ងៃ។

ជា ឆៃហេង ហៅ ភី មានអាយុ២៦ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅត្បូងឃ្មុំ ខេត្តកំពង់ចាម ជាកូនរបស់ពូជា គារ និងមីង លួន យេង មានប្រពន្ធឈ្មោះ ខេ យ៉េ ហៅ ឃីម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅពាណិជ្ជកម្មក្នុងឆ្នាំ១៩៧៧។ខ្មែរក្រហមបញ្ជូន ជា ឆៃហេង មកដល់គុកទួលស្លែងនៅថ្ងៃទី១៧ខែកុម្ភៈ ឆ្នាំ១៩៧៧ និងសម្លាប់ចោលនៅថ្ងៃទី២៤ខែឧសភាឆ្នាំ១៩៧៧។កំណត់សម្គាល់លើឯកសាររបស់ខ្មែរក្រហមសរសេរថា «ងាប់ដោយជំងឺស្គម និងចេញទឹកក្នុងពោះដោយទារុណកម្មដុតខ្ទួចសរសៃ បានព្យាបាល ខ្វាំងជាបន្តបន្ទាប់រហូតមក»។

ជា ជីម មានអាយុ២០ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្អាងខេត្តកណ្តាលជាកូនរបស់ពូ ជា ជីម និងមីង អ៊ឹម វ៉េច ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅវត្តអង្គទីទុយ ខែវិច្ឆិកា ឆ្នាំ១៩៧៦ហើយបញ្ជូនទៅឃុំឃាំង នៅគុកទួលស្លែង ក្នុងផ្ទះដ បន្ទប់ធំ២ បន្ទប់តូច៤។កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន២ខុសគ្នា មួយនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៧៦និងមួយទៀតនៅថ្ងៃទី៦ខែមករាឆ្នាំ១៩៧៧ ហើយត្រូវបានខ្មែរក្រហមសម្លាប់នៅថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៧៧។

ជា ជីម មានអាយុ២០ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅសន្ទុកខេត្តកំពង់ធំ ជាកូនរបស់ពូជា ជី និងមីងឡុង ហួនត្រូវបានខ្មែរក្រហមចាប់ខ្លួន នៅមន្ទីរកាត់ដេររដ្ឋថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៧៧ ហើយសម្លាប់ចោលនៅថ្ងៃនោះតែម្តង។

ជា ណារី មានអាយុ២១ឆ្នាំក្នុងឆ្នាំ១៩៧៦ អតីតកូនសិស្សមានស្រុកកំណើតនៅភ្នំពេញ ជាកូនរបស់ពូ ជា ប៊ុនអេង និងមីង មុំ ម៉ាឡ័យ មានប្តីឈ្មោះ លឹម តុងផេង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ជា ណារី នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល៩៣ថ្ងៃ។ ចំណែកឯប្តីលឹមតុងផេងត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃជាមួយប្រពន្ធ និងសម្លាប់នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៦ (មិនទំនងទេ)។ បើយោងតាម ឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា ជា ណារី មានប្តីម្នាក់ទៀតឈ្មោះ ហួត សុវណ្ណាត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃ ជាមួយគ្នាទាំងអស់ហើយសម្លាប់ចោលនៅថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៧៧។

ជា គ្រាន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៧០ ក្នុងឆ្នាំ១៩៧៦ ហើយបញ្ជូនទៅដល់គុកទួលស្លែងនៅថ្ងៃទី១២ខែសីហា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ជា គ្រាន នៅថ្ងៃ ទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល៣៦ថ្ងៃ។

ជា ថៃ សេង មានអាយុ៤៤ឆ្នាំក្នុងឆ្នាំ១៩៧៦ អតីតសាស្ត្រាចារ្យមានស្រុកកំណើតនៅភ្នំពេញ ជាកូនរបស់អ៊ំជា ជិនកុកនិងអ៊ំស្រីឃីម សារូន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរសន្តាត់កោះចូរ៉ាម (តំបន់២២) ថ្ងៃទី៩ ខែមករា ឆ្នាំ១៩៧៦ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក ០២ បន្ទប់លេខ៨។ ខ្មែរក្រហមបញ្ជូន ជា ថៃ សេង ទៅដល់គុកទួលស្លែងនៅថ្ងៃទី២២ខែកុម្ភៈ ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី២៧ខែឧសភាឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល៩៥ថ្ងៃ។

ជា ធន ត្រូវបានខ្មែរក្រហមចាប់ខ្លួន នៅកងពល១៧០ ក្នុងឆ្នាំ១៩៧៦។

ជា ប៉េងគា ហៅ កៀន មានអាយុ៣៩ឆ្នាំក្នុងឆ្នាំ១៩៧៦ អតីតទាហានសក្តិ៤ មានស្រុកកំណើតនៅកំពង់សៀម ខេត្តកំពង់ចាមជាកូនរបស់អ៊ំជាផៃនិងអ៊ំស្រី ជា ញឹម មានប្រពន្ធឈ្មោះម៉ិញស៊ីជារ៉ាន់ហៅញ៉ាច មានកូនប្រុស ១នាក់និងស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរ ១៧ (កោះគ) ថ្ងៃទី២១ឆ្នាំ១៩៧៦ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុង បន្ទប់ធំ០៧ បន្ទប់តូច១០។ ប៉េងគាត្រូវបានខ្មែរក្រហមបញ្ជូនទៅដល់គុកទួលស្លែង នៅថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៦ ហើយនៅពុំទាន់មានឯកសារបញ្ជាក់ពីកាល បរិច្ឆេទនៃការសម្លាប់នៅឡើយ។

ជា ប៉ោ ចាប់ខ្លួននៅកងពល១៧០ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៧០ ក្នុងឆ្នាំ១៩៧៦ ហើយបញ្ជូនទៅដល់គុកទួលស្លែងនៅថ្ងៃទី២៤ខែកញ្ញា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី២៩ខែឆ្នាំដដែល បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល៦ថ្ងៃ។

ជា ប៊ុន ហៅ ជា បួន មានអាយុ៣០ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅជីក្រែង ខេត្តសៀមរាប ជាកូនរបស់ពូស៊ុយ ជា និងមីង លឹម ខៀវ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅសំណង់ក្បាលថ្នល់ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ យបន្ទប់ធំ២បន្ទប់

តូច៩។ខ្មែរក្រហមសម្លាប់ជាប៊ុននៅថ្ងៃទីខែមីនា ឆ្នាំ១៩៧៧។

ជា បាវ មានអាយុ២៥ឆ្នាំ ក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅកោះធំខេត្តកណ្ដាលជាកូនរបស់ពូ ង៉ែត ជា និងមីង ស៊ុនត្រូវបានខ្មែរក្រហមចាប់ខ្លួននៅ ស្រុក១៨ (ស្រុកកោះធំ) ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ១០បន្ទប់ធំ២។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមិនច្បាស់ទេ។ ខ្មែរក្រហមសម្លាប់ជាបាវនៅថ្ងៃទី៦ខែធ្នូ ឆ្នាំ១៩៧៦។

ជា មលី មានអាយុ៣២ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅដង្កោខេត្តកណ្ដាល(ឥឡូវភ្នំពេញ) ជាកូនរបស់អ៊ំជាដេងនិងអ៊ំស្រីអ៊ួងរ៉ិចមានប្រពន្ធឈ្មោះ ឡេង ប៊ុនថនមានកូនប្រុស១ នាក់និងស្រី១ នាក់ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅឡូតដ្ឋ ថ្ងៃទី៤ខែមករាឆ្នាំ១៩៧៧ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះឆ បន្ទប់ធំ៥បន្ទប់តូច៩។ខ្មែរក្រហមសម្លាប់ជាមលីនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧។

ជា ម៉ៅ មានអាយុ២២ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកៀនស្វាយខេត្តកណ្ដាល ជាកូនរបស់ពូជានៅនិងមីងកុយមឿនត្រូវបាន ខ្មែរក្រហមចាប់ខ្លួននៅស្រុកភ្នំស្រុក ថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះក០៥ បន្ទប់លេខ ៩។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយលទៅធ្វើបញ្ជីឡើងវិញដោយការិយាល័យ សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថាមានឈ្មោះជាម៉ៅដល់ទៅ៣ឈ្មោះប៉ុន្ដែមានអាយុ, មុខងារ និងថ្ងៃចាប់ខ្លួនខុសគ្នានឹងជាម៉ៅក្នុងប្រវត្តិរូប។

ជា យឺន ហៅ ដែក មានអាយុ១៦ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅបារាយណ៍ ខេត្តកំពង់ធំ ជាកូនរបស់ពូ ថែម និងមីង មន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅផ្សារចាស់ ភ្នំពេញ ថ្ងៃទី៩ ខែកក្កដា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះលេខ១០៨បន្ទប់លេខ២។កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងគឺថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៧៦ រីឯកាលបរិច្ឆេទនៃ ការសម្លាប់ មានភាព មិនច្បាស់ លាស់ទេ មួយនៅថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៦ និងមួយទៀតនៅថ្ងៃទី២ ខែមករា ឆ្នាំ១៩៧៦។

ជា លី ហៅ លំ ជាយុទ្ធជនត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦។ ជា លី ត្រូវបានខ្មែរក្រហមចាប់មកពីមន្ទីរ ស-២១យ ហើយបញ្ជូនទៅដល់គុកទួលស្លែងនៅថ្ងៃទី៩ ខែវិច្ឆិកាឆ្នាំ១៩៧៦។២ថ្ងៃក្រោយមកខ្មែរក្រហមសម្លាប់ជា លី។

ជា វង់ មានអាយុ២៧ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្វាយរៀងខេត្តស្វាយរៀង ជាកូនរបស់ពូ ជាឆាយ និងមីងប៉ែនសីមានប្រពន្ធឈ្មោះ ឡាច មុំ មានកូនប្រុស១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួនស្រុកភ្នំស្រុក ថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះកបន្ទប់ធំ៥ បន្ទប់តូច៩។កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងគឺថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៦ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ជា វណ្ណា មានអាយុ២៣ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅព្រៃវែងខេត្តព្រៃវែង ជាកូនរបស់ពូ អ៊ូ ជា និងមីងទូចកាម ត្រូវបានខ្មែរក្រហមចាប់ខ្លួន នៅភ្នំពេញ ថ្ងៃទី២៤ ខែតុលាឆ្នាំ១៩៧៦។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន២ខុសគ្នា មួយនៅថ្ងៃទី២២ និងមួយទៀតនៅថ្ងៃទី២៤ ខែតុលាឆ្នាំ១៩៧៦។ខ្មែរក្រហមសម្លាប់នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧។

ជា វ៉ាន់នី ហៅ ប៉ិច មានអាយុ២៤ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅសំរោងទង ខេត្តកំពង់ស្ពឺ ជាកូនរបស់ពូ ជា សម្បត្តិ និងមីង នាង ប៉ៃ យ៉ាន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅពោធិ៍សាត់ ក្នុងខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងបន្ទប់ធំ០៦។កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន២ខុសគ្នាមួយនៅថ្ងៃទី២៥ ខែមីនា និងមួយទៀតនៅថ្ងៃទី៩ខែមេសាឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ជាវ៉ាន់នីនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៦។

ជា វេងហុង ហៅ ផល មានអាយុ២៤ឆ្នាំក្នុងឆ្នាំ១៩៧៦

មានស្រុកកំណើតនៅបារាយណ៍ ខេត្តកំពង់ធំ ជាកូនរបស់ពូជាព្រិន និង មីង ឈីវ ត្រូវបានខ្មែរក្រហម ចាប់ខ្លួននៅថ្ងៃទី៦ ខែតុលាឆ្នាំ១៩៧៦ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះច បន្ទប់ធំ ២ បន្ទប់តូច ១៨។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន២ខុសគ្នាមួយនៅថ្ងៃទី៥និងមួយទៀតនៅថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៧៦ រីឯកាលបរិច្ឆេទនៃការសម្លាប់គឺថ្ងៃទី១៨ខែឧសភាឆ្នាំ១៩៧៦។

ជា សយ ហៅ ជ័យ មានអាយុ៤៤ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅគងពិសីខេត្តកំពង់ស្ពឺ ជាកូនរបស់អ៊ំ ជានួននិងអ៊ំស្រីយូន មានប្រពន្ធឈ្មោះហៅធី ហៅ ធន មានកូនស្រី១នាក់ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរអគ្គសេនាធិការ ថ្ងៃទី២៩ខែធ្នូឆ្នាំ១៩៧៥ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០៧ បន្ទប់តូច ១៣។ ខ្មែរក្រហមបញ្ជូនជា សយ មកដល់គុកទួលស្លែងនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៦។នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ជា ស៊ីន មានអាយុ២៤ឆ្នាំ ក្នុងឆ្នាំ១៩៧៦ ស្រុកកំណើតនៅសំរោងខេត្តស្វាយរៀងជាកូនរបស់ពូ ជា កុង និងមីងវ៉ា ស៊ួង មាន ប្រពន្ធឈ្មោះមាស សាខន មានកូនស្រី១នាក់ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅព្រៃស ថ្ងៃទី៧ខែមិថុនា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះក០៥ បន្ទប់ធំ។កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង គឺនៅថ្ងៃទី៥ខែមិថុនា ឆ្នាំ១៩៧៨។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ជា សារ៉េត ហៅ តាំង ជាយុទ្ធជន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៤៥០ ក្នុងឆ្នាំ១៩៧៦។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងគឺថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៧៧។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ជា សុខ ភេទស្រី (អត់មានរូបថតទេ)មានអាយុ៣០ឆ្នាំក្នុងឆ្នាំ១៩៧៦មានស្រុកកំណើតនៅ កៀនស្វាយ ខេត្តកណ្ដាលជាកូនរបស់ពូជាឆាំនិងមីង ស៊ុម យ៉ែម មានប្ដី ឈ្មោះស្រីយ៉តមានកូនស្រី២ នាក់ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរោងចក្រ ប-៤ ថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧៦។ខ្មែរក្រហមសម្លាប់ជាសុខនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល៧០ថ្ងៃ។ ប្ដីឈ្មោះ ស្រី យ៉ត ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃជាមួយប្រពន្ធដែរ តែនៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ជា សុខ ហេង មានអាយុ២២ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្រុក១៨(ស្រុកស្អាង)ខេត្តកណ្ដាល ជាកូនរបស់ពូអៀនិងមីងជាអុប ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកង ១៨(គ-២១)ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះគបន្ទប់ធំ៥ បន្ទប់តូច ១៦។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន២ ខុសគ្នាមួយនៅថ្ងៃទី១៥និងមួយទៀតនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ជាសុខហេងនៅថ្ងៃទី១៩ ខែមករា ឆ្នាំ ១៩៧៧។

ជា សំផុន ហៅ ទោម មានអាយុ២០ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅ សណ្ដាន់ ខេត្តកំពង់ធំ ជាកូនរបស់ពូជេ ជាម និងមីង អ៊ុន កាយ ត្រូវបានខ្មែរក្រហម ចាប់ខ្លួននៅមន្ទីរកងពល៣១០ ថ្ងៃទី២២ ខែមករា ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ជាសំផុននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៧បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល៦១ថ្ងៃ។

ជា ហឿង អតីតគ្រូបង្រៀននៅបារាយណ៍ ខេត្តកំពង់ធំ ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងគឺនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៧៦ រីឯកាលបរិច្ឆេទ នៃការសម្លាប់មានភាព មិនស៊ីសង្វាក់គ្នាទេ មួយនៅថ្ងៃទី១៨ ខែកុម្ភៈ និងមួយទៀតនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ ១៩៧៦ដូចគ្នា។

ជា សំសុត អតីតទាហានសក្តិ៣ មកពីប្រទេសបារាំង ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទ នៃការមកដល់គុកទួលស្លែង

និងការសម្លាប់នៅឡើយ។

ជា ឡាំងហ៊ាង មានអាយុ៣៨ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកោះសូទិន ខេត្តកំពង់ចាម មានប្តីឈ្មោះកែវផាតក្រុមភូមិសាស្ត្រកងពល៣១០ មានកូនស្រី៤នាក់ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ ថ្ងៃទី៦ ខែកុម្ភៈឆ្នាំ១៩៧៧ហើយសម្លាប់ចោលនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល៤០ ថ្ងៃ ។សូមមើលព័ត៌មានលម្អិតអំពីកែវផាតឬកែវផាត់ពីខាងដើម។

ជា ឡុង(ជាឡុង)ជាប្រពន្ធហោធូរេនត្រូវបានខ្មែរក្រហមឃាត់ខ្លួនអគ្គីសនីទី២ថ្ងៃទី៩ខែវិច្ឆិកាឆ្នាំ១៩៧៦ហើយសម្លាប់ចោលនៅថ្ងៃដដែល។ ចំណែកប្តីឈ្មោះ ហោធូ រេន ត្រូវបានខ្មែរក្រហមចាប់បញ្ចូលគុកទួលស្លែងមុនប្រពន្ធ ហើយកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន៣ខុសគ្នាមួយនៅថ្ងៃទី២០ខែកុម្ភៈមួយទៀតនៅថ្ងៃទី២៧ ខែមីនានិងមួយទៀតនៅថ្ងៃទី៥ខែមេសាឆ្នាំ១៩៧៦ដូចគ្នា។ ខ្មែរក្រហមសម្លាប់ប្តីនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៦។ កូនស្រីម្នាក់ឈ្មោះហោស៊ុនណារ៉េតត្រូវបាន ខ្មែរក្រហមចាប់និងសម្លាប់នៅថ្ងៃជាមួយម្តាយ។

ជា ឡូជាយុទ្ធជននៅកង១៣មន្ទីរស-២១យត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅស-២១យក្នុងឆ្នាំ១៩៧៦។កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងគឺនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី១១ខែឆ្នាំដដែល។

ជា អន មានអាយុ៣៥ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅព្រៃឈរខេត្តកំពង់ចាមជាកូនរបស់អ៊ំជា និងអ៊ំស្រីស៊ិមមានប្រពន្ធឈ្មោះសីង មែន មានកូនប្រុស១នាក់ និងស្រី១នាក់ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ ថ្ងៃទី២៧ ខែកញ្ញាឆ្នាំ១៩៧៦ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះឆបន្ទប់ធំ៣បន្ទប់តូច១៤។កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងគឺនៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២៨ខែមករាឆ្នាំ១៩៧៧។

ជា អាង ហៅជារ៉េន មានអាយុ២៣ឆ្នាំ ក្នុងឆ្នាំ១៩៧៥ ស្រុកកំណើតនៅកំពង់ស្វាយ ខេត្តកំពង់ធំ ឪពុកម្តាយខិវ និងចែមចាប់ខ្លួនថ្ងៃទី៤ខែមករាឆ្នាំ១៩៧៧។

ជាប ជុនហ៊ិត មានអាយុ២៨ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកញ្ជៀច ខេត្តព្រៃវែង ជាកូនរបស់ពូជាប ហុង និងមីងទូចផន មានប្រពន្ធឈ្មោះហ៊ិត ទីយូអេងមានកូនប្រុស២ នាក់និងស្រី១ នាក់ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅតាខ្មៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះកបន្ទប់ធំ០៦បន្ទប់តូច៩។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ជាប ប៉ារ៉ូ ហៅប៉ែន មានអាយុ៣៥ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅព្រែកប្រសប់ ខេត្តក្រចេះ ជាកូនរបស់អ៊ំជាបញ៉ឹម និងអ៊ំស្រីជូវដែត មានប្រពន្ធឈ្មោះយុតផន មានកូនប្រុស៤នាក់និងស្រី១នាក់ត្រូវបាន ខ្មែរក្រហមចាប់ខ្លួននៅកងពល៤៥០ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ជាបប៉ារ៉ូនៅថ្ងៃទី៦ខែកក្កដាឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល១៣៨ថ្ងៃ។

ជាប ឡាំង ហៅសារឿន ជាយុទ្ធជនត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៧០ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមបញ្ជូនជាបឡាំងទៅដល់គុកទួលស្លែងនៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៧៦និងសម្លាប់ចោលនៅថ្ងៃទី១៩ ខែឆ្នាំដដែល បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល១១ថ្ងៃ។

ជាម កាន មានអាយុ២៦ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅទឹកជ្រៅខេត្តកំពង់ចាមជាកូនរបស់ពូដូងជាមនិងមីងទូចហុងត្រូវបានខ្មែរក្រហម ចាប់ខ្លួននៅត្បូងឃ្មុំថ្ងៃទី២ខែកុម្ភៈ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំង នៅគុកទួលស្លែងក្នុងផ្ទះ៥បន្ទប់ធំ៤។

ជិន ដួន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៥០២ ថ្ងៃទី៨ខែវិច្ឆិកាឆ្នាំ១៩៧៦ និងសម្លាប់ចោល នៅថ្ងៃទី២១ ខែធ្នូឆ្នាំ១៩៧៦បន្ទាប់ពីជាប់ឃុំឃាំង អស់រយៈពេល៤៤ថ្ងៃ។

**(តទៅលេខក្រោយ)**

**វ៉ាន់ ថាន់ពៅដារ៉ា និង ឡុង ដានី**

# “ផេះផង់ធូលី”
# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ
# ឡាំ សុំ ៖ អធិការកិច្ច សាលារៀន

***កូនស្រីរបស់គាត់ឡាំតារាវិទ្ធិបានរៀបរាប់ប្រាប់ថា៖***

*នៅពេលយើងនៅតូច ឪពុករបស់យើងបានចូលចិត្តលេងជាមួយយើង គាត់បានតែងខ្លួនធ្វើជាដំរីមួយៗ គាត់បានយកពូកធំមួយបត់វាពាក់កណ្ដាល ហើយដាក់ពូកបត់នោះនៅលើក្បាលរបស់គាត់ៗ បន្ទាប់មកគាត់បានសន្ធឹងដៃរបស់គាត់យោលទៅយោលមកនិងដើរតាមយើងៗគាត់បានដេញតាមគ្រប់គ្នានៅក្នុងផ្ទះៗ*

*គាត់បានធ្វើការងារអធិការកិច្ចសាលារៀនជាច្រើនដើម្បីឲ្យមានចំណូលជីវភាពរស់នៅ វាមិនមានបញ្ហាអ្វីឡើយចំពោះសាលារៀនទាំងនោះរួមមាន៖ សាលារៀនឯកជន ចិនឬបារាំងៗ គាត់ធ្លាប់បានធ្វើជា គ្រូបង្រៀនម្នាក់នៅមុនពេលជាអធិការកិច្ចៗ ខ្ញុំចាំបាននៅថ្ងៃមួយគាត់បានទៅហាវ៉ៃហើយបានត្រឡប់មកវិញដោយមានខោច្រើនសម្រាប់យើងទាំងអស់គ្នា ខោទាំងនោះមានឆ្នូតច្រើន និងពណ៌ឆើតឆាយៗ*

*យើងទាំងអស់គ្នាបានទៅរៀន សាលាបារាំងដែលនៅទីនោះមានគ្រូបង្រៀនពីរនាក់ នៅក្នុងថ្នាក់រៀនតែមួយម្នាក់ជាជនជាតិខ្មែរ និងម្នាក់ទៀតជាជនជាតិបារាំងៗ បងប្អូនប្រុសៗខ្ញុំទាំងអស់បានចាកចេញ ពីប្រទេសកម្ពុជានៅមុនឆ្នាំ១៩៧០ព្រោះពួកគេ បាននិយាយ ភាសាបារាំង យ៉ាងស្ទាត់ៗ ឪពុករបស់ខ្ញុំបាន សរសេរសំបុត្រជាច្រើនទៅកូនៗជាភាសា*



*នៅកណ្ដាល ៖ ឡាំ សុំ និង ម៉េង គីមសុន ជាមួយកូនៗឈ្មោះ គីម និង ប៉ារ៉ាម នៅក្នុងពិធីមួយធ្វើនៅក្នុងស្ដាតអូឡាំពិក ឆ្នាំ១៩៦០*

បារាំង។ គាត់ក៏ចេះនិយាយភាសាអង់គ្លេស វៀតណាម ចិន (ម៉ានដារីន និងកានទុន)ដែរ។ នៅពេលដែលខ្ញុំទៅផ្សារ ឪពុកខ្ញុំអាចនិយាយទៅកាន់អ្នកលក់នៅទីនោះ ជាភាសាចិន និងវៀតណាម។

នៅថ្ងៃយោធារបស់ ប៉ុល ពត បានចូលទីក្រុងភ្នំពេញ ឪពុកម្តាយរបស់ខ្ញុំបានហោះទៅក្រុងព្រះសីហនុ ជាទីកន្លែងដែលគាត់ទិញបានដីមួយឡូត៍។ គាត់ចង់រស់នៅក្បែរឆ្នេរសមុទ្រនៅពេលដែលគាត់ចាស់ទៅ។ ឪពុកខ្ញុំស្រឡាញ់ដីធ្លី គាត់បានទិញដីនៅក្នុង ក្រុងកែប ស្រែអំបិល និងក្រុងព្រះសីហនុ។គាត់ក៏បានស្រឡាញ់ការដាំដុះរួមមានផ្កា រុក្ខជាតិ និងដើមឈើហូបផ្លែដែរ។ វាជាចំណង់ចំណូលចិត្តរបស់គាត់ ហើយខ្ញុំក៏មានចំណូលចិត្តដូចគាត់ដែរ។ ហេតុដូច្នេះ ម្តាយខ្ញុំនិយាយថាខ្ញុំកាត់ទៅរកឪពុកខ្ញុំ។

ឪពុកមាររបស់ម្តាយខ្ញុំបានរស់នៅទីក្រុងព្រះសីហនុ។ គាត់ជាមេបញ្ជាការទាហាន លន់ នល់ ហើយបានសុំអ្នកបើកបររបស់គាត់ឲ្យជូនឪពុកម្តាយខ្ញុំទៅកំពង់ផែ ហើយចុះក្នុងទូកមួយទៅប្រទេសថៃ។ឪពុកខ្ញុំចង់ទៅ ប៉ុន្តែម្តាយខ្ញុំបានបដិសេធ ព្រោះអីកូនរបស់គាត់ទាំងអស់ នៅភ្នំពេញនៅឡើយ។ឪពុកមាររបស់ម្តាយខ្ញុំបានចាកចេញទៅ គាត់កំពុងរស់នៅប្រទេសបារាំងសព្វថ្ងៃនេះ។

ខ្មែរក្រហមបាននិយាយថា “សូមមេត្តា ចាកចេញជាប្រញាប់”បន្ទាប់មកបានបាញ់រះទៅលើមេឃ។ ដូច្នេះបងប្រុសខ្ញុំប្អូនស្រីៗ និងខ្ញុំបានវេចខ្ចប់យ៉ាងប្រញាប់យកបានអាហារសម្រាប់ហូបគ្រប់គ្រាន់តែពីរ បីថ្ងៃ ប៉ុណ្ណោះ ដូចជាអង្ករឆ្នាំងមួយ និងចានជាច្រើន។ យើងបានចាកចេញពីផ្ទះនៅថ្ងៃទី១៨ខែមេសា។ ប្អូនស្រីខ្ញុំបានខ្ចប់គ្រឿងអលង្ការរបស់ម្តាយខ្ញុំដាក់ក្នុងវ៉ាលីសមួយ ជាមួយនឹងរបស់មានតម្លៃផ្សេងទៀត ហើយបានដាក់វ៉ាលីសនោះចូលទៅក្នុងប្រឡោះមួយនៅខាងលើបន្ទប់របស់យើង។ នៅពេលយើងបានត្រឡប់មកវិញបន្ទាប់ពីរបបខ្មែរក្រហមមិនមានអ្វីនៅក្នុងប្រឡោះនោះឡើយ។



ឡាំ សុំ ជាមួយកូនស្រីៗ គីម, អណ្តែត, ម៉ុល និង តារាវិទ្ធិ នៅភ្នំពេញ ឆ្នាំ១៩៧១

ប្ដីរបស់បងស្រី ខ្ញុំឈ្មោះសុភី បានសម្រេចចិត្តថាយើងត្រូវទៅស្រុកកំណើត របស់គាត់នៅខេត្តព្រៃវែង។យើងមានគ្នា១១នាក់ បានដើរចេញទៅជាមួយគ្នា។ ប៉ុន្តែយើងបួននាក់បានចាកចេញពីព្រៃវែង ទៅកំពត ពីរបីថ្ងៃបន្ទាប់ពីយើងទៅដល់ព្រៃវែង ព្រោះអីយើងចង់ទៅរកឪពុកម្ដាយរបស់យើងហើយ យើងក៏មិនដឹងថាត្រូវរស់យ៉ាងម៉េចនៅព្រៃវែងដែរ។

វាទទេស្អាតនៅទីនោះ គឺមានតែវាលស្រែប៉ុណ្ណោះមិនមានដើមឈើហូបផ្លែឡើយ។ បងប្រុសខ្ញុំឈ្មោះ ថូរ៉ានី បាននាំយើងចេញទៅ។យើងចំណាយពេលជិតពីរខែបានទៅដល់ស្រុកកំណើតម្ដាយរបស់ខ្ញុំដោយយើងដោយថ្មើរជើងត្រឡប់ទៅក្រោយវិញ។ ខ្មែរក្រហមបានបន្តចាប់យើង ហើយបង្ខំឲ្យយើងធ្វើការប៉ុន្តែយើងបានបន្ត រត់គេចខ្លួន។នៅពេលយើងបានទៅដល់អ្នកដំបូងគេដែល ខ្ញុំបានឃើញគឺជាឪពុកខ្ញុំកាន់ចបកាប់មួយ។ មុននោះគាត់មានក្បាលពោះ ប៉ុន្តែឥឡូវនេះគាត់ស្គមខ្លាំងណាស់។ គាត់បានចាប់ផ្ដើមយំ នៅពេលដែលគាត់បានឃើញយើងហើយនិយាយថា“ ប៉ាបានរង់ចាំកូនទាំងអស់គ្នានៅទីនេះរាល់ថ្ងៃ។ ប៉ាបានបន់ស្រន់សម្រាប់កូនទាំងអស់គ្នាហើយបានរង់ចាំ”។ ភ្លាមៗនោះយើងទាំងអស់គ្នាបានយំ។

គាត់បានរស់នៅជាងពីរឆ្នាំ ឃ្វាលក្របី វែកដី និងធ្វើការងារផ្សេងច្រើនទៀត។គាត់បានជញ្ជូនដីនៅទីវត្ត ជាទីដែលខ្មែរក្រហមបានប្រាប់គាត់ថា គាត់មិនអាចត្រឡប់ទៅភ្នំពេញបានទេហើយក៏មិនមានមុខងារ ជាបុគ្គលដែលមានការអប់រំទៀតដែរ។ខ្មែរក្រហមបាន និយាយថាអ្នកឯងត្រូវធ្វើការឥឡូវនេះ។



**ឡាំ ស៊ុំ ជាមួយកូន៧នាក់ ក្នុងចំណោមកូន១៣នាក់ នៅភ្នំពេញ ឆ្នាំ១៩៧១**

នៅឆ្នាំ១៩៧៦ បងប្រុសខ្ញុំ ប្អូនស្រី និងខ្ញុំត្រូវបានបញ្ចូលទៅក្នុងកងចល័ត។ ដំបូងឡើយខ្មែរក្រហម បានឲ្យយើងមកផ្ទះនៅពេលយប់ ប៉ុន្តែ បន្ទាប់មក ខ្មែរក្រហមបានបញ្ជូនយើងកាន់តែឆ្ងាយទៅៗ។ ខ្ញុំបានរៀនធ្វើមួកស្លឹកត្នោតខណៈដែលខ្ញុំនៅក្នុងកងចល័ត។មួកនីមួយៗត្រូវប្រើពេលបួន

ទៅប្រាំម៉ោងដើម្បីធ្វើ ប៉ុន្តែខ្ញុំអាចធ្វើម្ជូកបាននៅតែពេលយប់ ដូច្នេះ ខ្ញុំត្រូវការពេលប្រាំឬប្រាំមួយយប់សម្រាប់ម្ជូកនីមួយៗ។ ខ្ញុំធ្វើម្ជូកបានច្រើនដើម្បីដូរយកក្តាម ឬអាហារផ្សេងៗនៅពេលខ្ញុំត្រូវការ។ នៅពេលដែលខ្ញុំបានដឹងថា ខ្ញុំនឹងត្រូវបានអនុញ្ញាតឲ្យទៅផ្ទះខ្ញុំបានធ្វើម្ជូកទុកជាច្រើន ដូច្នេះខ្ញុំអាចយកម្ជូកទៅដូរយកថ្នាំជក់ឲ្យឪពុករបស់ខ្ញុំ។ឪពុកខ្ញុំចូលចិត្តថ្នាំជក់ជាងចំណីអាហារ។

យើងមិនបាននៅទីនោះទេនៅពេលដែលខ្មែរក្រហម បានចាប់ឪពុកខ្ញុំទៅ។ អ្នកជិតខាងរបស់យើងបាននិយាយថា ឪពុករបស់ខ្ញុំត្រូវបានចាប់ខ្លួនហើយគាត់ត្រូវបានយកទៅដាក់នៅវត្តមួយ។ ខ្មែរក្រហមបានចោទប្រកាន់គាត់អំពីចំណង់រត់ភៀសខ្លួនចេញពីភូមិ ដើម្បីទៅជួបបងប្រុសរបស់ខ្ញុំពីរនាក់ដែលបានរស់នៅបរទេស។ ខ្មែរក្រហមក៏បាននិយាយ ដែរថា គ្មាននរណាម្នាក់ត្រូវធ្វើតាមឪពុកខ្ញុំ ឬធ្វើរឿងដូចដែលឪពុកខ្ញុំបានធ្វើឡើយ។ ខ្មែរក្រហមបានយកឪពុកខ្ញុំទៅមន្ទីរសន្តិសុខទូកមាស។ នៅតាមផ្លូវខ្មែរក្រហមបានវាយគាត់នឹងដើមអំពៅរឹង មិនមែនអំពៅទន់ដែលយើងហូបទេ។ ដើមអំពៅធំនិងរឹង។ បន្ទាប់ពីរបប ប៉ុល ពត ខ្ញុំបានឃើញសៀវភៅមួយរបស់ក្រសួងអប់រំ បានសរសេរអំពីឪពុករបស់ខ្ញុំ។ សៀវភៅនោះបានសរសេរថាខ្មែរក្រហមបានបញ្ជូន ឪពុកខ្ញុំចេញពីទូកមាសទៅមន្ទីរសន្តិសុខល្អាង នៅក្នុងខេត្តកំពតហើយបានសម្លាប់គាត់នៅទីនោះ។

ម្តាយខ្ញុំបានស្នាក់នៅផ្ទះរយៈពេល១០ថ្ងៃ បន្ទាប់យកឪពុកខ្ញុំទៅ។ គាត់បាននិយាយទៅកាន់អង្គការថា“ប្រសិនបើអង្គការត្រូវការនៅទីនេះមានកូនទាំងបួននាក់របស់ខ្ញុំ និងខ្ញុំ។ អ្នកអាចសម្លាប់យើងទាំងអស់គ្នា”។ ម្តាយខ្ញុំ បានខូចចិត្តយ៉ាងខ្លាំង។បន្ទាប់មកខ្មែរក្រហមបានយកគាត់ចេញទៅ រួមទាំងប្រជាជនមកពីភ្នំពេញស្ទើរតែទាំងអស់។ខ្ញុំបានរង់ចាំការហៅឈ្មោះម្តាយរបស់ខ្ញុំ ប៉ុន្តែពេលនោះមិនបានហៅទេ។

ម្តាយមីងម្នាក់ នៅក្នុងចំណោមម្តាយមីងរបស់ខ្ញុំច្រើននាក់ ដែលបានរស់នៅខាងក្រោមផ្ទះដែលយើងបានស្នាក់នៅរួមគ្នា។ គាត់ជាប្រធាននារីនៅក្នុងភូមិ។ គាត់កាចខ្លាំងណាស់ហើយខ្ញុំក៏ស្អប់គាត់ខ្លាំងណាស់ដែរ។ គាត់តែងតែបានប្រាប់កូនរបស់គាត់ឲ្យតាមដានយើង៖ តើយើងបានធ្វើអ្វីខ្លះ? យើងហូបអ្វីខ្លះ? និងមានរបស់របរអ្វី? នៅពេលខ្លះពូរបស់ខ្ញុំបានសុំមីងមេត្តាឲ្យយើងនូវចំណីអាហារ ប្រសិនជាមីងមានច្រើនប៉ុន្តែគាត់បានធ្វើជាមិនចង់ស្តាប់។ ទោះយ៉ាងណាគាត់បានទុកចំណីអាហារនោះទាល់តែរលួយខូច ជាជាងឲ្យមកយើង។គាត់បានដឹងថាជីដូនរបស់ខ្ញុំ បានរក្សាទុកនូវផ្តិលទឹកធំមួយដែលធ្វើអំពីប្រាក់។ គាត់បានរាយការណ៍ អំពីជីដូនខ្ញុំប្រាប់អង្គការដោយនិយាយថា ជីដូនខ្ញុំមិនស្មោះត្រង់។បន្ទាប់មកកម្មាភិបាលបានទៅផ្ទះគាត់ ហើយប្រមូលយករបស់របរទាំងអស់។បន្ទាប់ពីរបប ប៉ុល ពត នៅទីនោះមិនមានអ្វីហូបឡើយហើយក៏មិនមានអ្វីសម្រាប់មីងខ្ញុំដែរ។ ប្រសិនបើមីងខ្ញុំឲ្យជីដូនខ្ញុំរក្សាទុកផ្តិលទឹកធំនោះ គាត់នឹងបានលក់វាដើម្បីយកប្រាក់ទិញស្បៀងអាហារសម្រាប់ហូប។ ជីដូនខ្ញុំតែងតែថែរក្សាបីបាច់គ្រួសាររបស់គាត់។

នៅថ្ងៃដែលឪពុករបស់ខ្ញុំ ត្រូវបានចាប់យកទៅមន្ទីរសន្តិសុខមីងបាននិយាយថា វាត្រូវតែដូច្នេះព្រោះអីឪពុករបស់ខ្ញុំសក្តិសមនឹងទទួលកំហុស។បន្ទាប់ពីរបបប៉ុល ពតខ្ញុំបានទៅលេងស្រុកកំណើតរបស់ម្តាយខ្ញុំហើយខ្ញុំបានឃើញមីងខ្ញុំ។គាត់និយាយថា“អ្នកឯងល្អណាស់ហើយនិយាយពិរោះ”ដូចជាមិនមានរឿងអ្វីបានកើតឡើង។ គាត់បានភ្លេចនូវអ្វីដែលគាត់បានធ្វើនៅក្នុងសម័យ ប៉ុល ពត។

នៅពេលខ្លះ ខ្ញុំគិតអំពីមីងខ្ញុំ និងអ្នកខ្លះផ្សេងទៀតនៅក្នុងភូមិរបស់យើង ខ្ញុំខឹងជាខ្លាំង។ ប៉ុន្តែខ្ញុំមិនចង់សងសឹកព្រោះអីឥឡូវនេះយើងរស់នៅក្នុងសន្តិភាព។ ប្រជាជនទាំងអស់នៅក្នុងភូមិជីដូនជីតា របស់ខ្ញុំ នៅតែក្រនៅឡើយ។ អ្នកទាំងនោះបានប្រមូលអ្វីៗទាំងអស់ពីយើង នៅអំឡុងសម័យ ប៉ុល ពត ប៉ុន្តែពួកគេនៅតែក្រ។ ពួកគេមិនមានអ្វីធ្វើ មិនមានការអប់រំដូច្នេះនៅតែក្រីក្រ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**



រូបថតក្របក្រោយ ៖ អ៊ុយ ឈុនណា ជនភៀសខ្លួនដែលបានសុំធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាវិញក្នុងឆ្នាំ១៩៧៦

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥*

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 238, October 2019 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 0291 P.M/99, 2 August 1999.